# ស្វែងរក
# ការពិត



- ការផ្សះផ្សានៅប្រទេសកម្ពុជា

លេខ៥៥ ខែកក្កដា ឆ្នាំ២០០៤

ស្វែងរកការពិត

លេខ៥៥ ខែកក្កដា ឆ្នាំ២០០៤

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ទិវាជាតិដើម្បីការចងចាំនិងយុត្តិធម៌ ............................១

**ផ្នែកឯកសារ**

◆ នូ ស៊ូឡុត ហៅ ឡែម អតីតជំនួយការកងពលលេខ៩២០ ..........២

◆ កិច្ចប្រជុំពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ-កូរ៉េ .....................៥

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ ..........៦

◆ ដំណើរការកសាងកសិកម្មនិងឧស្សាហកម្ម................................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ យុទ្ធនារីផលិតអំបិល ....................................................១១

◆ យុទ្ធជនធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ..........................១៣

◆ មិនព្រមរៀបការជាមួយយុទ្ធជនពិការ.................................១៦

◆ យុទ្ធនារីបើកឡានដឹកដី...................................................១៩

◆ នៅតែមានសង្ឃឹម .........................................................២១

◆ ស្រុកឈូកក្នុងសម័យបដិវត្តន៍ .........................................២៣

◆ មិនបានរៀនព្រោះរវល់ធ្វើបដិវត្តន៍ ....................................២៦

**ផ្នែកច្បាប់**

◆ ជម្លោះនៅដាហ្វ៊ួរ .........................................................៣០

**វេទិកាពិភាក្សាសាធារណៈ**

◆ សុន្ទរកថារបស់ឯកឧត្ដម កូហ្វី អាណាន់..............................៣៥

◆ ការផ្សះផ្សានៅកម្ពុជា ....................................................៤០

◆ យោធាខេមរភូមិន្ទម្នាក់មានយោបល់ ..................................៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ អ្នកភូមិត្រពាំងកកោះសុំឲ្យជួយរកគ្រួសារ ...........................៥៩



បូជនីយដ្ឋានក្នុងខេត្តស្វាយរៀង

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** យិន នាន, ឆេង វើង, អៀ រតនា, ដាន់ សុជា, ប៉ាង ពីរ៉ែន, ផេង ពង្សរ៉ាស៊ី, ជុំ តែម, សារិន វីរៈ, កូហ្វី អាណាន់, ស៊ូហ្សាណា លីនគុន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្វួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រ:*

# ទិវាជាតិដើម្បីការចងចាំនិងយុត្តិធម៌

ខ្ញុំបាទសូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យបង្កើត «ទិវាជាតិដើម្បីការចងចាំនិងយុត្តិធម៌» ដែលនឹងប្រារព្ធឡើងនៅថ្ងៃទីមួយនៃដំណើរការរបស់តុលាការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ទិវានេះនឹងអនុញ្ញាតឲ្យប្រជាជនកម្ពុជាគោរពវិញ្ញាណក្ខន្ធសាច់ញាតិជាទីស្រលាញ់ទាំងឡាយដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម និងអនុញ្ញាតឲ្យអ្នកនៅរស់ពីរបបខ្មែរក្រហមរំឭកអំពីជីវិតរបស់ខ្លួននៅក្នុងរបបនេះ ព្រមទាំងផ្លាស់ប្តូរបទពិសោធន៍ផ្ទាល់ខ្លួនជាមួយអ្នកដទៃ ។ ព្រមជាមួយគ្នានេះដែរ ប្រជាជនកម្ពុជាទូទាំងប្រទេសអាចចាប់ផ្តើមចូលរួមតាមដានដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមកញ្ចក់ទូរទស្សន៍ ឬស្តាប់តាមវិទ្យុ ហើយក៏អាចកត់សម្គាល់ថា នៅទីបំផុត ប្រទេសកម្ពុជាកំពុងតែធ្វើដំណើរឆ្ពោះទៅរកការទទួលខុសត្រូវនិងយុត្តិធម៌នៅក្នុងដំណាក់កាលនេះនៃប្រវត្តិសាស្ត្ររបស់យើង ។

«ទិវាជាតិនៃការចងចាំនិងយុត្តិធម៌» នឹងផ្តល់ដល់រាជរដ្ឋាភិបាលកម្ពុជានូវឱកាសដ៏ប្រពៃមួយ ដើម្បីបង្ហាញថារាជរដ្ឋាភិបាលកម្ពុជាកំពុងតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ហើយអាចលះបង់ចោលនូវការបែងចែកគ្នា និងងាកមកគាំទ្រការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីផលប្រយោជន៍កាន់តែទូលំទូលាយរបស់ប្រជាជនកម្ពុជា ។ ការអនុញ្ញាតឲ្យសាធារណជនចូលមកអង្គុយនៅក្នុងតុលាការដើម្បីតាមដានដំណើរការកាត់ក្តី គឺជាការវិវឌ្ឍន៍ដ៏សំខាន់មួយសំដៅធានាឲ្យបាននូវការយកចិត្តទុកដាក់ចំពោះប្រជាជននិងគុណភាពខ្ពស់នៃតុលាការ ។

**ឆាំង យុ**



ប្រជាជនគាស់ឆ្អឹងជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# នូ ស៊ូឡុត ហៅ ឡែម អតីតជំនួយការកងពលលេខ៩២០

នូ ស៊ូឡុត ហៅ ឡែម ជាកូនកាត់ខ្មែរ-ឡាវ និងជាអតីតជំនួយការកងពលលេខ៩២០ ។ ឡែម ចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៦៨ តាមរយៈ អ៊ុំ ផាន់ ហើយក៏ត្រូវបាន ផាន់ បញ្ចុះបញ្ចូលឲ្យក្បត់នឹងបដិវត្តន៍ ។ ឡែម នៅក្នុងជួរបដិវត្តន៍បានប្រហែល១០ឆ្នាំ ក៏ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ ហើយកម្ទេចចោលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ ។

ឡែម រស់នៅជាមួយជីដូននៅភូមិស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងរៀននៅសាលាវត្តស្រះកែវមណីវណ្ណបានត្រឹមថ្នាក់ទី១២ (ថ្នាក់ទី១បច្ចុប្បន្ន) ។ នៅឆ្នាំ១៩៥៨ ឪពុករបស់ ឡែម បាននាំ ឡែម ឲ្យទៅរស់នៅជាមួយថៅកែឡានឈ្មោះ ហ៊ុក លឿង នៅភូមិបរកែវ ស្រុកអណ្តូងពេជ្រ ខេត្តរតនគិរី ។ អំឡុងពេលរស់នៅជាមួយថៅកែ លឿង, ឡែម បានបន្តការសិក្សារហូតដល់ថ្នាក់ទី៨ ។ នៅឆ្នាំ១៩៦២-៦៣ ឡែម បានវិលត្រឡប់មករស់នៅជាមួយក្រុមគ្រួសារនៅភូមិបញ្ចុះ ឃុំណងបាក់ ស្រុកអណ្តូងពេជ្រ ខេត្តរតនគិរី ប្រកបរបរជីកត្បូង ។ ពីឆ្នាំ១៩៦៣ ដល់ ឆ្នាំ១៩៦៨ ឡែម មករស់នៅភូមិបឡុយ ឃុំកេះចុង ស្រុកអណ្តូងពេជ្រ ខេត្តរតនគិរី ដោយប្រកបរបរជីកត្បូងនិងធ្វើចម្ការ ។

នៅឆ្នាំ១៩៦៨ ឡែម ចូលបម្រើបដិវត្តន៍តាមការអូសទាញរបស់ អ៊ុំ ផាន់ ដែលបាននាំ ឡែម ចូលព្រៃមួយឈ្មោះអូរឡាង នៅភ្នំតុកតូន ។ ទៅដល់ទីនោះ អង្គការបានចាត់តាំង ផាន់ ឲ្យធ្វើជាប្រធានភូមិ ហើយ ឡែម ធ្វើជាឈ្លបភូមិ ។ ធ្វើការជាមួយគ្នាយូរ ផាន់ ក៏មានការទុកចិត្តលើ ឡែម ហើយបាននិយាយអំពីបដិវត្តន៍ឆ្នាំ១៩៥៤ឲ្យ ឡែម ស្តាប់ ។ ផាន់ អប់រំ ឡែម ឲ្យធ្វើគិញ ដោយពន្យល់ប្រាប់ពីផលប្រយោជន៍ដែលទទួលបានគឺ ១) រស់នៅសប្បាយមានបុណ្យស័ក្តិ ២) បើធ្វើបដិវត្តន៍បន្តទៀតមានតែសេចក្តីស្លាប់ប៉ុណ្ណោះ ។ បន្ទាប់ពីយល់សេចក្តីមក ឡែម ក៏យល់ព្រមធ្វើគិញ ។ ផាន់ បានដាក់ភារកិច្ចមួយចំនួនឲ្យ ឡែម បំពេញគឺ ១) ក្តាប់មូលដ្ឋានបដិវត្តន៍និងក្បាលម៉ាស៊ីនដឹកនាំ ២) ក្តាប់កន្លែងលាក់ស្បៀងនិងឃ្លាំងសម្ភារផ្សេងៗ ៣) ក្តាប់សភាពការណ៍ប្រជាជនដើម្បីកៀងគរទៅតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ។ ប្រសិនបើក្តាប់ភារកិច្ចទាំងអស់នេះបានហើយត្រូវរាយការណ៍ឲ្យមេគិញឈ្មោះ គត់ ដើម្បីនាំទាហានមកវាតត្បាតកម្ទេចមូលដ្ឋានបដិវត្តន៍និងកៀរយកប្រជាជន ។ ផាន់ បានណែនាំ ឡែម ឲ្យស្គាល់គិញបីនាក់គឺឈ្មោះ សាំង, ភុន និង ដែង ដើម្បីធ្វើការងារជាមួយគ្នា ។ កម្លាំងរបស់ ឡែម បានបំភ័យប្រជាជនថា ទាហានព័ទ្ធភូមិហើយ ដើម្បីឲ្យប្រជាជនរត់ទៅលាក់ខ្លួនក្នុងព្រៃ បើកឱកាសឲ្យគិញដើរវាតត្បាតនិងស៊ើបការណ៍ក្នុងមូលដ្ឋានរបស់ខ្លួន ។ ឈ្មោះ សាំង នៅខាងជើងទន្លេដែលក្តាប់បានមូលដ្ឋានបដិវត្តន៍ក៏ទៅរាយការណ៍ឲ្យ គត់ ។ ទៅដល់ពាក់កណ្តាលផ្លូវ សាំង ត្រូវកងឈ្លបចាប់ខ្លួន ហើយជាប់ទាំងឈ្មោះ ផាន់ និង ដែង ទៀត ។ អ្នកទាំង៣ត្រូវកងឈ្លបកម្ទេចចោលគ្មានសល់ ។ ឡែម ដែលដាច់ខ្សែរយៈទាក់ទង ក៏ចង់ត្រឡប់មកផ្ទះវិញ ពីព្រោះនៅក្នុងព្រៃលំបាកពេក ។

នៅឆ្នាំ១៩៦៩ ឡែម ត្រូវអង្គការចាត់តាំងឲ្យធ្វើឈ្លបនៅតំបន់ទី១ភូមិភាគឦសាន ហើយបានធ្វើសកម្មភាពជាច្រើនដើម្បីបំផ្លាញបដិវត្តន៍ ដូចជា ១) បាញ់កាំភ្លើងដាក់ទាហានពីចម្ងាយធ្វើឲ្យមូលដ្ឋានបដិវត្តន៍ត្រូវបែកការណ៍បណ្តាលឲ្យទាហានលន់ណុលផ្លោងកាំភ្លើងធំដាក់ប្រជាជន ២) ទុកឱកាសឲ្យទាហានឆ្លងមកបោះទីតាំងនៅភូមិតាឡាវត្រើយខាងជើងដើម្បីធ្វើសកម្មភាពកម្ទេចកម្លាំងបដិវត្តន៍ និងបំផ្លាញគោក្របីរបស់ប្រជាជន ។

នៅឆ្នាំ១៩៧០ ឡែម បានជួបជាមួយ បៃ ហើយជំនុំគ្នាលើកផែនការត្រៀមយកប្រជាជនភូមិតាឡាវនិងភូមិបឡុយទៅកម្ទេចនៅមន្ទីរអង្គការ ។ ផែនការនេះគ្រោងនឹងអនុវត្ត៣ថ្ងៃទៀត ប៉ុន្តែមិនទាន់ទាំងបានអនុវត្តផង បៃ បានធ្វើឲ្យបែកការណ៍ ហើយក៏ត្រូវឈ្លបចាប់យកទៅកម្ទេចចោល ។ នៅឆ្នាំដដែល ខ្មែរក្រហមបានកាន់កាប់ភូមិភាគឦសានទាំងមូល ។ ឡែម ត្រូវបានអង្គការ

ចាត់តាំងឲ្យដឹកជញ្ជូនអាវុធនិងគ្រាប់កាំភ្លើងដាក់ក្នុងឃ្លាំង ហើយមករៀនបច្ចេកទេសយោធានៅមន្ទីរ យ-៣២ នៅភូមិចាន់ ឃុំចាន់ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី ។ បន្ទាប់មក ឡែម ត្រូវបានតែងតាំងជាប្រធានកងតូចនៃអនុសេនាធំលេខ៨០៤ភូមិភាគឦសាន ប្រចាំការនៅអូរឬងការពារមន្ទីរនិងផ្លូវចេញចូលរបស់អង្គការ ។ នូ តែង ជាប្រធាននយោបាយ បានពន្យល់ ឡែម អំពីភាពខុសគ្នារវាងប្រទេសសង្គមនិយមនិងប្រទេសសេរី បន្ទាប់មកបានណែនាំ ឡែម ឲ្យស្គាល់ ថង ដាំ, ថង សាម៉ៃ និង ប៊ូ សាំង ។ ទាំងបីនាក់នេះធ្វើការនៅសេនាធិការភូមិភាគឦសាន ។ ក្រោយមកអង្គការបានបញ្ជាឲ្យ ឡែម ទៅការពារផ្លូវពេលកុម្ម៉ង់ដូចុះ ប៉ុន្តែ ឡែម មិនបានទៅទេ លុះគ្រាតែកុម្ម៉ង់ដូទៅបាត់ទើបទៅការពារ ។ រឿងរ៉ាវនេះត្រូវអង្គការដឹង ហើយហៅ ឡែម មកអប់រំកុំឲ្យធ្វើដូចនេះទៀត ។

ឡែម ត្រូវបានតែងតាំងជាអនុប្រធានយោធាកងពលធំ៨០៤ ប្រចាំការនៅភូមិប៉ុង ក្នុងឃុំវ៉ឺនសៃ ស្រុកវីរជ័យ ខេត្តរតនគិរី ។ ថង ដាំ បន្តបញ្ចុះបញ្ចូល ឡែម ឲ្យយល់ព្រមធ្វើការឲ្យបក្សពលករ ហើយបានណែនាំភារកិច្ចមួយចំនួនដូចជា ១)ពង្រឹងកម្លាំងស្នូលទាំងនៅក្នុងកងទ័ពនិងមូលដ្ឋានឲ្យរឹងប៉ឹង ២)កសាងកម្លាំងកងទ័ពឲ្យបានច្រើន ៣)កសាងកម្លាំងប្រជាជន ៤)ពង្រឹងមូលដ្ឋានបផ្អែកឲ្យរឹងមាំ និង៥)សហការនឹងកម្លាំងខាងក្រៅឲ្យជាប់ ។ ក្រោយពីណែនាំហើយ ថង ដាំ បានប្រាប់ឲ្យ ឡែម ទាក់ទងនឹងខ្សែរយៈ៧នាក់ទៀតដែលនៅភាគខាងជើង ។

ឡែម ចូលរួមប្រជុំនៅមន្ទីរវ៉ឺនសៃដែលមានគ្នាទាំងអស់៩នាក់ដើម្បីពិនិត្យផែនការចាស់ និងលើកផែនការថ្មីទៅថ្ងៃមុខ ។ ថង ដាំ បាននិយាយថា ផែនការកន្លងមកអនុវត្តមិនបានប្រសើរតាមសំណូមពរទេ ដូច្នេះត្រូវលើកផែនការថ្មីគឺ ១)ពង្រឹងកម្លាំងស្នូលក្នុងកងទ័ពនិងតាមមូលដ្ឋានឲ្យរឹងប៉ឹង ២)កសាងកម្លាំងកងទ័ពឲ្យបានច្រើននិងមានវិន័យរឹងប៉ឹង ៣)កសាងកម្លាំងប្រជាជនដើម្បីជាប្រភពផ្តល់កម្លាំង ៤)ពង្រឹងមូលដ្ឋានបផ្អែកឲ្យរឹងប៉ឹងដើម្បីលាក់ក្បាលម៉ាស៊ីនដឹកនាំ ៥)សហការកម្លាំងខាងក្រៅឲ្យជាប់ដើម្បីជួយដោះស្រាយរឿងហេតុកើតឡើង ។ ឡែម អប់រំនិងកសាងកម្លាំងបានម្នាក់ ហើយបានចុះទៅជួប ថង បៃ នៅភូមិកាចូ ឃុំវ៉ឺនសៃ ដើម្បីសាកសួរអំពីកម្លាំងដែលកសាងបាន ។ នៅឆ្នាំ១៩៧៣ ឡែម ត្រូវអង្គការដកមកការពារមន្ទីរនៅភូមិស្រែគរ ឃុំលេខ៣ ស្រុក៤២ តំបន់៦ ភូមិភាគឦសានវិញ ។

នៅឆ្នាំ១៩៧៣ដដែល ឡែម ត្រូវបានចាត់តាំងឲ្យទៅរៀនបច្ចេកទេសយោធានៅសាលា គ-៩២ របស់អង្គការមជ្ឈិមនៅភូមិក្រវ៉ា ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឆ្លៀតឱកាសនោះ ថង ដាំ បានផ្តែផ្តាំ ឡែម ឲ្យភ្ជាប់អ្នកមកពីខាងជើងដើម្បីងាយស្រួលទាក់ទងគ្នា ។ មកដល់សាលា ឡែម បានស្គាល់ ភីម និង ខាំ ដែលជាមនុស្សរបស់ ថង ដាំ ។ អ្នកទាំងពីរបានណែនាំ ឡែម ឲ្យទាក់ទង ឈ្មោះ សួរ និង គិន ជាជនជាតិលាវដែលជាជំនួយការបង្ហាត់បច្ចេកទេសយោធានៅសាលា គ-៩២ និងជានិសាររបស់ ភីម ។ ពេលត្រឡប់មកអង្គភាពវិញ ឡែម បានពាំនាំពាក្យរបស់ ភីម និង ខាំ មកប្រាប់ ថង ដាំ ឲ្យខំហ្វឹកហាត់បច្ចេកទេសទ័ពដើម្បីប្រយុទ្ធ ។ ថង ដាំ បានណែនាំ ឡែម ឲ្យស្គាល់ ប៉យ និង ចាន់ ដែង ។ ប៉យ បានរាយការណ៍អំពីស្ថានភាពអំណោយផលក្នុងការធ្វើសកម្មភាពនៅក្នុងស្រុកនេះដោយសារមូលដ្ឋានបផ្អែកនៅស្រុក៥៥ករឹងមាំល្អ និងមានទំនាក់ទំនងល្អជាមួយបងប្អូនវៀតណាម ។

អង្គការបានចាត់តាំងកងធំលេខ៨០៤ទៅសមរភូមិ ចំណែក ថង ដាំ ដឹកនាំកម្លាំង៧នាក់មកប្រជុំនៅមន្ទីរស្រែគរ ។ ខ្លឹមសារនៃការប្រជុំគឺ ១)ទាក់ទងខ្សែរយៈមកពីភាគខាងជើងដើម្បីបន្ថយកម្លាំងប្រយុទ្ធរបស់បដិវត្តន៍ ២)ភ្ជាប់សភាពការណ៍ប្រជាជនដែលនៅជិតតំបន់ឃ្លាំង ហើយអប់រំនិងបំផុសតាមសភាពជាក់ស្តែង ៣)ភ្ជាប់សភាពការណ៍ឃ្លាំងឲ្យជាប់ ។ នៅពេលចូលសមរភូមិ កងធំលេខ៨០៤ត្រូវបានបញ្ចូលទៅក្នុងកងវរសេនាធំលេខ៣ កងពលលេខ១៤ បន្ទាប់មកអង្គការបានបញ្ជូនកងអនុសេនាធំលេខ៨០២ តំបន់៦ភូមិភាគឦសានដែលមានឈ្មោះ សុត និង ថង វ៉ាន់ ជាអ្នកទទួលខុសត្រូវ ។ ឡែម ស្នាក់នៅជាមួយ ថង វ៉ាន់ និង សុត ។ កងរបស់ ឡែម មិនបានស៊ើបការណ៍ឲ្យបានច្បាស់លាស់មុនពេលប្រមូលទ័ពចូលខ្សែត្រៀមទេ ។ ឡែម បានយកកាំភ្លើង១០ដើមនិងគ្រាប់មួយចំនួនព្រមទាំងយកអង្ករនិងអំបិលដាក់កណ្តាលភូមិ ធ្វើឲ្យបែកការណ៍ ហើយត្រូវយន្តហោះកម្ទេចចោលអស់ ។ នៅសមរភូមិផ្សារដែកខត្តុង្គ ឡែម ដកទ័ពចេញពី

ខ្សែត្រៀម ហើយបំផុសឲ្យយុទ្ធជនក្នុងកងទាមទារត្រឡប់ទៅភូមិវិញ ។

នៅឆ្នាំ១៩៧៥ ឡែម, ប៉ៃយ, សុត និង ថង វ៉ាន់ បានរួមគំនិតគ្នាដកទ័ពចេញពីខ្សែត្រៀមនៅសមរភូមិត្រពាំងព្រាយ ដើម្បីឲ្យខ្មាំងផ្តួលកងផ្សេងទៀតនៅបន្ទាយព្រាបម៉ម ។ អង្គការបញ្ជាឲ្យកងរបស់ ឡែម ការពារភ្នំប្រសិទ្ធិ ប៉ុន្តែ ឡែម បែរជានាំទ័ពមកត្រៀមនៅជើងព្រៃទុកផ្លូវឲ្យទាហានចុះមកបន្ទាយត្រពាំងត្នោត ។ ភា ជាសមាជិកកងវរសេនាតូចលេខ២៨៤ ក៏ត្រូវអង្គការទិតៀនអំពីបរាជ័យនៅសមរភូមិត្រពាំងត្នោត ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពបក្សកុម្មុយនិស្តកម្ពុជាបានវាយរំដោះទីក្រុងភ្នំពេញ ។ កម្លាំងរបស់ ឡែម បានចូលដល់ទីក្រុង ហើយនាំគ្នាស៊ីផឹកយ៉ាងសប្បាយ ។ បន្ទាប់ពីនោះ ឡែម និង ថង វ៉ាន់ បានសុំច្បាប់អង្គការទៅលេងផ្ទះ ។ ឡែម ទៅដល់ភូមិប៉ុង ហើយបានសួររក ថង ដាំ, ថង សាម៉ៃ និង ប៊ូ សាំង ប៉ុន្តែទាំង៣នាក់នេះមិននៅក្នុងភូមិទេ នៅសល់តែ ចាន់ ដែងម្នាក់គត់ ។ ចាន់ ដែង រាយការណ៍ថា កម្លាំងមួយចំនួនត្រូវអង្គការចាប់ខ្លួន ហើយមួយចំនួនទៀតបានជម្លៀសប្រជាជនទៅប្រទេសវៀតណាម ។ សព្វថ្ងៃនេះកម្លាំងធំៗអស់ហើយនៅតែកម្លាំងតូចៗប៉ុណ្ណោះដែលកំពុងលាក់ខ្លួននៅក្នុងភូមិឃុំ ។ នៅពេលមកដល់ភ្នំពេញវិញ ឡែម បានរាយការណ៍ប្រាប់ ប៉ៃយ អំពីរឿងរ៉ាវទាំងអស់ដែលខ្លួនភ្ញាប់បាន ។ ប៉ៃយ បានឲ្យយោបល់ថាត្រូវបន្តទាក់ទងនឹងកម្លាំងដែលរត់ទៅប្រទេសវៀតណាមនិងប្រទេសឡាវ ព្រោះខ្សែរយៈរត់ទៅទីនោះអស់ហើយ ។

ឆ្នាំ១៩៧៥-៧៦ អង្គការចាត់តាំងឲ្យកងពលលេខ៨០១ ការពារព្រំដែនខេត្តរតនគិរីនិងខេត្តស្ទឹងត្រែង ។ ប៉ៃយ ឆ្លៀតឱកាសនេះទាក់ទងជាមួយ ប៊ួ ខាវ ជាអតីតលេខាស្រុក៥៥ខ តំបន់ទី៣ ភូមិភាគឦសាន ។ នៅពេលបានលទ្ធផល ប៉ៃយ បានលើកផែនការបង្កទំនាស់នៅតាមមូលដ្ឋានរវាងប្រជាជននិងកងទ័ព ហើយណែនាំកុំឲ្យប្រជាជននៅតាមព្រំដែនវាយទាហានវៀតណាមគឺទុកឱកាសឲ្យវៀតណាមចូលឈ្លានពានក្នុងប្រទេស ។ បន្ទាប់មក ឡែម ចាត់តាំងឲ្យ សួរ នាំប្រជាជនចូលទៅក្នុងទឹកដីវៀតណាម ហើយបណ្តោយឲ្យទ័ពដើរហើរសេរីរហូតមានទ័ពមួយចំនួនរត់ទៅប្រទេសឡាវ ។ ឡែម បានទាក់ទងជាមួយ នូ ដាត់ និង ខាំ ដាន់ នៅភូមិប៉ុងដើម្បីដាក់ផែនការបំផុសប្រជាជនឲ្យស្អប់បដិវត្តន៍ដោយលើកហេតុផលថា បដិវត្តន៍ធ្វើឲ្យមានការព្រាត់ប្រាសរវាងកូនចៅបងប្អូននិងឪពុកម្តាយ ហើយរបបសម្ភពមិនសប្បាយមិនចាយលុយដូចឯកជនទេ ។ ជាលទ្ធផល ប្រជាជនមួយចំនួនមានការទោមនស្សយ៉ាងខ្លាំងនឹងបដិវត្តន៍ ។ ឆ្លៀតឱកាសនោះ ឡែម និងបក្ខពួកកសាងកម្លាំងថ្មីបាន៨នាក់ទៀត ។

ក្រោយមក អង្គការលើកផែនការដកប្រជាជនពីភូមិទៅរស់នៅប្រមូលផ្តុំនៅឃុំស្រែអង្គ្រង ហើយណែនាំឲ្យផ្លាស់មកធ្វើស្រែថ្មីដើម្បីចាត់តាំងសហករណ៍ ។ ឡែម ដែលមិនចង់ឲ្យប្រជាជនផ្លាស់ទៅឃុំស្រែអង្គ្រង ក៏ជំទាស់ថា អង្គការឲ្យប្រជាជនទៅនៅលើទួលគ្មានទឹកគ្មានដំណាំ ស្រែចាស់មិនធ្វើបែរជារានស្រែថ្មី ធ្វើយ៉ាងនេះពិតជាគ្មានបាយហូបទេ ។

នៅឆ្នាំ១៩៧៧ កម្លាំងសម្ងាត់បានឯកភាពគ្នាឈប់ធ្វើសកម្មភាពប្រឆាំង ព្រោះឃើញកម្លាំងដែលប្រឆាំងបដិវត្តន៍និងកម្លាំងដែលចូលមកក្តាប់សភាពការណ៍កងទ័ពត្រូវអង្គការចាប់ខ្លួនបានជាបន្តបន្ទាប់ ។ ឡែម ក៏ឈប់ទាក់ទងខ្សែរយៈនិងបញ្ឈប់សកម្មភាពប្រឆាំងបដិវត្តន៍ ហើយចង់វាកមករស់នៅជាមួយបដិវត្តន៍វិញ ។ នៅខែ២ ឆ្នាំ១៩៧៧ ឡែម ត្រូវអង្គការចាត់តាំងឲ្យមកធ្វើជំនួយការកងពលលេខ៨០១ដល់ខែ៤ អង្គការក៏ដកឲ្យមកធ្វើជាជំនួយការកងពលលេខ៩២០វិញ ។ នៅក្នុងកងពលនេះ ឡែម មិនបានទាក់ទងនឹងខ្សែរយៈណាម្នាក់ទេ រហូតដល់ថ្ងៃទី៨ខែ៦ ឆ្នាំ១៩៧៧ ឡែម ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ និងត្រូវសួរចម្លើយដោយឈ្មោះ ជាកាក់ ។ មិនមែនមានតែ ឡែម ម្នាក់ទេដែលត្រូវចាប់ខ្លួន ។ នៅក្នុងចម្លើយសារភាពរបស់គាត់មានភ្ជាប់ជាមួយនូវបញ្ជីឈ្មោះអ្នកដែលបានចូលរួមធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ជាច្រើនដែលមួយចំនួនមានបញ្ជាក់ខាងចុងថា “ចាប់” ។ យោងតាមបញ្ជីឈ្មោះអ្នកទោសដែលកម្ទេចនៅមន្ទីរស-២១ ឡែម ត្រូវអង្គការកម្ទេចចោលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ ។

**សូ ហ្វារីណា**

*(ឯកសារខ្មែរក្រហម)*

# កិច្ចប្រជុំពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ-កូរ៉េ

ក្រសួងពាណិជ្ជកម្ម

ជម្រាបគណៈកម្មាធិការ៨១

កម្មវត្ថុៈ សេចក្តីរាយការណ៍ជួបមិត្តកូរ៉េ ថ្ងៃទី៦ ខែ១២ ឆ្នាំ១៩៧៦

ខ្លឹមសារៈ

**ខាងកូរ៉េៈ** សួរបញ្ជាក់រោងចក្រស្លដែកនិងវត្ថុធាតុដើមនៃរោងចក្រស៊ូតកូស៊ិក ។ សួរបញ្ជាក់ម៉ាស៊ីនកិនស្រូវ ។ ជូនដំណឹងកប៉ាល់នឹងមកដល់២គ្រឿងនៅពាក់កណ្តាលខែ១២ ឆ្នាំ១៩៧៦ ។ ខាងយើងជម្រាបរឿងដឹកកៅស៊ូនិងអង្ករ ។

**ខាងយើងៈ** សមមិត្ត ឈឿន អុំ ហុង និង សមមិត្ត ហ៊ុន ។

**ខាងកូរ៉េៈ** លេខាទី២និងទី៣

មិត្តកូរ៉េសុំសួរបញ្ជាក់បញ្ហាមួយចំនួនៈ

១) រោងចក្រស្លដែកដែលស្នើទិញ តើប្រើវត្ថុធាតុដើមអ្វី?

២) រោងចក្រធ្វើស៊ូតកូស៊ិច តើប្រើវត្ថុធាតុដើមអ្វី?

៣) ឯម៉ាស៊ីនកិនស្រូវ តើមិត្តកម្ពុជាប្រុងយកយ៉ាងណា?

៤) សូមជម្រាបថា ពាក់កណ្តាលខែ១២នេះមានកប៉ាល់២គ្រឿងដឹកទំនិញមកទៀត ទី១ឈ្មោះ មៀងស៊ីញ និងទី២ឈ្មោះ ភាងហ្វា ។ កប៉ាល់ភាងហ្វាដឹកបាន៨ពាន់តោន ។

៥) សុំមិត្តកម្ពុជាផ្តល់លិខិតរាយល្អិតនៃការផ្តល់ទំនិញទៅកប៉ាល់មៀងស៊ិញនិងរឿងណាផង ។

៦) សុំផ្តល់ជូនគំរូខ្សែភ្លើងនិងគំរូថ្នាំអុកស៊ីតេត្រាស៊ីឃ្លីន ដើម្បីមិត្តកម្ពុជាពិនិត្យ បើត្រូវការយក សូមពត៌មានវិញ ។

**មិត្តយើងៈ**

១) រោងចក្រស្លដែកយើងខ្ញុំប្រើដែកចាស់ជាវត្ថុធាតុដើម ឯថាមពលយើងខ្ញុំទម្លាប់ដុតធ្យូងថ្ម ។ ឯពត៌មានចាំជម្រាបថ្ងៃក្រោយ ។ វត្ថុធាតុដើមធ្វើស៊ូតកូស៊ិច ចាំថ្ងៃក្រោយទើបជម្រាប គំរូថ្នាំពេទ្យនិងគំរូខ្សែភ្លើង ចាំយើងខ្ញុំពិនិត្យសិន ។

២) បញ្ហាម៉ាស៊ីនកិនស្រូវ យើងខ្ញុំចង់បានម៉ាស៊ីនជាប្រព័ន្ធកិនស្រូវរហូតដល់ចេញជាអង្ករ "សម្រិត" តែម្តង ។ ជាមួយគ្នានេះក៏សុំឲ្យមានម៉ាស៊ីនម៉ាស៊ូតជាប់ជាមួយគ្រប់ម៉ាស៊ីនស្រូវទាំងអស់ ។ ម្យ៉ាងទៀតសូមមិត្តកូរ៉េផ្តល់ផែនទី"ប្លង់"មកយើងខ្ញុំ ឯសំណង់អគារ យើងខ្ញុំនឹងសង់ដោយខ្លួនឯង ។

ចាប់ពីខែ១ទៅ បើមិត្តកូរ៉េអាចផ្តល់ឲ្យលើកដំបូង៣-៤គ្រឿងសិន ក៏ជាការងាយស្រួលដល់យើងខ្ញុំដែរ ដើម្បីយើងមានពិសោធន៍សង់អគារនិងត្រៀមលក្ខណៈសម្បត្តិផ្សេងៗ ។

ខាងយើងខ្ញុំមានបញ្ហា២ៈ

១) បញ្ហាដាក់អីវ៉ាន់តាមកប៉ាល់មិត្តកូរ៉េទៅវិញ យើងខ្ញុំចង់ផ្តល់ជូនច្រើនទៅមិត្តកូរ៉េ ប៉ុន្តែយើងខ្ញុំនៅខ្វះខាតមិនទាន់សម្បូរទំនិញ ។ ចំពោះកប៉ាល់លើកនេះ បើកប៉ាល់មិត្តកូរ៉េអាចទទួលដាក់បាន យើងខ្ញុំបានត្រៀមដាក់កៅស៊ូ១ពាន់តោន ។ កៅស៊ូនេះចូលក្នុងចំនួនកៅស៊ូដែលត្រូវផ្តល់ឆ្នាំ១៩៧៧ ។

២) បញ្ហាអង្ករៈ យើងខ្ញុំឆ្នាំនេះទទួលបានផលស្រូវល្អគួរសម ។ យើងខ្ញុំត្រៀមលក់នៅបរទេសមួយចំនួន ។ ជាគោលការណ៍យើងខ្ញុំនឹងលក់ជូនប្រទេសជាមិត្តមុន ។ បើមិត្តកូរ៉េយល់ព្រមទទួលអង្ករកម្ពុជា មិត្តកូរ៉េអាចចាត់ចែងលក់ដូរទៅប្រទេសណាក៏បាន ។ ខាងយើងខ្ញុំមានផែនការផ្តល់អង្ករជូនមិត្តកូរ៉េ៥ម៉ឺនតោនក្នុងឆ្នាំ១៩៧៧ សូមមិត្តកូរ៉េផ្តល់ពត៌មានឲ្យយើងខ្ញុំដឹង តើមិត្តកូរ៉េទាមទារលក្ខណៈសម្បត្តិអ្វីខ្លះ?

**មតិមិត្តកូរ៉េៈ** បញ្ហាដាក់កៅស៊ូនិងអង្ករ ចាំខ្ញុំរាយការណ៍ទៅក្នុងប្រទេសចិនសិនទើបជម្រាបតាមក្រោយ ។

**មតិយើងៈ** ឥឡូវនេះជិតដាច់ឆ្នាំហើយ តាមទម្លាប់តើមិត្តអនុវត្តយ៉ាងណាចំពោះបញ្ជីក្នុងពាណិជ្ជកម្មជាមួយប្រទេសនានា ។

**មតិមិត្តកូរ៉េៈ** តាមទម្លាប់យើងខ្ញុំតែងបញ្ឈប់បញ្ជីដាច់ឆ្នាំ បើជញ្ជីងពាណិជ្ជកម្មធ្ងន់ស្រាលនឹងដឹកបង្គ្រប់ឆ្នាំថ្មី ។

ការជួបសន្ទនាជាមួយមិត្តកូរ៉េចាប់ផ្តើមពីម៉ោង១៥រហូតដល់ម៉ោង១៦គត់ ។ សូមរាយការណ៍ជូនគណៈកម្មាធិការ៨១ ដើម្បីជ្រាបជាពត៌មាន ។

ធ្វើនៅថ្ងៃទី៦ ខែ១២ ឆ្នាំ១៩៧៦, គណៈកម្មាធិការមន្ទីរ

**(ឯកសារ D២២៧១៨)**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៤៩០ | ណយ ស៊ីម (ស្រី) | ប្រពន្ធ តឹក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៨-១២-៧៦ |
| ១៤៩១ | សាំង រេន (ស្រី) | ប្រពន្ធ ប៊ិន | រោងចក្រ ប-៤ | ២០-១០-៧៦ | ២៨-១២-៧៦ |
| ១៤៩២ | អ៊ឹង រ៉ាន់ (ស្រី) | ប្រពន្ធ ប៉ោ សាម៉េត | កំពង់សោម | ២៧-១២-៧៦ | ២៨-១២-៧៦ |
| ១៤៩៣ | អ៊ុក សៀប (ស្រី) | ប្រពន្ធ យឹម ដាំ | កំពង់សោម | ២៧-១២-៧៦ | ២៨-១២-៧៦ |
| ១៤៩៤ | កាំង គឹមលៀន (ស្រី) | ប្រពន្ធ ឆាំ ខន | កំពង់សោម | ២៧-១២-៧៦ | ២៨-១២-៧៦ |
| ១៤៩៥ | យ៉ាប់ យឺន | មេក្រុម១៣ | ២១យ | ៦-១-៧៧ | ១៤-១-៧៧ ឈឺស្លាប់ |
| ១៤៩៦ | សឿន ចាន់ថន | កូន សឿ សុត | ស៊ឹងមានជ័យ | ១២-១-៧៧ | ១៤-១-៧៧ |
| ១៤៩៧ | សឿ ស៊ីថា (ស្រី) | កូន សឿ សុត | ស៊ឹងមានជ័យ | ១២-១-៧៧ | ១៤-១-៧៧ |
| ១៤៩៨ | ហង់ អូន (ស្រី) | ប្រពន្ធ ពាន់ តែម | ស៊ឹងមានជ័យ | ១២-១-៧៧ | ១៤-១-៧៧ |
| ១៤៩៩ | ព្រុំ មិ | ជាងកឺ | តំបន់៣៥ | ២៦-១០-៧៦ | ១៦-១-៧៧ ឈឺស្លាប់ |
| ១៥០០ | តាំង ស្រេង ហៅ សុង សារិន | និស្សិត | ស្រុកបារាំង | ២-១-៧៧ | ១៨-១-៧៧ ឈឺស្លាប់ |
| ១៥០១ | ហួត សុវណ្ណា | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ១៩-១-៧៧ ឈឺស្លាប់ |
| ១៥០២ | ស៊ឹម យ៉េង | មេក្រុមកង១៣ | ស-២១យ | ១៧-១១-៧៦ | ១៩-១-៧៧ |
| ១៥០៣ | ស្រេង ស្រួច | សាលាបច្ចេកទេស | ស-២១យ | ៦-១-៧៧ | ១៩-១-៧៧ |
| ១៥០៤ | ស៊ុយ ហេង | យុទ្ធជនកង១៣ | ស-២១យ | ៦-១-៧៧ | ១៩-១-៧៧ |
| ១៥០៥ | ជា ជឹម | យុទ្ធជនកង១៣ | ស-២១យ | ៦-១-៧៧ | ១៩-១-៧៧ |
| ១៥០៦ | ជា សុកហេង (ស្រី) | យុទ្ធនារីកង១៤ | ស-២១យ | ១៥-១១-៧៦ | ១៩-១-៧៧ |
| ១៥០៧ | សួស រ៉ុម (ស្រី) | យុទ្ធនារីកង១៤ | ស-២១យ | ១៥-១១-៧៦ | ១៩-១-៧៧ |
| ១៥០៨ | ប៉ុច ម៉ាក់បុរី | កម្មករខាងរ៉ែ | សូវៀត | ២៦-១-៧៧ | ២៧-១-៧៧ ឈឺស្លាប់ |
| ១៥០៩ | ញ៉ែម ណេន | ប្រធានក្រឡឹង | រទេះភ្លើង | ១៩-១០-៧៦ | ២៨-១-៧៧ |
| ១៥១០ | ស៊ូ ហាប ហៅ ផល | យុទ្ធជន | កងពល៣១០ | ៣០-១០-៧៦ | ២៨-១-៧៧ |
| ១៥១១ | ជិន សុវត្ថិ ហៅ វង់ | ជាងជួសជុល | មន្ទីរស-៨ | ១៥-១០-៧៦ | ២៨-១-៧៧ |
| ១៥១២ | ហៃ ចំរើន ហៅ ណាន | កងហា | កងពល៣១០ | ៣០-១០-៧៦ | ២៨-១-៧៧ |
| ១៥១៣ | គុយ ឆេងឡាយ | កម្មករ | រទេះភ្លើង | ២១-១១-៧៦ | ២៨-១-៧៧ |
| ១៥១៤ | អ៊ុន ខ្មែរសាន | កម្មករចាស់ | រទេះភ្លើង | ២២-១១-៧៦ | ២៨-១-៧៧ |
| ១៥១៥ | ឈឹម សុជិត | និស្សិត | កាណាដា | ១២-១០-៧៦ | ២៨-១-៧៧ |
| ១៥១៦ | ដួ សុវណ្ណាន | និស្សិត | ស្រុកបារាំង | ១២-១០-៧៦ | ២៨-១-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៥១៧ | ហេង សុងហ៊ី | និស្សិត | ស្រុកបារាំង | ១២-១០-៧៦ | ២៨-១-៧៧ |
| ១៥១៨ | គុប សៀប | ពេទ្យ | ពេទ្យ១៧មេសា | ៧-១០-៧៦ | ២៨-១-៧៧ |
| ១៥១៩ | ថ្រីវ សុខុន ហៅ សៅ សុខុន | យុទ្ធជន | រទេះភ្លើង | ៨-៩-៧៦ | ២៨-១-៧៧ |
| ១៥២០ | ប៉ាល់ គ្រឿន ហៅ វ៉ាន់ | យុទ្ធជន | មន្ទីរពិការ៦២ | ៩-១០-៧៦ | ២៨-១-៧៧ |
| ១៥២១ | លឹម សុក ហៅ ចេក | សេដ្ឋកិច្ច | វរសេនាធំទី៥ | ៨-១១-៧៦ | ២៨-១-៧៧ |
| ១៥២២ | ប៉ែន ពេញ | ពលបាលត្រី | បាត់ដំបង | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១៥២៣ | គីម សុខុំ | កម្មករថ្មី | រទេះភ្លើង | ៩-១២-៧៦ | ២៨-១-៧៧ |
| ១៥២៤ | ឈុន សាប៊ន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២៨-១-៧៧ |
| ១៥២៥ | ហៀវ តុងហាន | កូនសិស្ស | សៀម | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១៥២៦ | ស្រី សុកឈុំ | កម្មករថ្មី | រទេះភ្លើង | ៨-១២-៧៦ | ២៨-១-៧៧ |
| ១៥២៧ | យិន ប៊ុ | ពលទោ | បាត់ដំបង | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១៥២៨ | សេង យ៉ាំ | ចោរព្រៃ | ពេជនិល | ១១-១១-៧៦ | ២៨-១-៧៧ |
| ១៥២៩ | អ៊ុក ស៊ុម | កម្មករចាស់ | រទេះភ្លើង | ២០-១០-៧៦ | ២៨-១-៧៧ |
| ១៥៣០ | សយ វ៉ាត | កម្មករថ្មី | រទេះភ្លើង | ២៧-១០-៧៦ | ២៨-១-៧៧ |
| ១៥៣១ | សឿ សុត | ប្តី យុតជន | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣២ | នូ រឿង | កម្មករចាស់ | រទេះភ្លើង | ២០-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៣ | ម៉ី ឈឿង | ប្តី ស ពៅ | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៤ | យឹម ស៊ុម | ប្តី អ៊ុក ចាន់ថន | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៥ | ឡម ឈុន ហៅ ហ៊ែល | ប្តី ស្រី រុន | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៦ | ឡុច ឈុន ហៅ ហែមដៃ | ប្តី ដាយ៉ាន | អគ្គិសនីទី២ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៧ | ដែក អិន | ប្តី ដាណេ | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៨ | ឈុំ មុនី ហៅ ម៉ុក សាមឿន | ប្តី ហុក សេងហុង | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៣៩ | ដុង ឆន | ប្តី ប្រាក់ សំអុល | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤០ | លីវ គីម | កម្មករថ្មី | រទេះភ្លើង | ២២-១២-៧៦ | ២៨-១-៧៧ |
| ១៥៤១ | រី ថេន | យុទ្ធជន | ថាមពល | ១១-១០-៧៦ | ២៨-១-៧៧ |
| ១៥៤២ | អ៊ុក ផន | ប្តី គីម កន | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤៣ | បួង សារឿន | ប្តី ឡុង វ៉ានី | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤៤ | សៅ ចំរើន ហៅ ប៉ក់ | ប្តី ស៊ុយ តាំងអេង | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤៥ | យី លឹម | កម្មករចាស់ | អគ្គិសនីទី១ | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤៦ | អ៊ុក វុទ្ធី | ប្តី ភៀន វណ្ណា | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |
| ១៥៤៧ | ញ៉ឹក ហេង ហៅ វ៉ុន | ប្តី សាង សំបាត់ | រទេះភ្លើង | ២៨-១០-៧៦ | ២៨-១-៧៧ |

(នៅមានត)

(ឯកសារខ្មែរក្រហម)

# ដំណើរការកសាងកសិកម្មនិងឧស្សាហកម្មរបស់កម្ពុជាប្រជាធិបតេយ្យ

## I. ដំណើរការកសិកម្ម

**សំណូមពរៈ** ទិសដៅតម្រង់មានពីរយ៉ាង÷

១) ដោះស្រាយសេចក្ដីត្រូវការចំពោះមុខឲ្យបានក្នុងកិច្ចផ្គត់ផ្គង់ជីវភាពប្រជាជនឲ្យបានគ្រប់គ្រាន់ ហើយធានាកិច្ចការពារប្រទេសផង ។

២) រៀបចំលក្ខណៈសម្បត្តិទៅថ្ងៃមុខជាបណ្ដើរៗ ច្បាំងដើម្បីជំរុញកសិកម្មឲ្យកាន់តែចម្រើននិងឈានទៅសម័យ ដោយកាន់តែម្ចាស់ការលើបញ្ហាទឹក ខាងម៉ាស៊ីននិងពាក់កណ្ដាលម៉ាស៊ីន ខាងជីនិងថ្នាំកសិកម្មផ្សេងៗ ។ម្យ៉ាងទៀត ដើម្បីបម្រើឧស្សាហកម្ម បម្រើការពង្រីងនិងពង្រីកកសិកម្មតទៅទៀត បម្រើជីវភាពប្រជាជនឲ្យកាន់តែធូរធារនិងសម្បូរសប្បាយ ដើម្បីបម្រើកិច្ចការប្រទេសយើង ។

### ក) ដំណើរការជំហានដំបូង

ជំហានដំបូងពីឆ្នាំ១៩៧៥ - ៨២ ។

ជំរុញផលិតកម្មកសិកម្មដែលមានទាំងអស់ដូចជា÷

◆ ដំណាំខាងស្បៀងមាន ស្រូវ ពោត សណ្ដែក ។ល ។

◆ ដំណាំខាងឧស្សាហកម្មមាន កៅស៊ូ ក្រចៅ កប្បាស ដូង អំពៅ ថ្នាំជក់ ។ល ។

◆ ផលិតកម្មផ្សេងៗទៀតមាន ព្រៃឈើ នេសាទទឹកសាប នេសាទទឹកប្រៃ ចិញ្ចឹមសត្វ និងដាំដំណាំហូបផ្លែផ្សេងៗ ។

### ខ) វិធីដំណើរការ

១) ត្រូវយកចិត្តទុកដាក់ជំរុញកន្លែងដែលមានលទ្ធភាពច្រើនជាងឲ្យបានជាអតិបរមា ទន្ទឹមនឹងនេះក៏ខិតខំកន្លែងផ្សេងទៀតដែរ ។

២) ចាត់ចែងផលិតកម្មដោយយកចិត្តទុកដាក់ កម្លាំងប្រជាជនចាស់សំខាន់បំផុត ពិសេសគឺកម្លាំងសហករណ៍ ចាត់ចែងកម្លាំងពលកម្មរបស់សហករណ៍នេះឲ្យមានប្រសិទ្ធភាព ។

៣) ជំរុញសំណង់ទឹកគ្រប់ប្រភេទឲ្យបានជាអតិបរមាដើម្បីម្ចាស់ការលើបញ្ហាទឹកឲ្យកាន់តែខ្ពស់ឡើង ។

៤) ប្រើម៉ាស៊ីននិងពាក់កណ្ដាលម៉ាស៊ីនខ្លះតាមទុននិងតាមលទ្ធភាពនៃជំហានដំបូងរបស់យើង ។

៥) ត្រូវគិតគូរប្រើប្រាស់ជីនិងថ្នាំកសិកម្មជាបណ្ដើរៗ ដើម្បីថែរក្សាការពារដំណាំដាំដុះឲ្យបានល្អ តាមលំដាប់ដំណើរការរបស់យើង ។

### គ) មាគ៌ាដំណើរការ

១) ត្រូវយកចិត្តទុកដាក់អំពីតួនាទីដឹកនាំរបស់បក្សខាងកសិកម្ម ។

២) ត្រូវយកចិត្តទុកដាក់ឃោសនាបំផុសចលនាមហាជនឲ្យឆាប់ ហើយចាត់តាំងកម្លាំងមហាជនឲ្យមានលក្ខណៈវិទ្យាសាស្ត្រនិងមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងន័យនេះត្រូវយកចិត្តទុកដាក់ចាត់ចែងកម្លាំង ហើយប្រមូលផ្ដុំតាមកន្លែងសំខាន់ៗ ។ ទន្ទឹមនឹងនេះ ក៏ត្រូវគិតគូរកន្លែងផ្សេងទៀតដែរ ។ ត្រូវបំផុសចលនាប្រឡងប្រណាំងក្នុងមហាជន ដើម្បីធ្វើជាគំរូក្នុងចលនាបង្កបង្កើនផលបដិវត្តន៍ ។ គំរូតាមទិសសមូហភាពដើម្បីបម្រើការកសាងប្រទេស បម្រើជីវភាពប្រជាជន បម្រើកិច្ចការពារប្រទេស មិនមែនប្រឡងប្រណាំងដើម្បីលុយទេ ។ ម្យ៉ាងទៀតកន្លែងដែលមានសមត្ថភាពបង្កបង្កើនផលបានល្អហើយនៅទំនេររហោឋាន ពិសេសតាមព្រំដែនត្រូវចាត់ចែងប្រជាជន យុវជន-យុវនារីមួយចំនួនទៅបោះទីតាំងដើម្បីទៅបង្កបង្កើនផលនិងការពារប្រជាជន ។

៣) ពង្រឹងនិងពង្រីកសហករណ៍ភាវូបនីយកម្មតទៅទៀតជាអង្គភាពមូលដ្ឋានរបស់ប្រជាជន ដើម្បីកសាងកសិកម្មបដិវត្តន៍របស់បក្ស ដើម្បីកសាងមូលដ្ឋានជនបទថ្មី និងដើម្បីកសាងជីវភាពកសិករថ្មី សមូហភាពភ្ញាក់រឭកខ្ពស់ខាងនយោបាយ សតិអារម្មណ៍និងចាត់តាំងហើយមានសមត្ថភាពបច្ចេកទេសកាន់តែខ្ពស់ ។

៤) ត្រូវយកចិត្តទុកដាក់លើកកម្ពស់ ការសន្សំសំចៃគ្រប់មុខទាំងអស់របស់រដ្ឋ សហករណ៍ និងគ្រួសារ គឺសន្សំសំចៃដើម្បីបដិវត្តន៍ ដើម្បីកសាងប្រទេស ការពារប្រទេស និងលើកតម្កើងជីវភាពប្រជាជន ។ ពាក្យស្លោកសន្សំសំចៃគឺ "ត្រូវសន្សំសំចៃ

តាំងពីស្រូវមួយក្បួរ វល្លិ៍មួយកន្ទុយទៅដើម្បីបដិវត្តន៍” ស្មារតីនេះត្រូវគ្របដណ្ដប់តាំងពីកុមារ យុវជន-យុវនារី រហូតដល់ចាស់ទុំ ។

៥) ដំណើរការកសិកម្មត្រូវចាត់ចែងតាមផែនការទាំងអស់ ជាផែនការរបស់រដ្ឋទូទាំងប្រទេស ជាផែនការភូមិភាគ ជាផែនការតំបន់ ជាផែនការមូលដ្ឋានផ្សេងៗ និងសហករណ៍ ។

៦) ក្នុងបញ្ហាកសិកម្មត្រូវគិតគូរជាបណ្ដើរៗ បញ្ហាបច្ចេក-ទេសនិងវិទ្យាសាស្ត្រឲ្យកាន់តែចម្រើនជាលំដាប់ ដើម្បីឲ្យកសិកម្មរបស់យើងឈានទៅជាកសិកម្មសម័យគឺបញ្ហាទឹក បញ្ហាគ្រឿងម៉ាស៊ីន បញ្ហាជី និងថ្នាំកសិកម្ម បញ្ហាអគ្គិសនី និងបញ្ហាពិសោធន៍វិទ្យាសាស្ត្រផ្សេងៗ ។

ជាមូលដ្ឋានយើងផ្អែកលើពិសោធន៍របស់មហាជនយើងដោយធ្វើសន្និបាត ទស្សនកិច្ចទៅវិញទៅមក ។

៨) ការប្រើប្រាស់ដីធ្លីដើម្បីបង្កបង្កើនផល ត្រូវគិតគូរទិសពីរយ៉ាងគឺ÷ ទី១ ដីដែលមានហើយពិសេសដីល្អត្រូវប្រើប្រាស់វាឲ្យបានជាអតិបរមាគឺដាំមិនឈប់ ហើយត្រូវលើកគុណភាពដីនេះឲ្យជាប់ដោយបញ្ហាទឹក បញ្ហាជី បញ្ហាដាំតាមរបៀបវិទ្យាសាស្ត្រ គឺដាំអស់ដីតិចប៉ុន្តែបានផលច្រើន ។ ទី២ ទន្ទឹមនឹងនេះក៏ត្រូវពង្រីកដីថ្មីដែលល្អថែមទៀតឲ្យកាន់តែច្រើនឡើង កុំពង្រីកដីមិនល្អ ។

៩) បក្សនិងរដ្ឋបដិវត្តន៍ត្រូវយកចិត្តទុកដាក់ជួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់ការកសាង កសិកម្មបដិវត្ត នៅជនបទថ្មីរបស់យើងគឺជួយខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង បច្ចេកទេស វិទ្យាសាស្ត្រ ទុន និងមធ្យោបាយ ។ល។ ត្រូវជួយជាពិសេសដល់អង្គការសហករណ៍និងអង្គការរដ្ឋដែលកសាងកសិកម្មថ្មីនៅជនបទ ។

១០) ត្រូវយកចិត្តទុកដាក់កសាងកម្មាភិបាលគ្រប់ប្រភេទខាងផ្នែកកសិកម្មនៅជនបទ ទាំងកម្មាភិបាលនយោបាយ ទាំងកម្មាភិបាលបច្ចេកទេស ។

ប៉ុន្តែទាំងអស់នេះត្រូវជាប់ចលនានិងបម្រើចលនាកសិកម្ម ។ ឧទាហរណ៍ៈ រើសសមាសភាពល្អក្នុងសហករណ៍ខ្លះមកអប់រំខាងមាគ៌ាសហករណ៍ ខាងមាគ៌ាកសិកម្ម ហើយឲ្យគេទៅផ្សព្វផ្សាយក្នុងសហករណ៍ជាកិច្ចការនយោបាយរបស់យើងគ្រប់គ្រងចលនានិងដឹកនាំចលនា ។

កិច្ចការបច្ចេកទេសក៏ត្រូវចេញពីចលនានេះដែរ ជ្រើសរើសយុវជន-យុវនារីដែលចូលចិត្តខាងហ្នឹងឲ្យគិតគូរ ហើយឲ្យទៅមើលកន្លែងពិសោធន៍ដទៃ ។

## II. ដំណើរការកសាងឧស្សាហកម្ម

***សំណូមពរៈ*** ជាទិសតម្រង់មាន២គឺៈ

១) ដោះស្រាយសេចក្ដីត្រូវការចាំបាច់ចំពោះមុខឲ្យបាន ។

២) រៀបចំលក្ខណៈសម្បត្តិបណ្ដើរៗ ដើម្បីបោះទីតាំងឧស្សាហ-កម្មឲ្យបានឆាប់រហ័ស ឈានទៅកែប្រែប្រទេសកសិកម្មអន់ថយឲ្យទៅជាប្រទេសកសិកម្មឧស្សាហកម្ម ហើយឈានពីនោះឲ្យទៅជាប្រទេសឧស្សាហកម្មកសិកម្មសម័យ ។


សកម្មភាពនៅក្នុងរោងចក្រតម្បាញ

### ក) ដំណើរការជាជំហានៗ

**ជំហានដំបូងៈ**

◆ តាមសំណូមពរបម្រើការចាំបាច់ចំពោះមុខ បញ្ហាធំគឺស្តារនិង

ជួសជុលរោងចក្រផ្សេងៗ ជាចាំបាច់ដែលបានខូចខាតក្នុងសង្គ្រាម ។ ទន្ទឹមនឹងនេះក៏ត្រូវខិតខំបន្ថែមថ្មីខ្លះតាមលទ្ធភាពជាជំហានដំបូងរបស់យើង ។

◆ យកចិត្តទុកដាក់ស្តារនិងជួសជុលរោងចក្រតូច- ធំ ដូចជា រោងចក្រតម្បាញ សំបកបារី ស៊ីម៉ងត៍ កន់ឡានគ្រប់ធុន កន់ជិះ និងគ្រប់សម្ភាររបស់វា ។ល ។ ព្រមទាំងរៀបចំរោងចក្រឬរោងជាងជួសជុលគ្រឿងម៉ាស៊ីន កប៉ាល់ រោងចក្រធ្វើថ្នាំពេទ្យ និងបរិក្ខារពេទ្យ ។ល ។

◆ ឯថែមថ្មីដែលចាំបាច់ ដូចជារោងចក្រផលិតឧបករណ៍ផលិតកម្មផ្សេងៗ បម្រើកសិកម្ម និងជីវភាពប្រជាជនសំខាន់ៗ ដូចជា រណារ ញញួរ ដែកទ្រនាប់ ពន្លាក ដែកខួង ដែកឈូស ចប ។ល ។ ម្យ៉ាងទៀត ត្រូវមានរោងចក្រឬរោងជាងធ្វើរបស់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនដូចជា÷ ចាន ឆ្នាំង ស្ពាបព្រា ដែកកេះ ថ្មដែកកេះ ថ្មពិល របស់របរសិក្សានិងមន្ទីរខ្លះដូចជា សៀវភៅ ដងប៉ាកកា ខ្មៅដៃ ទឹកខ្មៅ ។ល ។ ព្រមជាមួយនោះក៏ត្រូវគិតគូររោងចក្រឬរោងជាងធ្វើមធ្យោបាយដឹកជញ្ជូនដូចជាៈ កង់ រទេះរុញ រទេះសេះ រ៉ឺម៉ក កាណូត កប៉ាល់សម្រាប់ទន្លេធំ និងកប៉ាល់សម្រាប់សមុទ្រ (ពី៥០ទៅ១០០០តោនជាដើម) ក្រៅពីនេះក៏ត្រូវគិតគូរអំពីឧស្សាហកម្មខាងសំណង់ជាបណ្តើរៗ ដូចជា ក្បឿង ឥដ្ឋ បេតុង ។ល ។

### ១) មាគ៌ាដំណើរការមួយចំនួន

◆ ត្រូវយកចិត្តទុកដាក់បញ្ហាបក្សដឹកនាំខាងឧស្សាហកម្មតាមមាគ៌ាឧស្សាហកម្មរបស់បក្ស ។ ដូច្នេះបក្សត្រូវគិតគូរកសាងខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង ក្នុងកម្មករថ្មីរបស់បក្ស និងក្នុងភារកិច្ចថ្មីរបស់បក្សឲ្យមានជំហររឹងប៉ឹង ។ ក្នុងនេះត្រូវយកចិត្តទុកដាក់ គោលជំហរធ្វើម្ចាស់លើឧស្សាហកម្ម លើរោងចក្រ លើវត្ថុធាតុដើម លើកម្លាំងពលកម្ម លើផលិតកម្មឧស្សាហកម្ម ។ល ។

ម្យ៉ាងទៀត ត្រូវដឹកនាំឲ្យជាប់ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ដោយដាក់បច្ចេកទេសក្រោមមាគ៌ារបស់បក្ស ។ ទន្ទឹមនេះ ត្រូវបំពាក់ជំហរខ្លួនឧបត្ថម្ភខ្លួន សន្សំសំចៃ កម្រិតខ្ពស់ ។

◆ ត្រូវក្តាប់និងអនុវត្តពាក្យស្លោក "ចំណាយទុនតិចល្មម តែគុណភាពការងារនិងគុណភាពផលិតផលខ្ពស់" ។

◆ ត្រូវរៀបចំចាត់ចែងកម្លាំងពលកម្ម ខាងឧស្សាហកម្មឲ្យសមស្រប ។

◆ លំដាប់ដំណើរការកសាងឧស្សាហកម្មរបស់យើង ដំបូងត្រូវស្តារឧស្សាហកម្មចាស់ដែលមានធ្វើជាទុនដើម្បីដោះដូរជាមួយខាងប្រទេសក្រៅខ្លះ ដើម្បីបំពេញសំណូមពររបស់យើងជាដំបូង ដែលចាំបាច់ត្រូវស្តារឧស្សាហកម្មចាស់និងរៀបចំឧស្សាហកម្មថ្មីខ្លះ ។ ម្យ៉ាងទៀត ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលធ្វើខ្លួនឯងរហូតដល់មួយរយៈកាល យើងធ្វើខ្លួនឯងបានជាមូលដ្ឋានរហូតដល់ធ្វើបានទាំងស្រុង ។

◆ ត្រូវគិតគូរដំណើរការឧស្សាហកម្មតាមរបៀបផែនការ កុំធ្វើរាយប៉ាយតាមនឹកឃើញ ។ ត្រូវធ្វើតាមទិសនិងសំណូមពរច្បាស់លាស់ ។ ឧទាហរណ៍ៈ ទុនសម្រាប់ឧស្សាហកម្ម១០០ ចែកទៅជាឧស្សាហកម្មបម្រើកសិកម្ម៦០ ឧស្សាហកម្មបម្រើជីវភាពប្រជាជន២០ ឧស្សាហកម្មបម្រើកិច្ចការពារប្រទេស ២០ ។

◆ ត្រូវគិតគូរបញ្ហាបច្ចេកទេសនិងវិទ្យាសាស្ត្រឲ្យកាន់តែរីកចម្រើនល្អលាស់ជាលំដាប់ ។ ក្នុងកិច្ចដំណើរការឧស្សាហកម្មរបស់យើង ដោយម្យ៉ាងយកបច្ចេកទេស តម្រិះវិជ្ជា ការច្នៃប្រឌិតរបស់មហាជន ប្រជាជនយើងមកបម្រើនិងជំរុញផលិត-កម្មឧស្សាហកម្ម ។ ត្រូវគិតគូរបច្ចេកទេសនិងវិទ្យាសាស្ត្រសម័យតាមពិសោធន៍និងចលនារបស់ខ្លួនយើង និងពិសោធន៍សកលលោកដែលសមស្របនឹងចលនារបស់យើង ។

◆ បញ្ហាកសិកម្ម ទន្ទឹមនឹងការពង្រឹងពង្រីកឧស្សាហកម្មគ្រប់ផ្នែក ត្រូវយកចិត្តទុកដាក់បំផុត សិប្បកម្មគ្រប់ផ្នែកដែរ ហើយត្រូវធ្វើតាម២បែបគឺ ទី១ តាមលក្ខណៈមហាជន និងទី២ តាមអគ្គការរដ្ឋ ។ ក៏ប៉ុន្តែសំខាន់ត្រូវយកសិប្បកម្មរបស់មហាជនជាមូលដ្ឋាន ។

ទីតាំងឧស្សាហកម្មរបស់យើងមិនប្រមូលផ្តុំធំទេ គឺពង្រាយៗ ជាទីក្រុងឧស្សាហកម្មតូចៗពាសពេញផ្ទៃប្រទេស ។

**(ឯកសារ D២១៩១០)**

# យុទ្ធនារីផលិតអំបិល


ចាន់ ណេង

ចាន់ ណេង ចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីឆ្នាំ១៩៧២ ។ មុនដំបូង ណេង ធ្វើជាគ្រូបង្រៀនកុមារនៅភូមិអន្ត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ។ បន្ទាប់មក ណេង ធ្វើជាកម្មករស្រែអំបិលរហូតដល់ឆ្នាំ១៩៧៦ ណេង ក៏ផ្លាស់មកធ្វើជាអ្នកដឹកជញ្ជូនស្បៀងឲ្យកម្មករវិញ ។ នៅអំឡុងពេលនោះ ណេង មានការតក់ស្លុតជាខ្លាំងនៅពេលដែលដឹងថា អ្នកនៅធ្វើការជាមួយខ្លួននិងកម្មករស្រែអំបិលមួយចំនួនបាត់ខ្លួន ។ នៅឆ្នាំ១៩៧៩ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ណេង បានវិលត្រឡប់មកស្រុកកំណើតវិញ ។

នៅឆ្នាំ១៩៧២ ភូមិអន្ត្រាវត្រូវខ្មែរក្រហមកាន់កាប់ទាំងស្រុង ។ ប្រធានភូមិឈ្មោះ ប៉ោ បានចុចឈ្មោះ ណេង ឲ្យធ្វើជាគ្រូបង្រៀនក្នុងភូមិ ។ សាលារៀនគឺនៅក្រោមផ្ទះរបស់ប្រជាជន ព្រោះសាលារៀនពិតប្រាកដត្រូវយន្តហោះទម្លាក់គ្រាប់បែកបាក់បែកខ្ទេចខ្ទីអស់ទៅហើយ ។ គ្រូប្រើប្រាស់សម្ភារបង្រៀនដែលសេសសល់ពីរបបមុន ។ ក្រៅពីការរៀនសូត្រ គ្រូត្រូវនាំកុមារចូលរួមលើកទំនប់ជីកប្រឡាយ ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានឃោសនាអូសទាញយុវជនឲ្យចូលបម្រើបដិវត្តន៍ ។ គណៈឃុំបានទិតៀននារីៗនៅក្នុងភូមិជារឿយៗថា បានទាក់ទងស្នេហាជាមួយយុវជនធ្វើឲ្យយុវជនមិនអាចចេញទៅបម្រើជាតិបាន ។ ណេង បានសម្រេចចិត្តចូលបម្រើការងារនៅសមរភូមិមុខជាមួយនារីជាច្រើននាក់ទៀតក្នុងភូមិហើយធ្វើការនៅអង្គភាពស្រែអំបិល ។ ការងាររបស់គាត់គឺរែកអំបិល ។ គាត់តែងតែផ្លាស់ប្តូរកន្លែងធ្វើការជាញឹកញាប់គឺចេញពីកែបទៅតាពីង បានតែមួយថ្ងៃក៏ផ្លាស់មកនៅកំពង់នង់ហៅកំពង់កណ្តាល ។ គ្រប់កន្លែងដែល ណេង ធ្វើការគឺផលិតអំបិល ។ នៅឆ្នាំ១៩៧៥ ណេង មកធ្វើការនៅអង្គភាពស្រែអំបិលត្រើយកោះដែលមាន ជឿន ជាប្រធាន ។ រយៈពេល៥ខែដំបូង ណេង មិនបានទទួលទានទឹកសាបទាល់តែសោះគឺហូបតែទឹកប្រៃហើយភ្ជាវ ។ ការទាក់ទងគ្នារវាងស្ត្រីនៅស្រែអំបិលនិងបុរសនៅតាមក្រសួងមន្ទីរនានាត្រូវកាត់ផ្តាច់ ។ ប្រសិនបើបុរសណាម្នាក់ពេញចិត្តនារីនៅក្នុងក្រុមផលិតអំបិល បុរសនោះត្រូវតែស្នើមក ជឿន ដើម្បីសុំរៀបការ ។

ប្រហែលឆ្នាំ១៩៧៥របបអាហារត្រូវបានកំណត់ឲ្យហូប៣ពេល ។ ណេង បានហូបឆ្អែត ប៉ុន្តែទន្ទឹមនឹងនេះជើងរបស់គាត់ក៏របកស្បែកដំបៅឡើងសុសព្រោះទឹកអំបិលស៊ី ។ នៅឆ្នាំ១៩៧៦ ណេង ត្រូវអង្គការផ្លាស់មកធ្វើជាអ្នកដឹកស្បៀងឲ្យកម្មករវិញ ។ អង្ករ ត្រី និងគ្រឿងទេសផ្សេងៗ ដឹកចេញពីទីក្រុងភ្នំពេញតាមរថភ្លើងមកកាន់ខេត្តកំពត បន្ទាប់មក ណេង ទទួលដឹកជញ្ជូនស្បៀងទាំងនោះតាមឡាននិងកាណូតយកទៅឲ្យការដ្ឋាននីមួយៗ ។ នៅក្នុងអង្គភាពរបស់ ណេង មានបាត់មនុស្សជាញឹកញាប់ ។ អ្នកដែលបាត់ខ្លួនច្រើនតែអ្នកដែលខ្មែរក្រហមចោទថាក្បត់បដិវត្តន៍និងជាសមាសភាពមិនល្អ ។ ណេង បានបញ្ជាក់ថា អ្នកដែលខ្មែរក្រហមចាប់ខ្លួនត្រូវបានបញ្ជូនចេញពីស្រែអំបិល ហើយសម្លាប់ចោល ។ ស្ត្រីម្នាក់ដែលធ្វើការនៅក្នុងអង្គភាព ស្រែអំបិលជាមួយ ណេង ត្រូវអង្គការចាប់យកទៅសម្លាប់ បន្សល់ទុកក្មួយប្រុសម្នាក់អាយុ៧ឆ្នាំដែលមានរបួសជាដំណំ ដោយសារលោកភ្លើងដែលឈ្លបខ្មែរក្រហមដុតរោល ។ ណេង បានយកក្មេងនោះមកចិញ្ចឹមទុកដូចជាកូន ។

ក្រោយមក ណេង បានស្គាល់នារី ឡុង ម៉ាមេរិទ្ធ ហៅ មាន ជាប្រធានវរសេនាតូចប្រចាំនៅអង្គភាពស្រែអំបិល ។ មាន ជាមនុស្សរាក់ទាក់ស្លូតបូតហើយស្រឡាញ់ប្រជាជន ។ មាន ជិតស្និទ្ធនិងទុកចិត្ត ណេង ខ្លាំងណាស់រហូតហ៊ានប្រគល់ការងារឲ្យ ណេង ទទួលខុសត្រូវជំនួសខ្លួនទៀតផង ។ នៅពេលធ្វើប្រវត្តិរូប ណេង

បានលាក់មិនឲ្យនរណាដឹងថាគាត់បានរៀនសូត្រឡើយ ព្រោះបារម្ភក្រែងមានគ្រោះថ្នាក់ដល់ខ្លួន ។

អំឡុងឆ្នាំ១៩៧៧-៧៨ មាន ត្រូវអង្គការស្នើឲ្យទៅសម្រាលកូននៅមន្ទីរពេទ្យព្រះកេតុមាលា ព្រោះគាត់មានផ្ទៃពោះជិតគ្រប់ខែ ប៉ុន្តែនេះគ្រាន់តែជាលេសមួយប៉ុណ្ណោះ ការពិត មាន ត្រូវអង្គការចោទប្រកាន់ថាក្បត់បដិវត្តន៍ ជាភ្នាក់ងារសេ.អ៊ី.អា ហើយត្រូវចាប់ខ្លួន ។ បន្ទាប់ពី មាន ត្រូវអង្គការចាប់ខ្លួន ណេង មានការភ័យខ្លាចក្រែងអង្គការចាប់គាត់ដែរ ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀត-ណាមវាយសម្រុកខ្លាំង ណេង បានរត់ចេញពីស្រែអំបិលទៅកាន់ព្រំដែនកម្ពុជា-ថៃ ហើយបានជួបឪពុកម្តាយរបស់គាត់នៅទីនោះ ។ ក្រុមគ្រួសាររបស់គាត់ក៏នាំគ្នាត្រឡប់មកស្រុកកំណើតវិញ ។ ឪពុកម្តាយរបស់ ណេង បានស្លាប់ក្រោយឆ្នាំ១៩៧៩ ។

សព្វថ្ងៃនេះ ណេង មានអាយុ៤៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ ។ ណេង មានអាហារហូបចុកបរិបូណ៌ និងមានសេរីភាពគ្រប់គ្រាន់ ប៉ុន្តែគាត់មិនអាចបំភ្លេចរបបខ្មែរក្រហមដែលបង្ខំឲ្យគាត់ធ្វើការយ៉ាងលំបាក រហូតធ្វើឲ្យជើងរបស់គាត់ដំបៅស្អុយសាច់ស្ទើររលួយ ថែមទាំងទទួលរងនូវការនិន្ទាឈ្នានីស ការគំរាមកំហែងយកទៅសម្លាប់ចោលគ្មានលស់ថ្ងៃ ។ គាត់ចង់រស់នៅឲ្យក្នុងសង្គមមួយដែលពោរពេញដោយសន្តិភាពហើយចង់ឲ្យមានការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមផង ព្រោះវានឹងអាចជួយរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ ។

**សូ ហ្សារីណា**

# វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# យុទ្ធជនធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ យុវជន-យុវនារីមួយចំនួនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ រីឯមួយចំនួនទៀតដែលមិនស្ម័គ្រចិត្ត ក៏ត្រូវរដ្ឋអំណាចមូលដ្ឋានចាប់បង្ខំឲ្យចូលរួមដែរ ។

ឡុង តុង ហៅ ឡុង តាង មានស្រុកកំណើតនៅភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ តុង ចូលបម្រើបដិវត្តន៍នៅក្នុងឆ្នាំ១៩៧២ តាមរយៈឈ្មោះ វ៉ាន់ ដែលជាយោធាក្នុងកងទ័ពរំដោះ ។ ពេលនោះ តុង ទើបតែមានអាយុ១៦ឆ្នាំប៉ុណ្ណោះ ឪពុកម្ដាយរបស់ តុង មិនពេញចិត្តឲ្យកូនទៅទេ ដោយយល់ថាកូនរបស់គាត់នៅតូចពេក ប៉ុន្តែគាត់មិនហ៊ានប្រកែកប្រឆាំងនឹងទិសដៅរបស់អង្គការឡើយ ។ តុង ស្ថិតនៅក្នុងអង្គភាពកងឯករាជ្យកាំភ្លើងធំលេខ៥០២ ដែលដឹកនាំដោយមេបញ្ជាការមកពីភាគខាងជើងវៀតណាមឈ្មោះ ពៅ ។ ដោយសារមេបញ្ជាការឃើញថា តុង នៅក្មេងពេកក៏ចាត់តាំងឲ្យ តុង ជួយដាំបាយនិងឃ្វាលសេះរបស់អង្គភាពនៅសមរភូមិក្រោយ ។ នៅខែមករា ឆ្នាំ១៩៧៣ តុង ត្រូវបានអង្គភាពបញ្ជូនឲ្យទៅសិក្សាវិជ្ជាពេទ្យនៅសេនាធិការប្រចាំភូមិភាគ៣០៤ ខេត្តសៀមរាបអស់រយៈពេល១ឆ្នាំ (ចន្លោះឆ្នាំ១៩៧៣-៧៤) ។ មុខវិជ្ជាដែល តុង បានរៀនគឺព្យាបាលជំងឺទូទៅ ព្យាបាលរបួស និងវិធីសង្គ្រោះបន្ទាន់ ។ ការសិក្សាផ្នែកទ្រឹស្តីធ្វើឡើងនៅពេលយប់ ហើយពេលថ្ងៃអនុវត្តជាក់ស្តែង គឺលាងរបួស រុំរបួស និងដេរមុខរបួសឲ្យកងទ័ពដែលបញ្ជូនមកពីសមរភូមិមុខ ។ សិក្ខាកាមដែលចូលរួមរៀនវិជ្ជាពេទ្យកាលពីជំនាន់នោះមានស្រីមានប្រុសចំនួនប្រហែល៣០នាក់ដែលមានអាយុត្រឹមតែ១៦ឬ១៧ឆ្នាំប៉ុណ្ណោះ ។


ឡុង តុង

បន្ទាប់ពីរៀនចប់នៅក្នុងឆ្នាំ១៩៧៤ តុង មកប្រចាំការនៅអង្គភាពពេទ្យសេនាធិការភូមិភាគ៣០៤ប្រចាំនៅខេត្តសៀមរាប ។ ក្រោយមកអង្គភាពរបស់ តុង បានផ្ទេរមកប្រចាំការនៅភ្នំសន្ទុក ក្នុងខេត្តកំពង់ធំ ។ តុង បានបម្រើការងារផ្នែកព្យាបាលរបួស ហើយដើរតាមកងទ័ពរហូតចាប់តាំងពីពេលនោះមក ។ នៅពេលអង្គការបើកយុទ្ធនាការវាយរំដោះយកទីក្រុងភ្នំពេញ អង្គភាពរបស់ តុង បានទទួលមុខព្រួញវាយចូលតាមប្រែកព្រែកក្ដាម ។ ពេលដណ្ដើមបានទីក្រុងភ្នំពេញ ពោលគឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្ដើមជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង ។ ចំណែកទាហានលន់ណុលមួយចំនួនដែលធ្លាប់យល់ដឹងពីអំពើឃោរឃៅផ្ដាច់ការរបស់បក្សកុម្មុយនិស្តកម្ពុជា បានព្យាយាមលាក់ប្រវត្តិរូបរបស់ខ្លួនដោយដើរបន្លំជាមួយហ្វូងប្រជាជនចេញពីទីក្រុងភ្នំពេញទាំងមិនដឹងគោលដៅពិតប្រាកដ ។ នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញអស់ហើយ អង្គភាពរបស់ តុង បានទទួលបញ្ជាឲ្យបោះទីតាំងនៅម្តុំវត្តភ្នំ ។ នៅទីនោះ តុង និងយុទ្ធជនទាំងអស់ហាត់ក្បួនយោធានៅពេលព្រឹក ពេលថ្ងៃបន្តិចបោសសំរាមនៅក្នុងទីក្រុងភ្នំពេញ ហើយនៅពេលយប់មានភារកិច្ចយាមកាមការពារទីក្រុងតាមមុខសញ្ញាដែលថ្នាក់លើបានកំណត់ ។ ពេលយាមកាម យុទ្ធជនទាំងអស់ត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់ ពីព្រោះនៅមានសេសសល់អតីតទាហានលន់ណុលមួយចំនួនតូចដែលបង្កប់ខ្លួនក្នុងទីក្រុង ចេញមកធ្វើសកម្មភាពបង្កឲ្យមានភាពចលាចលដោយគប់គ្រាប់បែកទៅលើផ្ទះថ្មជាញឹកញយ ។ ទាហានលន់ណុលទាំងនោះត្រូវទ័ពខ្មែរក្រហមចាប់ខ្លួនបានជាបន្តបន្ទាប់ ។ បន្ទាប់ពីចាប់ខ្លួនបានហើយមិនដឹងអង្គការបញ្ជូនទៅទីណាទេ ។

តុង អះអាងថា គាត់បានចូលរួមសន្និបាតនៅស្តាតអូឡាំពិកម្តង ។ តុង បានប្រាប់ឲ្យដឹងថា នៅពេលនោះមានការយាមកាម

និងផែកដេរយ៉ាងតឹងរ៉ឹងនិងហ្មត់ចត់ជាទីបំផុត ។ ខ្លឹមសារនៃអង្គសន្និបាតគឺគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ការដឹកប្រព័ន្ធប្រឡាយដើម្បីអភិវឌ្ឍន៍ប្រទេសជាតិនិងការស្រាវជ្រាវរកចាប់ក្អាក់ងារបង្កប់របស់ខ្មាំង ។ តុង បាននិយាយថា "អ្នកមានឋានៈធំៗដែលទៅចូលរួមក្នុងសន្និបាតនាពេលនោះមាន ប៉ុល ពត និង សុន សេន ។ កាលនោះ សុន សេន មានឋានៈជាអគ្គបញ្ជាការកងទ័ព ។ សុន សេន ធ្លាប់ចុះមកសាកសួរសុខទុក្ខយុទ្ធជនតាមអង្គភាពម្តងម្កាលដែរ ។ ពេលមកម្តងៗ មានអង្គរក្សហែហមឆ្វេងស្តាំមកជាមួយ ហើយមិនដែលនៅយូរទេ" ។ បន្ទាប់ពីនៅវត្តភ្នំរយៈពេល៣ខែ តុង បានឡើងឋានៈជាប្រធានកងអនុសេនាតូច និងក្តាប់យុទ្ធជនចំនួន៣០នាក់ ហើយបានផ្លាស់ចេញពីពេទ្យមកធ្វើស្រែនៅប្រាំងចំរេះរហូតដល់ចុងឆ្នាំ១៩៧៦ ។

នៅឆ្នាំ១៩៧៧ អង្គការបានផ្លាស់អង្គភាពរបស់ តុង ឲ្យមកធ្វើស្រែនិងដឹកប្រឡាយនៅបឹងបាយ៉ាប អន្លង់ក្ងាន អង្គក្រពើ និងកប់ស្រូវ ។ ការហូបចុករបស់កងទ័ពនៅពេលនោះគឺហូបបបររាវៗ ពេលខ្លះបានហូបបាយដែរ ប៉ុន្តែមិនឲ្យហូបតាមចិត្តចង់ទេ គឺត្រូវវាល់ចែកគ្នា ។ បន្លែដែលយកមកស្លគ្មានអ្វីក្រៅពីព្រលិត និងត្រកួនដែលបេះមកពីបឹងបាយ៉ាបឡើយ ។ តុង និយាយទាំងអស់សំណើចថា មុនដំបូងបេះផ្កាព្រលិតយកមកស្លហូប ដល់ពេលហូបអស់ផ្កា ចាប់ផ្តើមបេះដើមហូបម្តង ។ ព្រលិតនិងត្រកួនលូតលាស់មិនទាន់អ្នកបេះហូបទេ ។ ការហូបព្រលិតនិងត្រកួនយូរៗទៅបណ្តាលឲ្យយុទ្ធជនមានធ្មេញខ្មៅគ្រប់គ្នា ព្រោះជ័រកាន់ ។

នៅឆ្នាំ១៩៧៧ សភាពការណ៍ច្របូកច្របល់បានកើតមាន ។ ប្រធានកងពលនិងមេៗភូមិភាគ៣០៤ ត្រូវអង្គការចាប់យកទៅសម្លាប់ចោលគ្មានសល់ដូចជា កុយ ធួន, អឿន, ឈិន, សួង, រ៉ន និង សុខ ជាដើម ដោយចោទថា ក្បត់បដិវត្តន៍ ខ្សែសេ.អ៊ី.អា ហើយបានបញ្ជូនកម្មាភិបាលភូមិភាគនិរតីឈ្មោះ ញ៉ី និង សន ឲ្យមកដឹកនាំកងពលជំនួសអ្នកដឹកនាំចាស់វិញ ។ ចំណែកឈ្មោះ ពៅ ដែលជាមេបញ្ជាការរបស់ តុង ត្រូវថ្នាក់លើចោទថាជាខ្សែ "កាហ្សេបេ" ហើយត្រូវអង្គការហៅឲ្យទៅនៅទីក្រុងភ្នំពេញ រួចចាប់ខ្លួន ។ អង្គការបានយកកាសែតថតសំឡេងរបស់ អឿន មកចាក់ឲ្យកងទ័ពនៅក្នុងអង្គភាពស្តាប់ ។ ក្នុងកាសែតនោះ អឿន បានសារភាពថា ខ្លួនគាត់ពិតជាក្បត់នឹងអង្គការបដិវត្តន៍មែន ។ យុទ្ធជនទាំងអស់មានទឹកមុខស្រងូតស្រងាត់ ព្រួយបារម្ភពីសុខទុក្ខរបស់ អឿន គ្រប់ៗគ្នា ប៉ុន្តែម្នាក់ៗមិនហ៊ានសម្តែងអាការៈឲ្យអ្នកដទៃដឹងទេ ព្រោះខ្លាចក្រែងអង្គការយកទោសពៃរ៍ចាប់យកទៅកម្ទេចចោលទៀត ។ បន្ទាប់ពីចាប់មេដឹកនាំកងពលអស់ហើយ អង្គការក៏ចាប់ផ្តើមចាប់ថ្នាក់ក្រោមបន្ទាប់ៗទៀត ដូចជាវរសេនាធំ វរសេនាតូច អនុសេនាធំ អនុសេនាតូច តាមការសារភាពរបស់អ្នកទោសមុនៗដែលឆ្លើយដាក់ ។ តុង បាននិយាយថា "ខ្ញុំមានសំណាងល្អណាស់ដែលគេមិនឆ្លើយដាក់ខ្ញុំ" ។ ក្រោយពេលចាប់មេធំៗអស់ អង្គការចេញបញ្ជាឲ្យយុទ្ធជនទាំងអស់ធ្វើប្រវត្តិរូបជាញឹកញាប់ ។ នៅឆ្នាំ១៩៧៨ អង្គការបានដាក់ផែនការជ្រើសរើសយុទ្ធជនមួយចំនួនដែលមានសមាសភាពនិងវណ្ណៈភាពល្អយកទៅធ្វើសង្គ្រាមជាមួយកងទ័ពវៀតណាម ។ យុទ្ធជនដែលមានជាប់ពាក់ព័ន្ធនិន្នាការនយោបាយមិនសូវល្អដូចជា តុង ជាដើមមិនត្រូវបានជ្រើសរើសយកទៅប្រយុទ្ធនៅព្រំដែនទេ ប៉ុន្តែអង្គការបានបញ្ជូនឲ្យទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំងវិញ ។ ការងារនៅព្រលានយន្តហោះលំបាកជាងនៅបឹងបាយ៉ាបពីរដង ។ យុទ្ធជនទាំងអស់ត្រូវកាប់គាស់គល់ឈើដូចជាដើមស្វាយដើមត្នោត និងគាស់យកឫសឈើចេញដើម្បីចាក់ដីបង្ហាប់ធ្វើផ្លូវ ។ ការងារនេះត្រូវធ្វើយ៉ាងសម្រិតសម្រាំងនិងយកចិត្តទុកដាក់ជាទីបំផុត ។ តុង ជាអ្នកបញ្ជាត្រាក់ទ័រចូកដីដាក់ពង្រាយសម្រាប់ធ្វើផ្លូវយន្តហោះរត់ ។ ប្រធានទទួលមើលការខុសត្រូវរួមក្នុងការធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនោះមានឈ្មោះ តាលៃ, តាឌួក និង តាម៉េត (ស៊ូ ម៉េត) ។ កាលនោះមានអ្នកជំនាញការចិនធ្វើជាទីប្រឹក្សាផ្នែកបច្ចេកទេស និងមានអ្នកបកប្រែភាសាខ្មែរ-ចិនម្នាក់ដែលជាអ្នកស្រុកមកពីខេត្តកំពត ។ ពេលធ្វើការងារ ចិន និងខ្មែរធ្វើការជាមួយគ្នា ប៉ុន្តែដល់ពេលហូបចុកវិញ ក្រុមខាងជនជាតិចិនហូបផ្សេង ឯក្រុមខ្មែរហូបផ្សេងមិនឲ្យហូបឡុកឡំគ្នាទេ ។ កន្លែងស្នាក់នៅរបស់ជនជាតិចិនក៏មានលក្ខណៈសមរម្យជាងកម្មករខ្មែរ ។ អង្គការយកចិត្តទុកដាក់ចំពោះជនជាតិចិនណាស់គឺឲ្យហូបចុកសេរី ដោយឡែកកម្មករខ្មែរ អង្គការមិនសូវ

ផ្គត់ផ្គង់ឲ្យបានគ្រប់គ្រាន់ប៉ុន្មានឡើយ ។ ក្រោយមក ដោយសារខ្វះខាតបុគ្គលិកពេទ្យ ថ្នាក់លើបានដក តុង ឲ្យមកធ្វើពេទ្យ ។ តុង បម្រើការងារខាងពេទ្យនេះបានប្រហែល៣-៤ខែ ក៏ត្រូវបានអង្គការដកឲ្យទៅដាំឪឡឹកវិញ ។ នៅដើមឆ្នាំ១៩៧៩ពេលដែលកងទ័ពវៀតណាមវាយបណ្តេញខ្មែរក្រហមចេញពីទីក្រុងភ្នំពេញ ជនជាតិចិនដែលធ្វើការនៅព្រលានយន្តហោះត្រូវបានអង្គការបញ្ជូនទៅខេត្តបាត់ដំបងអស់ ។ ចំណែក តុង មិនបានដឹងអំពីស្ថានការណ៍យ៉ាងម៉េចៗទេ ព្រោះគាត់នៅខេត្តកំពង់ឆ្នាំងកំពុងតែដើរសុំអាចម៍គោពីប្រជាជនមកធ្វើជីទុកសម្រាប់ដាក់ចម្ការឪឡឹក ។ តុង បានឃើញឡានតូច-ធំបើកតាមផ្លូវជាតិលេខ៥ ជាហូរហែ ដែលដឹកយុទ្ធជននិងកម្មាភិបាលមកពីទីក្រុងភ្នំពេញ ។ តុង បានចូលអង្គភាពវិញនៅម៉ោងប្រហែល៨យប់ ។ ពេលនោះមេបញ្ជាការបានកោះប្រជុំយុទ្ធជនទាំងអស់ឲ្យរៀបចំអីវ៉ាន់ជាបន្ទាន់ ។ យុទ្ធជនណាដែលថ្នាក់លើទុកចិត្តត្រូវបានបំពាក់អាវុធឲ្យរួចជាស្រេចដើម្បីធ្វើដំណើរចាកចេញពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ឆ្ពោះទៅអមលាំង (ខេត្តកំពង់ស្ពឺ) និងភ្នំឱរ៉ាល់ ។

តុង បានរស់នៅជាមួយខ្មែរក្រហមរហូតដល់ឆ្នាំ១៩៨៥ ទើបរត់ចូលជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ។ មូលហេតុដែលបណ្តាលឲ្យ តុង បោះបង់ចោលការតស៊ូជាមួយខ្មែរក្រហមគឺដោយសារតែខ្មែរក្រហមនៅប្រើគោលនយោបាយចាស់ដដែលៗ ដូចជា ខោអាវស្មៀកពាក់ ការប្រជុំការងារធំតូច នៅមានលក្ខណៈចាស់គំរិលឥតមានផ្លាស់ប្តូរអ្វីសោះ ម្យ៉ាងទៀត តុង មានការធុញទ្រាន់នឹងការធ្វើសង្គ្រាមកាប់សម្លាប់តែខ្មែរគ្នាឯងណាស់ ។ ដោយមានចិត្តចង់កសាងគ្រួសារមួយនិងរស់នៅដោយស្ងប់ស្ងាត់ផងនោះ តុង បានសម្រេចចិត្តផ្តាច់ខ្លួនចេញពីក្រុមខ្មែរក្រហម ។ តុង បានរៀបការក្នុងឆ្នាំ១៩៨៥ ជាមួយ ចាន់ ឃាន់ ដែលសព្វថ្ងៃមានអាយុ៤៦ឆ្នាំ និងមានកូនស្រី១នាក់ កូនប្រុស២នាក់ ។ សព្វថ្ងៃ តុង មានអាយុ៤៧ឆ្នាំ រស់នៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ប្រកបរបរធ្វើស្រែចម្ការ ។

**ឆេង ម៉េង**

ជនាញការចិននិងយុទ្ធជនខ្មែរក្រហម



# មិនព្រមរៀបការជាមួយយុទ្ធជនពិការ


ជិន សារី

នៅក្នុងរបបខ្មែរក្រហម ប្រជាជនគ្រប់រូបមិនថាប្រុស ស្រី ចាស់ក្មេង ត្រូវតែធ្វើការងារធ្ងន់ធ្ងរក្នុងរយៈពេលជាច្រើនម៉ោងក្នុងមួយថ្ងៃៗ ។ សូម្បីតែកុមារដែលកំពុងសិក្សាត្រឹមថ្នាក់បឋមសិក្សា ក៏ត្រូវបង្ខំឲ្យធ្វើការងារដែរ ដើម្បីបង្ហាញឲ្យឃើញអំពីសមត្ថភាពរបស់ខ្លួនក្នុងការចូលរួមចំណែកកសាងប្រទេស ។ អង្គការបានបង្ខំឲ្យកុមារធ្វើការធ្ងន់ៗដូចមនុស្សចាស់ ដូចជារែកដី លើកទំនប់ ជីកប្រឡាយ លើកផ្លូវលំ ជញ្ជូនសំណាប និងការងារផ្សេងៗទៀត ។

ជិន សារី មានដំណើរជីវិតមិនខុសពីកុមារដទៃទៀតនៅក្នុងរបបខ្មែរក្រហមឡើយ ។ មុនពេលចូលបម្រើបដិវត្តន៍ សារី បានរស់នៅយ៉ាងសុខសាន្តជាមួយក្រុមគ្រួសាររបស់នាងដែលមានឪពុកម្ដាយនិងបងប្អូន៧នាក់ នៅក្នុងភូមិតាឡង់ ឃុំបានៀវ ស្រុកឈូក ខេត្តកំពត ។ សារី បានចូលរៀននៅសាលាបឋមសិក្សាជាមួយនឹងកុមារដទៃទៀតនៅក្នុងភូមិ ។ នៅឆ្នាំ១៩៧០ ភូមិតាឡង់ត្រូវខ្មែរក្រហមចូលលុកលុយនិងកាន់កាប់ ។ នៅឆ្នាំ១៩៧៤ សារី មានអាយុ១៣ឆ្នាំ រៀននៅថ្នាក់ទី១០ (ថ្នាក់ទី៣បច្ចុប្បន្ន) ។ ថ្ងៃមួយប្រធានឃុំបានៀវឈ្មោះ អូក បានចាត់តាំង សារី ឲ្យទៅធ្វើការនៅក្នុងកងចល័តស្រុក ។ កុមារដទៃៗទៀតដែលមានអាយុស្របាលៗគ្នាក៏ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅក្នុងកងចល័តធ្វើការនៅវត្តស៊ីងក្នុងភូមិសត្វពង ឃុំសត្វពង ស្រុកឈូក ដែលស្ថិតនៅឆ្ងាយពីផ្ទះ និងបែកពីក្រុមគ្រួសារ ។

ការងាររបស់កងចល័តនៅពេលនោះគឺជីកប្រឡាយ លើកទំនប់ ។ រៀងរាល់ថ្ងៃ សារី ត្រូវងើបតាំងពីម៉ោង៥ព្រឹកដើម្បីទៅធ្វើការឲ្យទាន់ម៉ោង៦ ហើយឈប់សម្រាកហូបបាយនៅម៉ោង១១ និងចាប់ផ្ដើមធ្វើការវិញនៅម៉ោង១ថ្ងៃត្រង់រហូតដល់ម៉ោង៥ល្ងាច ។ នៅពេលយប់ កុមារត្រូវចែកវេនគ្នាយាមការពារជំរំស្នាក់នៅ ។ របបអាហារដែល សារី ទទួលគឺពីរពេលក្នុងមួយថ្ងៃ ហើយមួយពេលៗទទួលបានបបររាវៗចំនួនបីវែក ។ កុមារនៅក្នុងកងចល័តមានរូបរាងកាយស្គមស្លេកស្លាំងអស់កម្លាំងល្ហិតល្ហៃ និងខ្សព្រាហ៍មានជំងឺតម្កាត់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏កុមារទាំងអស់នៅតែខិតខំប្រឹងប្រែងធ្វើការ ដោយសារភ័យខ្លាចការសម្លុត ការគំរាមកំហែង ការដាក់ទោសគ្មានអាណិតអាសូរ ឬការចាប់ខ្លួនយកទៅបាត់ៗដោយចោទប្រកាន់ថាជាមនុស្សខ្ជិលច្រអូសស្អីកស្រពន់មិនសកម្មនឹងការងារ ។ ដោយហត់ហេវខ្លាំងពេកកុមារខ្លះដួលសន្លប់ឬស្លាប់នៅក្នុងការដ្ឋានក៏មាន ។

នៅក្នុងភូមិឯណោះ ឪពុកម្ដាយនិងបងប្អូនរបស់ សារី ក៏ត្រូវអង្គការបញ្ជូនទៅធ្វើការឆ្ងាយៗ និងហូបចុកមិនគ្រប់គ្រាន់ដែរ ។ មនុស្សទាំងអស់ធ្វើការប្រៀបបីដូចជាគ្រឿងម៉ាស៊ីន គឺដឹងតែពីធ្វើការជាច្រើនម៉ោងក្នុងមួយថ្ងៃៗ ដោយគ្មានការតវ៉ា គ្មានការបញ្ចេញយោបល់អ្វីទាំងអស់ ។ អ្នកទាំងនេះបាត់បង់អស់នូវទំនាក់ទំនងរវាងគ្នានឹងគ្នា និងត្រូវកាត់ផ្ដាច់មនោសញ្ចេតនារវាងឪពុកម្ដាយ កូន បងប្អូន ឬមិត្តភក្ដិ ។ ទោះបីជាអង្គការដាក់វិន័យតឹងរ៉ឹងយ៉ាងណាក៏ដោយ ក៏មិនអាចកាត់ផ្ដាច់មនោសញ្ចេតនារវាងកុមារនិងក្រុមគ្រួសារបានដែរ ។ យូរៗម្ដង សារី បានទទួលការអនុញ្ញាតពីប្រធានកងឲ្យមកលេងផ្ទះបានមួយថ្ងៃ ហើយត្រូវត្រឡប់ទៅវិញនៅពេលល្ងាច ពីព្រោះ សារី អត់មានរបបអាហារនៅក្នុងភូមិទេ ។ ជួនកាលដោយសារការនឹករឭកឪពុកម្ដាយពេក សារី លួចរត់មក ផ្ទះនៅពេលម៉ោងសម្រាក ។ ពេលមកដល់ភូមិ សារី បានជួប មុខឪពុកម្ដាយនិងបងប្អូនតែមួយភ្លែតប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៦ សារី ត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅកោះស្លា ដោយសារនាងមានប្រវត្តិរូបល្អ ជាអ្នកពេញសិទ្ធិ ហើយសកម្មនឹងការងារ ។ នៅក្នុងរបបខ្មែរក្រហម អ្នកមានប្រវត្តិរូបល្អគឺប្រជាជនពេញសិទ្ធិដែលមិនជាប់ទាក់ទងនឹងនិន្នាការរបបចាស់ ហើយស្ថិតនៅក្នុងវណ្ណៈកសិករក្រីក្រ មានបងប្អូនចូលបម្រើបដិវត្តន៍តាំងពីមុន និងជាមនុស្សដែលមានចំណេះដឹងទាប ។ កោះស្លាគឺជាការដ្ឋានលើកទំនប់ដែលមានទំហំធំជាងការដ្ឋាននៅវត្តស៊ឹងទៅទៀត ។ នៅទីនោះមានយុវជនយុវនារីជាច្រើនត្រូវបានអង្គការបញ្ជូនទៅពីស្រុកផ្សេងៗគ្នាក្នុងខេត្តកំពតដើម្បីឲ្យមកលើកទំនប់ ។ បុរសនិងស្ត្រីនៅដាច់ដោយឡែកពីគ្នា ។

នៅកោះស្លា សារី ត្រូវធ្វើការងារធ្ងន់ធ្ងរជាងមុន ដោយត្រូវធ្វើការបន្ថែមនៅពេលយប់ពីម៉ោង៧ដល់ម៉ោង៩ ហើយការហូបចុក វិន័យ និងការដាក់ទោស ក៏មានលក្ខណៈតឹងតែងជាងមុនដែរ ។ ដោយសារការស្រេកឃ្លាន អ្នកខ្លះបានលួចរបស់សម្ភារៈ... ភាពដើម្បីហូប ហើយពេលដែលឈ្លបខ្មែរក្រហមឬប្រធានកងចាប់បានអ្នកទាំងនោះត្រូវទទួលទោសដោយការធ្វើទារុណកម្ម ឬយកទៅដាក់គុក ឬក៏បញ្ជូនទៅបាត់តែម្តង ។ អ្នកខ្លះបេះស្លឹកឈើ ឬចាប់សត្វល្អិតបរិភោគ រហូតដល់កើតជំងឺផ្សេងៗ ។ សារី និយាយថា «នៅទីនោះប្រសិនបើយើងឈឺទៅធ្វើការមិនកើត ពេទ្យនឹងចាក់ទឹកចូលក្នុងខ្លួនយើងឲ្យស្លាប់តែម្តង ដូចពាក្យស្លោកខ្មែរក្រហមថា ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។ មនុស្សជាច្រើនបានស្លាប់ដោយសារតែធ្វើការបាក់កម្លាំង គ្មានអាហារហូបគ្រប់គ្រាន់ និងដោយសារជំងឺគ្រុនចាញ់និងជំងឺផ្សេងៗទៀត ។ រហូតមកដល់សព្វថ្ងៃនេះ សារី នៅតែមានចម្ងល់ថា ហេតុអ្វីបានជាខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការកាន់តែធ្ងន់ ប៉ុន្តែចែកអាហារឲ្យកាន់តែតិចទៅវិញ ។ សារី បន្តថា «យើងខំធ្វើការងារទាំងអស់គ្នា ឪពុកម្តាយខ្ញុំខិតខំធ្វើស្រែ តែពួកគាត់ក៏ហូបមិនឆ្អែតដូចខ្ញុំដែរ ។ យើងខិតខំធ្វើការដោយសារតែការបង្ខិតបង្ខំប៉ុណ្ណោះ» ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ អង្គការបានបញ្ជូន សារី និងយុវនារីមួយចំនួនទៀតដែលត្រូវបានចម្រាញ់ថាជាអ្នកមានប្រវត្តិរូបល្អឲ្យមកធ្វើការនៅទីក្រុងភ្នំពេញ ។ ពេលមកដល់ទីក្រុងភ្នំពេញ យុវនារីទាំងអស់ត្រូវគេបែងចែកឲ្យទៅធ្វើការនៅតាមផ្នែកផ្សេងៗគ្នា ។ សារី ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅផ្នែកថែទាំអ្នករបួសនៅមន្ទីរពេទ្យ៦មករា (សព្វថ្ងៃហៅពេទ្យព្រះកេតុមាលា) ទាំង សារី មិនដែលចេះវិជ្ជាពេទ្យសូម្បីតែបន្តិចសោះពីមុនមក ។ សារី បានចាប់ផ្តើមអនុវត្តការងាររបស់ខ្លួនភ្លាមបន្ទាប់ពីប្រធានពេទ្យបង្ហាញអំពីរបៀបលាងរបួស របៀបថែអ្នករបួស និងរបៀបចាក់ថ្នាំតែពីរដងប៉ុណ្ណោះ ។ ក្នុងមួយសប្តាហ៍មានពេទ្យជាជនជាតិចិនមកបង្រៀនបច្ចេកទេសពេទ្យម្តង ។ សារី មិនធ្លាប់មានទោសរហូតដល់ថ្នាក់ទទួលទារុណកម្មធ្ងន់ធ្ងរ ឬក៏ចាប់បញ្ជូនទៅមន្ទីរឃុំឃាំងទេ ប៉ុន្តែបរិយាកាសការងារដែលសារី បានជួបប្រទះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការរស់នៅរបស់អ្នកទោសក្នុងមន្ទីរឃុំឃាំងដែរ ។ ប្រធានអង្គភាពបានហៅ សារី ទៅអប់រំម្តង ដោយសារតែ សារី បានធ្វើឲ្យបែកសឺរ៉ាំងចាក់ថ្នាំមួយដែលមានន័យស្មើនឹងធ្វើឲ្យខូចខាតរបស់រួមមួយដែរ ។ ជួនកាល សារី ត្រូវអ្នករបួសជេរ ឬធាក់ដួលនៅពេលដែលនាងកំពុងលាងរបួសឲ្យ ។ ជាញឹកញាប់ ប្រធានពេទ្យតែងតែប្រជុំណែនាំប្រាប់បុគ្គលិកពេទ្យទាំងអស់ឲ្យខិតខំអត់ធ្មត់ធ្វើការងារ កុំឆេវឆាវ កុំឲ្យទំនាស់ជាមួយអ្នកជំងឺ ។ ចាប់តាំងពីអង្គការបញ្ជូនទៅធ្វើការនៅកោះស្លារហូតមកដល់ភ្នំពេញ សារី មិនដែលបានទៅលេងផ្ទះឬក៏ដើរទៅណាក្រៅពីកន្លែងដែលខ្លួនធ្វើការឡើយ ។ សារី និយាយថា «នៅក្នុងមន្ទីរពេទ្យ៦មករានេះមានអគារប្រហែល១០ខ្នង តែខ្ញុំមិនអាចដើរទៅអគារណាផ្សេងក្រៅពីអគារដែលខ្ញុំធ្វើការឡើយ ហើយក៏មិនដែលឃើញអ្នកធ្វើការនៅអគារផ្សេងដែរ ។ កាលនៅកងចល័ត យ៉ាងហោចណាស់ខ្ញុំអាចសុំច្បាប់ទៅលេងផ្ទះបានមួយថ្ងៃ ឬលួចទៅលេងផ្ទះបានមួយភ្លែតៗដែរ ក៏ប៉ុន្តែតាំងពីពេលខ្ញុំមកធ្វើការនៅភ្នំពេញ ខ្ញុំមិនដែលបានទៅលេងផ្ទះហើយក៏មិនដែលបានទទួលដំណឹងពីអ្នកផ្ទះម្តងណាសោះ» ។

ក្រៅពីទ្រាំទ្រនឹងការងារហើយ នារីពេទ្យត្រូវទទួលរងនូវការបង្ខំឲ្យរៀបការជាមួយនឹងកងទ័ពពិការថែមទៀត ។ សារី បាននិយាយថា «នៅពេលនោះកងទ័ពពិការមានសិទ្ធិស្នើនារីពេទ្យ

រៀបការបាន ព្រោះជនពិការទាំងនោះបានលះបង់ខ្លួនក្នុងការធ្វើសង្គ្រាមដើម្បីការពារប្រទេស ហើយពេលនេះត្រូវពិការទៅសមរភូមិលែងកើត ដូច្នេះគេត្រូវការពេទ្យថែរក្សា» ។ នារីពេទ្យដែលមានរូបរាងស្អាតត្រូវបង្ខំឲ្យរៀបការជាមួយកងទ័ពពិការ ។ បើនរណាម្នាក់ហ៊ានប្រកែកច្បាស់ជាត្រូវអង្គការចាប់យកទៅសម្លាប់ចោលមិនខាន ។ នារីពេទ្យខ្លះសុខចិត្តសម្លាប់ខ្លួនឯង ។ សារី បានប្រាប់ពីការតាំងចិត្តរបស់ខ្លួនថា «ខ្ញុំសុខចិត្តស្លាប់មិនព្រមរៀបការជាមួយជនពិការដាច់ខាត ។ ក៏ប៉ុន្តែពេលនោះសំណាងល្អដែលខ្ញុំនៅក្មេងនៅឡើយ អង្គការមិនបង្ខំឲ្យខ្ញុំរៀបការទេ» ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយលុកចូលដល់ទីក្រុងភ្នំពេញ សារី រួមជាមួយបុគ្គលិកពេទ្យនិងអ្នកជំងឺជាច្រើននាក់ទៀត បានរត់ចេញពីមន្ទីរពេទ្យ ហើយធ្វើដំណើរតាមរថភ្លើងឆ្ពោះទៅខេត្តបាត់ដំបង បន្ទាប់មកក៏បន្តដំណើរដោយថ្មើរជើងរហូតដល់ប្រទេសថៃ ។ សារី បន្តរស់នៅក្នុងជំរំជនភៀសខ្លួនតាមព្រំដែនកម្ពុជា-ថៃ ហើយបានរៀបការជាមួយបុរសម្នាក់ឈ្មោះ យ៉ន យ៉ុង នៅឆ្នាំ១៩៨០ ។ នៅឆ្នាំ១៩៩៣ ប្តីប្រពន្ធ សារី បានធ្វើមាតុភូមិនិវត្តន៍មករស់នៅជួបជុំឪពុកម្តាយបងប្អូននៅស្រុកកំណើតវិញ ។

សព្វថ្ងៃនេះ សារី រស់នៅជួបជុំក្រុមគ្រួសារប្រកបមុខរបរធ្វើស្រែចម្ការនិងលក់ដូរបន្តិចបន្តួចទៅតាមលទ្ធភាពរបស់ខ្លួន ។ សារី មានកូនពីរនាក់ ។ គាត់បាននិយាយថា «ខ្ញុំតែងតែនិយាយរឿងនេះប្រាប់កូនៗខ្ញុំឲ្យបានដឹងជារឿយៗ ។ វានៅក្មេងខ្ញុំមិនចង់ឲ្យវាធំឡើងមានវាសនាដូចជាខ្ញុំកាលពីពេលនោះទេ ។ របបខ្មែរក្រហមធ្វើឲ្យខ្ញុំរស់នៅក្នុងភាពភ័យខ្លាច ជួបនូវការលំបាកវេទនាទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ស្អែតស្អន់ហើយ ខ្ញុំមិនចង់ឲ្យរបបហ្នឹងកើតឡើងម្តងទៀតចំពោះកូន ចៅខ្ញុំជំនាន់ក្រោយៗទេ» ។

តាមរយៈការចុះស្រាវជ្រាវរបស់បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងខេត្តកំពត យើងបានរកឃើញប្រជាជននៅទីនោះជាច្រើននាក់ទៀតដែលធ្លាប់ជួបប្រទះរឿងរ៉ាវប្រហាក់ប្រហែលនឹងដំណើររឿងរបស់ សារី ដែរ ។

**អឿ រតនា**

## សេចក្តីជូនដំណឹងស្តីអំពីការបើកឱ្យប្រើប្រាស់ «ការិយាល័យពត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលយើងនឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅហើយ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហមយុត្តិធម៌ និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទដទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១) ផ្តល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២) ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្តីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **អៀ ម៉េងទ្រី** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# យុទ្ធនារីបើកឡានដឹកដី


ជឹម រ៉េត

ជឹម រ៉េត មានស្រុកកំណើតនៅក្នុងភូមិព្រៃកតាប្រាក់ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល ។ ជឹម រ៉េត និងក្រុមគ្រួសារបានត្រឡប់មករស់នៅក្នុងភូមិកំណើតវិញក្នុងពេលមានការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនខ្មែរនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលរៀបចំឡើងដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរួមជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ។ រ៉េត បានរៀបការជាមួយប្តីរបស់គាត់ឈ្មោះ វណ្ណា នៅឆ្នាំ១៩៨៣ ពេលរស់នៅជំរំជនភៀសខ្លួនសាយអេច និងមានកូនស្រី២នាក់ ប្រុស២នាក់ ។ សព្វថ្ងៃ វណ្ណា ប្រកបមុខរបរជាគ្រូពេទ្យប្រចាំភូមិ ។

ស្រុកស្អាងជាស្រុកមួយនៅក្នុងខេត្តកណ្តាលស្ថិតនៅតាមបណ្តោយដងទន្លេបាសាក់ ។ នៅអំឡុងឆ្នាំ១៩៧៤ ស្រុកស្អាងបានធ្លាក់ក្រោមការកាន់កាប់របស់ចលនារំដោះជាតិ (ទ័ពខ្មែរក្រហម) ។ បើពិនិត្យតាមភូមិសាស្ត្រនិងរឿងរ៉ាវដែលប្រជាជននៅក្នុងស្រុកស្អាងបាននិយាយប្រាប់ ស្រុកស្អាងគឺជាសមរភូមិជួរមុខរបស់ចលនារំដោះជាតិខ្មែរក្រហម ហើយក៏ជាកន្លែងដែលទទួលរងការវាយបកវិញយ៉ាងខ្លាំងរបស់កងទ័ពលន់ណុលតាមរយៈការបាញ់ផ្លោងនិងទម្លាក់គ្រាប់បែក ។ ប្រជាជនមួយចំនួនបានភៀសខ្លួនទៅតំបន់ដែលកាន់កាប់ដោយកងទ័ពរំដោះ និងខ្លះទៀតរត់មកទីក្រុងភ្នំពេញដែលស្ថិតក្រោមការគ្រប់គ្រងរបស់លន់ណុល ដើម្បីគេចឲ្យផុតពីការវាយប្រហារគ្នា ។

រ៉េត រៀននៅសាលាបឋមសិក្សាវត្តតាលន់បានតែពីរបីឆ្នាំប៉ុណ្ណោះក៏បោះបង់ការសិក្សា ព្រោះសាលាត្រូវបិទទ្វារដោយសារតែការទម្លាក់គ្រាប់បែកខ្លាំងពេក ។ យោងតាមប្រវត្តិរូប របស់ រ៉េត ដែលធ្វើនៅឆ្នាំ១៩៧៧បញ្ជាក់ថា រ៉េត បានចូលបដិវត្តន៍នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៥នៅក្នុងមន្ទីរ២១ តំបន់២៥ តាមរយៈ ហួត សេ ជាប្រធានមន្ទីរ២១ ដោយមូលហេតុឈឺចាប់ចំពោះខ្មាំងនិងដើម្បីរំដោះជាតិរំដោះខ្លួនឲ្យរួចផុតពីអំពើទាំងនោះ ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រ៉េត រួមទាំងមិត្តរួមភូមិពីរបីនាក់ទៀតដូចជាឈ្មោះ នៅ, ផល និង វ៉ាន ត្រូវអង្គការបញ្ជូនពីភូមិតាមកប៉ាល់មកស្នាក់នៅឃុំព្រែកអំបិលក្នុងស្រុកស្អាងខេត្តកណ្តាល រយៈពេល៥ថ្ងៃ ។ បន្ទាប់មកទើបអង្គការបញ្ជូនមកទីក្រុងភ្នំពេញដើម្បីឲ្យមករុះរើផ្ទះនៅម្តុំផ្លូវត្រសក់ផ្អែមយកទៅកសាងការដ្ឋាននៅវត្តអង្គរជ័យនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រហែលមួយខែក្រោយមក រ៉េត ត្រូវបានអង្គការផ្លាស់ឲ្យទៅធ្វើផ្ទះឲ្យយុទ្ធជនយុទ្ធនារី នៅក្នុងវត្តអង្គរជ័យក្នុងស្រុកកៀនស្វាយ ។ បន្ទាប់ពីសាងសង់ផ្ទះសម្រាប់ស្នាក់នៅរួចហើយ អង្គការបានដក រ៉េត ឲ្យទៅលើកភ្លឺធ្វើស្រែដូចយុទ្ធជនយុទ្ធនារីដទៃទៀតដែរ ។ នៅក្នុងអង្គភាពវត្តអង្គរជ័យបានជាងមួយឆ្នាំ ហួត សេ ដែលជាប្រធានគ្រប់គ្រងនៅទីនោះ ត្រូវអង្គការចាប់ខ្លួនដោយចោទថាជាប់ខ្សែរយៈក្បត់ ។ ចំណែក រ៉េត ក៏ត្រូវអង្គការបញ្ជូនមកនៅទឹកថ្លាក្រុងភ្នំពេញក្នុងអង្គភាពការដ្ឋានទី២ ក្រោមការដឹកនាំរបស់ សម សារ៉ាត ដែលចំណុះឲ្យក្រសួងកសិកម្ម ។ ពេលនោះ រ៉េត រួមជាមួយយុទ្ធនារី៩នាក់ទៀតត្រូវបានអង្គការបង្គាប់ឲ្យរៀនបើកឡាន ។ កាលនោះនៅក្នុងទីក្រុងភ្នំពេញគ្មានប្រជាជនសាមញ្ញរស់នៅទេ គឺមានតែកម្មករ ទាហាន បុគ្គលិកពេទ្យ និងបុគ្គលិកនៅតាមមន្ទីរក្រសួងនានាប៉ុណ្ណោះ ។

ជារៀងរាល់ព្រឹក រ៉េត រួមជាមួយមិត្តភក្តិបានរៀនបើកឡាន និងរៀនជុសជុលគ្រឿងម៉ាស៊ីនក្រោមការបង្ហាត់បង្រៀនរបស់បុរស

ចំណាស់ម្នាក់ដែលជាប្រជាជន១៧មេសា ។ ហាត់រៀនបានប្រហែលជាមួយខែ រ៉េត និងមិត្តភក្តិរួមក្រុមបានបើកឡានដឹកដីពីក្រៅទីក្រុងភ្នំពេញត្រង់ម្តុំទឹកថ្លាយកទៅចាក់បំពេញនៅបឹងបាយ៉ាប ដើម្បីសាងសង់រោងចក្រមួយ ។ រ៉េត បានដឹងថា គម្រោងសាងសង់រោងចក្រនោះគឺស្ថិតក្រោមជំនួយឧបត្ថម្ភពីប្រទេសកូរ៉េ ហើយគាត់បានឃើញអ្នកបច្ចេកទេសជាជនជាតិកូរ៉េមកធ្វើការនៅទីនោះ ។ នៅក្នុងការដ្ឋានសាងសង់រោងចក្រ រ៉េត បានជួបជាមួយមិត្តភក្តិជាច្រើនមកពីភូមិកំណើតជាមួយគ្នា ។ ក្រៅពីការងារបើកឡានដឹកដីនៅពេលថ្ងៃរួចហើយ នៅពេលយប់ចាប់ពីម៉ោង៦ ទៅដល់ម៉ោង១០ និងរៀងរាល់ថ្ងៃសៅរ៍ថ្ងៃអាទិត្យ រ៉េត ព្រមទាំងនារីបើកឡានទាំងអស់ត្រូវអង្គភាពបញ្ជូនឲ្យទៅស្ទូងស្រូវថែមទៀត ។ ការហូបចុកគឺមិនបានគ្រប់គ្រាន់សមនឹងកម្លាំងដែលធ្វើការឡើយ ។ នារីមួយចំនួនត្រូវអង្គការផ្តល់អាហារឲ្យបីដងក្នុងមួយថ្ងៃ ហើយក្នុងអំឡុងពេលពីរសប្តាហ៍បន្ទាប់មកត្រូវបញ្ជូនទៅមន្ទីរពេទ្យដើម្បីពិនិត្យឈាមម្តង ។ នារីទាំងអស់មិនដឹងថាតើការពិនិត្យឈាមនេះមានគោលបំណងអ្វីទេ បុគ្គលិកពេទ្យគ្រាន់តែប្រាប់ថា អង្គការត្រូវការឈាមមិត្តនារីទាំងអស់ ។

រ៉េត រស់នៅក្នុងការដ្ឋានទាំងការភ័យខ្លាចហើយមិនដែលហ៊ានសុំអនុញ្ញាតមកលេងផ្ទះឡើយ ។ ថ្ងៃមួយ ម្តាយមីងរបស់ រ៉េត បានសរសេរសំបុត្រផ្ញើមកអង្គភាពរបស់ រ៉េត ដោយកុហកថាឪពុករបស់ រ៉េត នៅភូមិមានជំងឺ ។ ពេលនោះ រ៉េត បានសុំអនុញ្ញាតពីប្រធានកងមកផ្ទះបានរយៈពេលមួយថ្ងៃមួយយប់ ។ ពេលទៅដល់ផ្ទះ រ៉េត ដឹងថាឪពុកម្តាយបងប្អូនរបស់គាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅកងចល័តហើយការហូបចុកត្រូវអង្គការបង្ខំឲ្យហូបរួមនិងមិនគ្រប់គ្រាន់ឡើយ ។

ថ្ងៃដែលកងទ័ពខ្មែរក្រហមរត់ចេញពីទីក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៩ រ៉េត រួមជាមួយមិត្តភក្តិនៅក្នុងអង្គភាពក៏ជិះរថយន្តរបស់អង្គការចេញពីទីក្រុងភ្នំពេញដែរ ។ ចូលដល់ព្រៃជ្រៅរថយន្តទៅមុខលែងរួចក៏នាំគ្នារត់កាត់ព្រៃទៅដល់ខេត្តបាត់ដំបង ។ រ៉េត បានឆ្លងទៅរស់នៅក្នុងជំរំតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ រ៉េត ចង់ត្រឡប់មកផ្ទះវិញដែរ ប៉ុន្តែមិនស្គាល់ផ្លូវ ម្យ៉ាងដោយមិនមាននរណាមកជាមួយ គាត់ក៏រស់នៅក្នុងជំរំរហូតដល់បានជួបនិងរៀបការជាមួយប្តីរបស់គាត់ ។

រ៉េត វិលត្រឡប់មកភូមិកំណើតវិញនៅឆ្នាំ១៩៨៣ ដោយឡែកបងប្រុសម្នាក់របស់ រ៉េត ដែលចូលធ្វើទ័ពខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ បានបាត់ខ្លួនឈឹងរហូតមកដល់សព្វថ្ងៃ ។ ចំណែកបងស្រីម្នាក់ទៀតឈ្មោះ រុន និងប្តី ព្រមទាំងកូនៗសរុប៦នាក់ ដែលត្រូវអង្គការជម្លៀសចេញពីភ្នំពេញទៅខេត្តបាត់ដំបង កាលពីឆ្នាំ១៩៧៦ ត្រូវស្លាប់ទាំងអស់ ។ រ៉េត តែងតែនិយាយពីទុក្ខវេទនាដែលគាត់បានឆ្លងកាត់សម័យខ្មែរក្រហមប្រាប់កូនរបស់គាត់ជារឿយៗក្នុងគោលបំណងឲ្យក្មេងៗជំនាន់ក្រោយបានដឹងអំពីរឿងនេះ ។

**ផាន់ សុជា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៧-៧:៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៦:៣០-៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្តាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ផាត រចនា និង លី សុផល**

# នៅតែមានសង្ឃឹម


ខ្វាន់ ស៊ីចន

ខ្វាន់ ស៊ីចន ជាអតីតកម្មាភិបាលពេទ្យមួយរូបនៅក្នុងរបបខ្មែរក្រហម ។ រហូតមកដល់សព្វថ្ងៃនេះ គាត់បានរក្សាទុករូបថតមួយសន្លឹកដែលថតជាមួយប្តីរបស់គាត់ឈ្មោះ ធូ សារ៉ាត ។ នោះគឺជារូបដែលអ្នកទាំងពីរបានថតនៅហាងមួយក្បែរផ្សារកំពង់ចាមនៅឆ្នាំ១៩៧៤គឺក្រោយពេលរៀបការបានមួយឆ្នាំ ។ កាលនោះ ស៊ីចន មានផ្ទៃពោះ៣ខែ ហើយប្តីរបស់គាត់បានឌុបគាត់តាមកង់ទៅមន្ទីរពេទ្យដើម្បីពិនិត្យពោះ ។ ពេលត្រឡប់មកវិញ គាត់បានបបួលប្តីចូលថតរូបទុកជាអនុស្សាវរីយ៍ ។ គាត់ថតរូបជាមួយប្តីជាច្រើនសន្លឹក ប៉ុន្តែរហូតមកដល់សព្វថ្ងៃគាត់រក្សាទុកបានតែ១សន្លឹកនេះប៉ុណ្ណោះ ។ ស៊ីចន តែងតែនឹកឃើញប្តីរបស់គាត់ជានិច្ច ជាពិសេសគាត់នៅចាំពាក្យមួយឃ្លាដែលប្តីរបស់គាត់ធ្លាប់បាននិយាយប្រាប់ថា *"បងមានសំណាងណាស់ដែលបានអូនធ្វើជាប្រពន្ធ ប្រសិនបើបាត់អូន បងមិនរៀបការទៀតឡើយ"* ។


*ខ្វាន់ ស៊ីចន និង ធូ សារ៉ាត ក្នុងឆ្នាំ១៩៧៤*

ស៊ីចន និង សារ៉ាត បានរៀបមង្គលការនៅឆ្នាំ១៩៧៣ តាមប្រពៃណីបដិវត្តន៍ខ្មែរក្រហម ដែលមានកូនកម្លោះនិងកូនក្រមុំ២គូនិងមានការចូលរួមពីក្រុមគ្រួសារទាំងសងខាង ។ កាលណោះ ស៊ីចន មានតួនាទីជាប្រធានក្រុមយុទ្ធនារីផលិតវ៉ាក់សាំងនៅមន្ទីរពេទ្យជ-២ ភូមិភាគបូព៌ា ចំណែក សារ៉ាត ជាអនុប្រធានក្រុមផ្នែកយុទ្ធជន ។ មួយឆ្នាំក្រោយមក ស៊ីចន បានលាឈប់ពីតួនាទីជាប្រធានក្រុមដោយសារតែគាត់មានទំនាស់ជាមួយប្រធានមន្ទីរឈ្មោះ តាហេង និង សុវណ្ណ ម្យ៉ាងទៀតដោយសារតែគាត់មានកូននៅក្នុងបន្ទុកផង ។

ក្រោយខែមេសា ឆ្នាំ១៩៧៥ អង្គការបានដកអង្គភាពពេទ្យជ-២ មកប្រចាំការនៅមន្ទីរពេទ្យក្រុងភ្នំពេញមានទីតាំងនៅក្បែរជ្រោយចង្វារ ។ នៅទីនោះបច្ចេកទេសនិងឧបករណ៍ប្រើប្រាស់មានលក្ខណៈទំនើបជាងមន្ទីរពេទ្យនៅខាងភូមិភាគបូព៌ា ។ អៀង ធីរិទ្ធ ហៅ ភា តែងមកមន្ទីរពេទ្យនេះដើម្បីត្រួតពិនិត្យសកម្មភាពការងារនិងប្រជុំជាមួយកម្មាភិបាលពេទ្យជារឿយៗ ។ នៅក្នុងអង្គប្រជុំ ស៊ីចន និងសមាជិកដទៃទៀតបានប្រចោមនិយាយអំពីទោសកំហុសរបស់ សុវណ្ណ ជាប្រធានក្រុមដែលបានប្រើអំណាចផ្តាច់ការមកលើបុគ្គលិកពេទ្យ ។ ក្រោយពេលប្រជុំមិនយូរប៉ុន្មាន សុវណ្ណ ក៏ត្រូវអង្គការចាប់ខ្លួន ។

នៅឆ្នាំ១៩៧៦ ស៊ីចន ត្រូវបានអង្គការចាត់តាំងឲ្យមកទទួលគណៈប្រតិភូគុយបាក្នុងពេលមានពិធីសម្តែងសិល្បៈខ្មែរនៅសាលមហោស្រពចតុមុខ ។ គាត់បានទៅប្តូរសម្លៀកបំពាក់នៅមន្ទីរសង្គមកិច្ចនៅម្តុំផ្សារថ្មី ផ្លាស់សម្លៀកបំពាក់ខ្មៅចេញ ហើយស្លៀកហូលនិងដាមួងតាមបែបប្រពៃណីខ្មែរវិញ ។ ចំណែកយុទ្ធជនពាក់អាវពណ៌ស ។

មួយឆ្នាំក្រោយមក ស៊ីចន និង ប្តី ត្រូវបានអង្គការហៅឲ្យចូលរួមប្រជុំជាមួយកម្មាភិបាលមកពីខាងភូមិភាគបូព៌ា ។ ក្រោយពេលប្រជុំចប់ ប្រធាន

របស់គាត់បញ្ជាឲ្យគាត់រៀបចំអីវ៉ាន់ដើម្បីផ្លាស់ប្តូរទីកន្លែងទៅរស់នៅម្តុំបុរី១០០ខ្នងដើម្បីធ្វើការក្នុងរោងចក្រ ។ ពេល ស៊ីចន ទៅដល់ទីនោះ គាត់ត្រូវអង្គការចាត់ឲ្យធ្វើស្រែ ។ អៀង ធីរិទ្ធ ចេញចូលនៅទីនោះជាញឹកញាប់ដើម្បីអប់រំឲ្យយុវជនយុវនារីខិតខំប្រឹងប្រែងធ្វើការងារ ។ ២ខែក្រោយមក នៅថ្ងៃមួយ ពេលដែល ស៊ីចន កំពុងស្ទូងស្រូវ ស្រាប់តែមានរថយន្តមួយគ្រឿងមកដឹកអតីតកម្មាភិបាលនៅមន្ទីរពេទ្យ ជ-២ ទៅធ្វើការនៅទីកន្លែងផ្សេង ។ អ្នកនៅលីវត្រូវដឹកទៅកន្លែងផ្សេងពីអ្នកមានគ្រួសារ ចំណែក ស៊ីចន ត្រូវអង្គការផ្លាស់ឲ្យទៅធ្វើការនៅមន្ទីរពេទ្យ ព-១ (មន្ទីរពេទ្យកាល់ម៉ែត្រ) ជាមួយប្តីរបស់គាត់ដែលផ្លាស់ទៅតាំងពីពីរខែមុន ។ នៅពេទ្យ ព-១ ស៊ីចន ធ្វើការខាងដាំស្ល ចំណែកប្តីរបស់គាត់ធ្វើការខាងជួសជុលនិងសាងសង់អគារ ។ ពេលនោះគាត់មានផ្ទៃពោះកូនទី៣ ។ នៅចុងឆ្នាំ១៩៧៨ កូនច្បងរបស់គាត់ឈ្មោះ លាភ បានស្លាប់ដោយសារជំងឺនៅមន្ទីរពេទ្យ ព-១ ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ពេលដែល ស៊ីចន កំពុងស្ទូងស្រូវ មានក្មេងប្រុសម្នាក់បានរត់ទៅប្រាប់គាត់នៅវាលស្រែថាឲ្យគាត់រៀបចំអីវ៉ាន់ភ្លាមៗ ពីព្រោះមានមនុស្សជាច្រើនកំពុងរៀបចំអីវ៉ាន់រត់ ។ នៅពេលគាត់ទៅដល់ផ្ទះ ប្តីរបស់គាត់បានជញ្ជូនអីវ៉ាន់ចុះមកក្រោមរួចជាស្រេច ។ ស៊ីចន ឡើងទៅខាងលើផ្ទះម្តងទៀតដើម្បីរកមើលអីវ៉ាន់ក្រែងនៅមានសេសសល់មិនទាន់យក ។ នៅពេលចុះមកក្រោមវិញស្រាប់តែបាត់ប្តីរបស់គាត់មិនដឹងទៅណា ។ អ្នកជិតខាងប្រាប់គាត់ថា មានមនុស្សមកហៅ សាវ៉ាត ឲ្យទៅជញ្ជូនអីវ៉ាន់ពីឡានដាក់រថភ្លើង ។ ចាប់តាំងពីពេលនោះមក ស៊ីចន បានបែកពីប្តីជារៀងរហូត ។

ស៊ីចន និងកូនៗបានធ្វើដំណើរតាមរថភ្លើងទៅខេត្តបាត់ដំបង ។ ទៅដល់ទីនោះ គាត់បានទទួលដំណឹងថា ភ្នំពេញត្រូវកងទ័ពវៀតណាមវាយបែកហើយធ្វើឲ្យគាត់រឹតតែអស់សង្ឃឹមក្នុងការជួបប្តីរបស់គាត់វិញ ។ គាត់បានបន្តដំណើរតាមឡានរហូតទៅដល់ស្រុកបវេល ។ នៅតាមផ្លូវធ្វើដំណើរ គាត់បានប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើន ។ គាត់បានឈប់សម្រាកជាមួយប្រជាជននៅក្នុងសហករណ៍មួយក្នុងស្រុកបវេល ។ ពេលនោះគាត់បានជួបជនពិការមួយក្រុមហើយបានស្នើសុំដោយសាររទេះគោរបស់អ្នកទាំងនោះធ្វើដំណើរទាំងគ្មានគោលដៅច្បាស់លាស់ ។ បុរសម្នាក់ឈ្មោះ វី បានធានាជួយពកូនស្រីទីពីររបស់ ស៊ីចន ដើម្បីជួយសម្រាលកម្លាំងរបស់គាត់ខ្លះ ។ នៅពេលរត់គេចខ្លួនពីការដេញតាមរបស់កងទ័ពវៀតណាម ស៊ីចន ក៏វង្វេងបែកពី វី និងកូនស្រីទី២របស់គាត់ ។

នៅក្នុងពេលធ្វើដំណើរដែលប្រឈមមុខនឹងគ្រោះថ្នាក់គ្រប់យ៉ាង ស៊ីចន បានទទួលដំណឹងថាប្តីរបស់គាត់រស់នៅភូមិលាច ។ គាត់បានសម្រេចចិត្តទៅរកប្តីរបស់គាត់ដោយមិនបានទៅតាមរកកូនឡើយ ព្រោះនៅពេលនោះមានគ្រោះថ្នាក់ជាច្រើននៅតាមផ្លូវ ។

៩ឆ្នាំក្រោយមក ស៊ីចន បានឮដំណឹងថាកូនស្រីទី២របស់គាត់រស់នៅជាមួយនារីម្នាក់ធ្វើការនៅក្នុងសមាគមមួយនៅឃុំជយោ ។ ស៊ីចន បានទៅតាមរកកូនរបស់គាត់នៅទីនោះ ប៉ុន្តែនៅពេលគាត់ទៅដល់ កូនស្រីរបស់គាត់បានទៅបេះសណ្តែកនៅឃុំស្ពឺ ស្រុកចម្ការលើបាត់ទៅហើយ ។ គាត់បានស្នើសុំឲ្យនារីដែលជាម្តាយចិញ្ចឹមរបស់កូនស្រីគាត់ជូនគាត់ទៅរកកូននៅឯចម្ការ ក៏ប៉ុន្តែនារីនោះបដិសេធ ព្រោះមិនចង់ឲ្យកូនស្រីមកគាត់វិញ ដោយសារនារីនោះក៏ស្រឡាញ់កូនស្រីគាត់ទុកដូចជាកូនបង្កើតរបស់ខ្លួនដែរ ។ ស៊ីចន បានពឹងក្មេងម្នាក់ឲ្យជូនទៅស្ពឺ ហើយបានជួបកូនរបស់គាត់ពិតប្រាកដ ដោយគាត់ចំណាំមានស្លាកស្នាមនៅលើខ្លួន ។ នារីនោះនៅតែមិនអនុញ្ញាតឲ្យគាត់យកកូនមកផ្ទះវិញដដែល ។ ស៊ីចន បានប្តឹងដល់សាលាឃុំ រហូតដល់បានកូនត្រឡប់មកផ្ទះវិញ ។ ស៊ីចន រស់នៅជាមួយកូនបានតែ៧ឆ្នាំប៉ុណ្ណោះ កូននោះក៏ស្លាប់ដោយសារជំងឺស្អុន ។

សព្វថ្ងៃនេះ ស៊ីចន អាយុ៥៣ឆ្នាំ រស់នៅជាមួយប្អូននៅក្នុងភូមិទី៣ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ គាត់នៅសល់កូនស្រីម្នាក់ដែលកំពុងរស់នៅប្រទេសតៃវ៉ាន់ជាមួយប្តី ។ រាល់ពេលដែលគាត់ឃើញរូបថត គាត់តែងតែនឹកឃើញដល់អនុស្សាវរីយ៍រវាងគាត់និងប្តីរបស់គាត់ជានិច្ច ជាពិសេសនៅពេលជួបទុក្ខលំបាកវេទនាម្តងៗ ។ គាត់នៅតែទន្ទឹងមើលផ្លូវប្តី និងនៅតែសង្ឃឹមថាប្តីរបស់គាត់នៅរស់ហើយត្រឡប់មករកគាត់វិញនៅថ្ងៃណាមួយមិនខាន ។

**ប៉ាង ពីច័ន**

# ស្រុកឈូកក្នុងសម័យបដិវត្តន៍

ស្រុកឈូកជាស្រុកមួយនៅក្នុងខេត្តកំពត នៅតាមបណ្តោយផ្លូវជាតិលេខ៣ ។ ស្រុកឈូកមានចម្ងាយប្រមាណ១០០គីឡូម៉ែត្រពីក្រុងភ្នំពេញ ។ ខ្ញុំបានធ្វើដំណើរទៅស្រុកឈូកជាលើកដំបូងបំផុតក្នុងជីវិត ។ ប្រជាជនភាគច្រើនជាអ្នកស្រែចម្ការដែលមានភាពរួសរាយរាក់ទាក់និងស្និទ្ធស្នាល ។ កម្រិតជីវភាពនៃប្រជាកសិករទាំងនោះស្ថិតក្នុងស្ថានភាពសមរម្យ ។

បច្ចុប្បន្ននេះប្រជាជននៅស្រុកឈូកមិនមានការភិតភ័យដូចកាលពីអំឡុងសង្គ្រាមឆ្នាំ១៩៧០ឡើយ ។ កាលពីសង្គ្រាមឆ្នាំ១៩៧០ ស្រុកឈូកពោរពេញទៅដោយភាពប្រទាញប្រទង់គ្នារវាងទាហានលន់ណុលនិងកងទ័ពខ្មែររំដោះ ។ ប្រជាជនជាច្រើនបានរត់ចូលព្រៃចូលរួមជាមួយកងកម្លាំងតស៊ូរំដោះជាតិ ។

នៅឆ្នាំ១៩៦៨ កុប្បកម្មមួយដឹកនាំដោយ តាម៉ុក បានកើតឡើងនៅឃុំត្រពាំងរាំង ស្រុកឈូក ទាមទារឲ្យបំបាត់របបនាយទុនប្រតិកិរិយានិងរាជានិយម ។ នៅឆ្នាំ១៩៧០ បន្ទាប់ពីការធ្វើរដ្ឋប្រហាររបស់លន់ណុលទម្លាក់របបរាជានិយមដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ កងកម្លាំងតស៊ូបានបង្វែរទិសដៅរបស់ខ្លួនមកគាំទ្រខាងសម្តេច សីហនុ វិញ ។ ខ្មែររំដោះបានប្រើប្រាស់ហេតុផលថ្មីនិងសមរម្យមួយដើម្បីអូសទាញប្រជាជនឲ្យចូលរួមជាមួយខ្លួន គឺធ្វើបដិវត្តន៍ដើម្បីយកសម្តេចឪមកដឹកនាំប្រទេសជាថ្មី ។ ការឃោសនានេះបានទទួលលទ្ធផលគួរជាទីពេញចិត្ត ។ ប្រជាជនជាច្រើន ជាពិសេសយុវជនបានស្ម័គ្រចិត្តចូលព្រៃធ្វើបដិវត្តន៍ ។ សាលារៀនស្ទើរតែទាំងអស់ត្រូវបិទទ្វារ ។ ពីដើមភូមិដល់ចុងភូមិ ប្រជាជនជំនុំគ្នានិយាយតែអំពីការតស៊ូរំដោះជាតិវិញ ។

ចាប់ពីឆ្នាំ១៩៧២ ទំនប់រំលេចនិងទំនប់ស្ទឹងកេត្រូវបានធ្វើឡើងក្រោមផែនការលាក់កំបាំងមួយរបស់មេចលនាខ្មែររំដោះ ។ ទំនប់ទាំងពីរនេះជាយុទ្ធសាស្ត្រចម្បងមួយក្នុងចំណោមយុទ្ធសាស្ត្រដទៃទៀត ។ យុវជនយុវនារីរាប់សិបនាក់មកពីឃុំនានាក្នុងស្រុកត្រូវបានកេណ្ឌមកធ្វើទំនប់នេះ ។ ប្រជាជនដែលមានទីលំនៅឆ្ងាយពីការដ្ឋានលើកទំនប់ត្រូវចំណាយពេលជាច្រើនថ្ងៃទើបទៅដល់ទំនប់ ។ ព្រៃភ្នំក្រាំថ្មគឺជាជម្រកបណ្តោះអាសន្នសម្រាប់អ្នកទាំងនោះ ។ ក្រៅពីការងារលើកទំនប់ កិច្ចប្រជុំតូចៗតែងត្រូវធ្វើឡើងជាញឹកញាប់ ។ បដិវត្តន៍មួយបានរីកលូតលាស់កាន់តែធំឡើងៗចេញពីស្រទាប់កសិករ ។

ក្នុងឆ្នាំដដែលនេះការទម្លាក់គ្រាប់បែករបស់កងទ័ពអាកាសអាមេរិកបានចាប់ផ្តើមនៅខេត្តកំពតនិងខេត្តផ្សេងៗទៀត ។ ស្រុកឈូកក៏ត្រូវទទួលរងនូវការទម្លាក់គ្រាប់បែកនេះដែរក្នុងនោះទីតាំងសំខាន់ៗរបស់ខ្មែររំដោះដែលមាននៅក្នុងព្រៃជ្រៅៗត្រូវបានបំផ្លាញស្ទើរអស់ ។ ចំណុចណាត់ជួបប្រជុំរវាងភាគីខ្មែររំដោះនិងវៀតណាមនៅអន្លង់រស់ស្ថិតនៅកណ្តាលព្រៃដែលមានភ្នំពទ័ជុំវិញក្នុងឃុំស្វាយអញ្ចិត ស្រុកឈូក (បច្ចុប្បន្នស្រុកជុំគីរី) ក៏ត្រូវយន្តហោះទម្លាក់គ្រាប់បំផ្លាញអស់ដែរ ។ រណ្តៅគ្រាប់បេ-៥២ រាប់រយកន្លែងបានក្លាយទៅជាអាងស្តុកទឹក និងកន្លែងកប់សាកសពប្រជាជនដែលស្លាប់ដោយការអត់ឃ្លាននិងធ្វើការហួសកម្លាំង ។ បងប្អូនជីដូនមួយពីរនាក់របស់ ខេង ញ៉ី បានស្លាប់ក្នុងពេលលើកទំនប់រំលេច ។ ញ៉ី ក៏ធ្លាប់បានទៅតាមឪពុកម្តាយរបស់ខ្លួនដើម្បីលើកទំនប់ទាំងពីរខាងលើដែរ ។ ញ៉ី រៀបរាប់ថា "កាលនោះខ្ញុំនៅតូច


ខេង ញ៉ី

នៅឡើយហើយមិនបានរៀនសូត្រអីទាំងអស់ ។ ព្រលឹមឡើងដឹងតែពីរែកដី លើកទំនប់" ។ កាលណោះ ញ៉ី ពុំទាន់គ្រប់អាយុ១០ឆ្នាំនៅឡើយទេ ឪពុកម្តាយរបស់ ញ៉ី មិនបានគិតគូរដល់ការរៀនសូត្ររបស់នាងឡើយ ។

នៅដើមឆ្នាំ១៩៧៤ ជម្លោះរវាងកងទ័ពខ្មែររំដោះជាមួយកងទ័ពរំដោះវៀតណាមនៅក្នុងព្រៃដែលដឹកនាំដោយ ទីកាម បានកើតឡើងព្រមគ្នាជាមួយនឹងការខិតខំវាយបណ្តេញរបប

សាធារណរដ្ឋខ្មែរឲ្យចាកចេញពីអំណាច ។ ទីបំផុតកងទ័ពរំដោះរបស់វៀតណាមបានចាកចេញពីទឹកដីកម្ពុជា ។ នៅសល់តែមួយមុខព្រួញប៉ុណ្ណោះដែលត្រូវកម្ចាត់នោះគឺរបបសាធារណរដ្ឋខ្មែរ ។ ប្រជាជនងាកទៅរកចលនាខ្មែររំដោះកាន់តែច្រើនឡើងៗ ។ ការផ្គត់ផ្គង់ជាស្បៀងអាហារនិងសម្ភារក៏មានចំនួនកាន់តែច្រើនឡើងៗដែរ ។ មិនយូរប៉ុន្មានស្រុកឈូកទាំងមូលបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ចលនាខ្មែររំដោះ ។ នៅខែមេសា ឆ្នាំ១៩៧៥ ជ័យជម្នះទាំងស្រុងបានធ្លាក់មកលើខ្មែរក្រហម ។ រចនាសម្ព័ន្ធការងារទាំងឡាយត្រូវបានរៀបចំឡើងនាពេលបន្ទាប់នៅតាមបណ្តាភូមិ ឃុំ ស្រុក តំបន់ និងភូមិភាគ ។ មកដល់ឆ្នាំនេះ ភារកិច្ចលើកទំនប់នៅតែបន្ត ឯមនុស្សស្លាប់នៅតែមានច្រើន ។ ទំនប់កោះស្លាត្រូវបានកសាងឡើងតាមផែនការរបស់ថ្នាក់លើ ។ ប្រជាជនទូទាំងខេត្តកំពតត្រូវជាប់កំណែនឲ្យមកលើកទំនប់ចំនួនបីខាងលើដើម្បីស្តុកទឹកធ្វើស្រែនារដូវប្រាំង ។ ប្រជាជនដែលត្រូវកេណ្ឌឲ្យទៅលើកទំនប់កោះស្លាត្រូវចំណាយពេលធ្វើដំណើររហូតដល់មួយខែឯណោះ ។ កែវ ឈឿន មេភូមិបឹងនិមល ឃុំបឹងនិមលបាននិយាយថា អ្នកដែលទៅលើកទំនប់នៅកោះស្លា ភាគច្រើនចេញពីកងចល័តឃុំនិងស្រុក ។ អ៊ុំ តាំ ធ្លាប់បានជ្រើសរើសចេញពីកងចល័តស្រុកទៅលើកទំនប់នៅកោះស្លា ។ តាំ ជាអតីតកម្មាភិបាលខ្មែរក្រហមដែលត្រូវបានជ្រើសរើសទៅធ្វើជានារីពេទ្យនៅភ្នំពេញកាលពីឆ្នាំ១៩៧៧ ។ ក្រៅពីតាំ នៅមាន គុន, មិន ឃឿន, ស៊ីន, ហោម, ភើយ និងអ្នកផ្សេងជាច្រើនទៀតដែលមានរឿងរ៉ាវដូចៗគ្នា ។ ប្រជាជនមូលដ្ឋានខ្លះត្រូវជម្លៀសចេញទៅឆ្ងាយពីស្រុកកំណើត ព្រោះអង្គការស៊ើបដឹងថាមានជាប់សាច់ឈាមជាមួយអ្នកនៅភ្នំពេញ ។ កុមារតូចៗត្រូវបញ្ជូនទៅតាមកងកុមារចល័តឃុំនិងស្រុក ។ ភារកិច្ចចម្បងនៃអ្នកទាំងនោះគឺលើកទំនប់ ។ តាមសម្តីរបស់ ផែន ដែលជាសមាជិកគណៈកម្មការស្រុកឈូក ទទួលបន្ទុកវប្បធម៌និងសង្គមកិច្ចកាលរបបខ្មែរក្រហមបានអះអាងថា ការលើកទំនប់គឺជាផែនការស្នើសុំដោយថ្នាក់តំបន់ ។ ផែនការនេះបានកំណត់ទិសដៅការងារយ៉ាងតឹងរ៉ឹងបំផុត ។ ប្រជាជន១៧មេសាដែលជម្លៀសចេញពីទីក្រុងភ្នំពេញទៅបានស្លាប់អស់យ៉ាងច្រើនដោយសារជំងឺគ្រុនចាញ់ អត់អាហារ ធ្វើការហួសកម្លាំង ។ ប្រជាជនមូលដ្ឋានជាច្រើនទៀតបានស្លាប់តាមរបៀបដូចគ្នាដែរ ។ កងឈ្លបក្មេងៗ គណៈភូមិនិងគណៈឃុំ គឺជាអ្នកមើលការខុសត្រូវដោយផ្ទាល់ទៅលើអ្នកទាំងនោះ និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការបញ្ជាសម្លាប់ ឬធ្វើទារុណកម្ម ។ ផែន និយាយថា គាត់ជាអ្នកដាក់បញ្ជាផ្ទាល់ដល់ប្រជាជនឲ្យលើកទំនប់ដើម្បីឲ្យទាន់ផែនការថ្នាក់លើដាក់ចុះ បើអ្នកណាមិនខិតខំធ្វើការនឹងត្រូវហៅមកអប់រំកសាងឬយកទៅរៀនសូត្រ ។


អ៊ុំ តាំ

គណៈភូមិមាននាទីរាយការណ៍លទ្ធផលការងារមកគណៈឃុំនៅរៀងរាល់មួយសប្តាហ៍ឬពីរសប្តាហ៍ម្តង ។ គណៈឃុំរាយការណ៍ទៅគណៈស្រុក ចំណែកគណៈស្រុកនឹងរាយការណ៍បន្តទៅតំបន់ហើយតំបន់បន្តទៅភូមិភាគ ។ ផែន បានរាយការណ៍អំពីលទ្ធផលការងារដែលទទួលបានពីភូមិទៅឲ្យថ្នាក់ស្រុកក៏ដូចជាចាំទទួលការងារពីថ្នាក់ស្រុកមកអនុវត្តបន្តដែរ ។ ក្រៅពីតួនាទីជាសមាជិកគណៈកម្មការស្រុកឈូក ផែន នៅមានភារកិច្ចមួយទៀតគឺគ្រប់គ្រងឃុំចំនួនបី គឺឃុំស្រែចែង ឃុំត្រពាំងរាំង និងឃុំខ្ពករុន ។ ក្រៅពីដឹកនាំឲ្យកសិករលើកទំនប់ ផែន បានដឹកនាំឲ្យធ្វើស្រែតាមផែនការមួយហិកតាបីតោនថែមទៀត ។

ឆ្នាំ១៩៧៧បន្ទាប់ពីទំនប់ទាំងអស់កសាងហើយជាស្ថាពរ កុមារនិងយុវជនយុវនារីត្រូវអង្គការជ្រើសរើសឲ្យទៅធ្វើការនៅភ្នំពេញ ។ ប្រវត្តិការងារគ្រប់គ្រងត្រូវបានសើរើមកពិនិត្យ ។ កង សាមឿន, ឡឹក អ៊ុប, ឌុក នី និងអ្នកដទៃជាច្រើនរូបទៀតគឺជាអ្នកដែលមានសំណាងបានទៅធ្វើការនៅភ្នំពេញ ។ លោកគ្រូបង្រៀនក្មេងៗគឺជាអ្នកជ្រើសរើសក្មេងៗដោយផ្ទាល់តាមបញ្ជាពីគណៈឃុំ ។ ឪពុកម្តាយរបស់ក្មេងៗទាំងនោះមិនបានដឹងអំពីការផ្លាស់ប្តូរការងារនេះ ហើយក៏មិនដឹងអំពីកន្លែងដែលកូនៗរបស់គាត់ស្នាក់នៅទីណាដែរ ។ ការជ្រើសរើសបានធ្វើឡើងនៅក្នុងឃុំជាច្រើននៅក្នុងស្រុកឈូក ។ បន្ទាប់ពីកុមារត្រូវបែងចែកទៅ

ធ្វើការកន្លែងថ្មីអស់ហើយ គ្រូៗក៏បានទទួលភារកិច្ចថ្មីដែរគឺមួយចំនួនធ្វើការនៅក្នុងរោងចក្រតម្បាញមងនៅចាក់អង្រែនៃទីក្រុងភ្នំពេញ មួយចំនួនធ្វើជាអ្នកថែរក្សាជនពិការនៅមន្ទីរពេទ្យវិកលចរិតតាខ្មៅ និងមួយចំនួនទៀតធ្វើជាអ្នកជូនភ្ញៀវអន្តរជាតិ ។

ជំទប់លេខ១ឃុំស្រែក្នុងឈ្មោះ សួស ណែប អាយុ៥០ឆ្នាំនិយាយថា "គ្មាននរណាម្នាក់គេចផុតពីកំណែននេះទេ ឲ្យតែអ្នកនោះមានប្រវត្តិការងារល្អ" ។ ខៀវ ភា បច្ចុប្បន្នអាយុ៣៩ឆ្នាំ គឺជាអតីតកម្មាភិបាលខ្មែរក្រហមដែលក្មេងបំផុតក្នុងចំណោមកម្មាភិបាលទាំង១០នាក់ដែលត្រូវជ្រើសរើសយកទៅធ្វើការនៅទីក្រុងភ្នំពេញ ។ ចាស់ទុំក្នុងភូមិបាននិយាយថា ភា បានទៅធ្វើការទាំងខ្លួនមិនដឹងអ្វីទាល់តែសោះ ។ មិន យឿន សប្បាយនឹងការងាររហូតភ្លេចទឹកនាដល់ឪពុកម្តាយនៅឯស្រុកកំណើត ។ ជារៀងរាល់ថ្ងៃ យឿន និងកម្មាភិបាលឯទៀតត្រូវបានអនុញ្ញាតឲ្យទៅមើលកុនច្រៀងរាំរែក និងទទួលការអប់រំមនោគមវិជ្ជាពីអង្គការ ។ តាម៉ុក អនុញ្ញាតឲ្យក្មេងៗទាំងអស់ដែលដឹកជញ្ជូនមកពីស្រុកឈូកនិងស្រុកឯទៀតស្នាក់នៅបណ្តោះអាសន្ននៅផ្ទះរបស់គាត់ ។ សាយ ថុន អាយុ៤២ឆ្នាំ ជាអតីតកម្មាភិបាលនៅរោងចក្រតម្បាញមងចាក់អង្រែបានរំឭកថា គាត់បានស្នាក់នៅផ្ទះ តាម៉ុក ចំនួនបីថ្ងៃ ។ ក្មេងៗដែលមានពាក់គ្រឿងអលង្ការត្រូវដោះចេញទាំងអស់ ។ តាម៉ុក គឺជាអ្នកដោះគ្រឿងអលង្ការពីខ្លួនកុមារទាំងអស់ដោយផ្ទាល់ដៃ ។ បន្ទាប់មកក្មេងៗទាំងអស់បានធ្វើប្រវត្តិរូបដើម្បីចូលធ្វើការនៅតាមកន្លែងដែលបានគ្រោងទុក ។


ខៀវ ភា


សាយ ថុន

អ្នកដែលមានប្រវត្តិមិនល្អត្រូវបញ្ជូនទៅមន្ទីរអប់រំកែប្រែតំបន់ភ្នំដារឬទៅភូមិខ្ទិលដើម្បីអប់រំឲ្យជ្រះស្រឡះពីកម្មែលសក្តិភូមិ ។ ប្អូនស្រីបង្កើតរបស់ ញ៉ី ត្រូវអង្គការបញ្ជូនទៅមន្ទីរសន្តិសុខភ្នំដារ និងក្រោយមកបញ្ជូនទៅភូមិខ្ទិលដែលមានទីតាំងស្ថិតនៅក្នុងឃុំដូនយ៉យ ស្រុកឈូក ព្រោះតែនាងមិនព្រមកាត់សក់និងបានលួចលាបម្សៅ ។ មនុស្សរាប់ពាន់នាក់បានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំដារ ។ អ្នកទោសនៅទីនោះគឺជាអ្នកខិលច្រអូសនឹងការងារ អ្នកជាប់និន្នាការនយោបាយ និងអ្នកខុសសីលធម៌ ។ នៅមន្ទីរសន្តិសុខស្រុកឈូកក៏ដូចគ្នាដែរ ។ គុន គឺជាប្រធានមន្ទីរសន្តិសុខ ។ មានមនុស្សរាប់ពាន់នាក់បានស្លាប់នៅក្នុងមន្ទីរសន្តិសុខទាំងពីរនេះ ។ ជើងភ្នំតាកុចគឺជាទីតាំងសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម ។

រោងចក្រចក្រីទីងមួយត្រូវបានកសាងឡើងកាលពីឆ្នាំ១៩៧៦ នៅក្នុងស្រុកឈូក ដែលមានឈ្មោះ ឈុំ ជាប្រធាន និងឈ្មោះ ចេង ជាអនុប្រធាន ។ យុវជនយុវនារីភាគច្រើនជាអ្នកមកពីស្រុកឈូកត្រូវបានជ្រើសរើសឲ្យធ្វើជាកម្មករនៅក្នុងរោងចក្រនេះ ។ ឈុន លិ អាយុ៥៨ឆ្នាំ ជាប្រពន្ធរបស់ ចេង និងជាកម្មការិនីនៅក្នុងរោងចក្រចក្រីទីង បានប្រាប់ថា គាត់ស្ពឹកដៃជើងរហូតដល់សព្វថ្ងៃនេះព្រោះតែជាតិស៊ីម៉ង់ត៍និងគីមី ។ ឈុំ និង ចេង ត្រូវអង្គការចាប់ខ្លួនហើយបញ្ជូនទៅកាន់គុកទួលស្លែង នៅខែធ្នូ ឆ្នាំ១៩៧៨ ។ លិ និយាយថា ប្តីរបស់គាត់ត្រូវអង្គការហៅទៅភ្នំពេញតែ៩ថ្ងៃប៉ុណ្ណោះមុនថ្ងៃដួលរលំនៃរបបខ្មែរក្រហម ។


ឈុន លិ

ក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ កុមារដែលបានមកធ្វើការនៅភ្នំពេញទាំងប៉ុន្មានបានរត់គេចខ្លួនទៅទីជនបទឆ្ងាយៗ ហើយមិនហ៊ានវិលមករស់នៅស្រុកកំណើតវិញទេ ។ បូ, ចន, ឡែម, អ៊ីម និងអ្នកផ្សេងជាច្រើនទៀតបានទៅរស់នៅតាមទីកន្លែងឆ្ងាយៗពីស្រុកកំណើត ហើយបានមកលេងស្រុកកំណើតម្តងម្កាលប៉ុណ្ណោះ ។ ចំណែក សៀវ, ជុំ ខន, សន ង៉ែម, ដាន់ ជឿន,

តុញ ទន និងអ្នកផ្សេងជាច្រើនទៀត បានបាត់ខ្លួននិងស្លាប់ក្នុងពេលរត់គេចនៅឆ្នាំ១៩៧៩ ។ នៅមានមនុស្សផ្សេងៗជាច្រើនទៀតដែលរហូតមកដល់សព្វថ្ងៃនេះនៅតែពុំមានដំណឹងបន្តិចទាល់តែសោះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារប្រវត្តិរូបរបស់អតីតកម្មាភិបាលខ្មែរក្រហមមកពីស្រុកឈូកបានចំនួន២០៦ ឯកសារក្នុងចំណោមឯកសាររាប់ម៉ឺនសន្លឹកដែលនៅសេសសល់ពីការដុតបំផ្លាញ ។ ក្នុងចំណោមឯកសារទាំងនេះ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវឃើញថា មានអតីតកម្មាភិបាលខ្មែរក្រហមចំនួន១០៥នាក់ ដែលនៅរស់រហូតមកដល់បច្ចុប្បន្ន ក្នុងនោះមាន៤៩នាក់កំពុងបន្តការនៅរស់ក្នុងស្រុកកំណើត និង៥៦នាក់ទៀតកំពុងរស់នៅខេត្តផ្សេងៗនិងនៅបរទេស ។ ចំណែកឯអ្នកដែលបាត់ខ្លួន ក្រុមស្រាវជ្រាវបានរកឃើញចំនួន៧១នាក់និង១២នាក់ផ្សេងទៀតបានស្លាប់នៅក្រោយឆ្នាំ១៩៧៩ ។ រីឯប្រវត្តិរូបចំនួន១៨ទៀតក្រុមស្រាវជ្រាវមិនបានរកឃើញអត្តសញ្ញាណឡើយ ។ **ផេង ពង្សរ៉ាស៊ី**

# មិនបានរៀនព្រោះរវល់ធ្វើបដិវត្តន៍



អ៊ុន សារ៉េម

វ័យកុមារគឺជាវ័យដែលត្រូវការនូវការថែទាំដិតដល់ពីឪពុកម្តាយនិងត្រូវការទៅសាលារៀនដើម្បីក្រេបជញ្ជក់យកចំណេះដឹង ។ កុមារគួរតែបានរស់នៅជួបជុំឪពុកម្តាយបងប្អូនមានការហូបចុកគ្រប់គ្រាន់ មិនមានការរំលោភបំពាន មិនមានអំពើហិង្សា មិនត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ហួសពីកម្លាំង ។ ផ្ទុយទៅវិញ របប៣ឆ្នាំ៨ខែនិង២០ថ្ងៃដែលដឹកនាំដោយខ្មែរក្រហមបានប្រើប្រាស់កម្លាំងពលកម្មរបស់កុមារហួសពីសមត្ថភាព ។ អ្វីដែលជាតម្រូវការចាំបាច់របស់កុមារ ខ្មែរក្រហមមិនបានផ្តល់ឲ្យទេ ។ នៅក្នុងរបបនោះ កុមារធ្វើការដូចជាទាសករ វែកដី លើកទំនប់ ជីកប្រឡាយ និងធ្វើការងារផ្សេងៗទៀតជាច្រើនដែលខ្លួនមិនធ្លាប់បានធ្វើពីមុនមក ។

ខែមិថុនាកន្លងមកនេះ ខ្ញុំបានចុះទៅស្រាវជ្រាវនិងធ្វើសម្ភាសន៍ជាមួយប្រជាជនមួយចំនួនដែលរស់នៅក្នុងស្រុកឈូកនិងស្រុកជុំគីរី ខេត្តកំពត ។ ប្រជាជនដែលខ្ញុំបានជួបសុទ្ធសឹងជាអ្នកដែលបានឆ្លងកាត់ជីវិតកុមារភាពនៅក្នុងរបបខ្មែរក្រហម ។ ខាងក្រោមនេះគឺជាសាច់រឿងរបស់ស្ត្រីម្នាក់ឈ្មោះ អ៊ុន សារ៉េម ដែលបានចំណាយរយៈពេល៤ឆ្នាំធ្វើការបម្រើខ្មែរក្រហម ។

សារ៉េម ឈប់រៀនត្រឹមថ្នាក់ទី១០ក្នុងឆ្នាំ១៩៧៤ នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ភូមិ ។ ការរស់នៅជួបជុំឪពុកម្តាយបានរយៈពេលមិនយូរប៉ុន្មាន សារ៉េម ត្រូវបានជម្លៀសឲ្យទៅធ្វើការនៅឯទំនប់រំលេចតាមរយៈការចាត់តាំងរបស់ប្រធានឃុំ ។ សារ៉េម មិនមានចិត្តចង់ទៅបន្តិចសោះឡើយ ចំណែកឪពុកម្តាយរបស់ សារ៉េម ក៏មិនពេញចិត្តឲ្យ សារ៉េម ទៅឆ្ងាយដែរ ។ សារ៉េម មានអាយុទើបតែ១២ឆ្នាំប៉ុណ្ណោះ ។ ក្មេងៗរស់នៅក្នុងភូមិរបស់ សារ៉េម ស្ទើរតែទាំងអស់ បានចេញដំណើរទៅជាមួយគ្នាដោយខានមិនបាន ។ សារ៉េម ត្រូវបានអង្គការចាត់ចូលទៅក្នុងកងកុមារដែលមានចំនួនកុមាររាប់រយនាក់ ។ ពេលទៅដល់ទំនប់រំលេច គាត់ត្រូវបានដឹកនាំឲ្យធ្វើការងារដោយប្រធានកងឈ្មោះ យ៉េន ។ សារ៉េម ធ្វើការងារជាមួយកុមារជាច្រើនដែលមកពីភូមិឃុំផ្សេងៗគ្នា ។ ជារៀងរាល់ថ្ងៃ សារ៉េម ត្រូវក្រោកពីម៉ោង៥ភ្លឺរៀបចំខ្លួនចេញទៅវែកដីលើកទំនប់ជីក ប្រឡាយដើម្បីបង្ហូរទឹកបញ្ចូលស្រែ កាប់ឆ្ការព្រៃ និងជម្រះស្មៅ ។ គាត់ត្រូវធ្វើការងារតាំងពីព្រលឹមរហូតទល់យប់ទើបអាចសម្រាកបាន ។ សារ៉េម បានហូបត្រឹមតែបបរមួយកូនចានប៉ុណ្ណោះសម្រាប់អាហារមួយពេល ។ សារ៉េម មានការធុញទ្រាន់នឹងការងារជាខ្លាំង ប៉ុន្តែមិនហ៊ានជំទាស់នឹងបញ្ជារបស់អង្គការ ។ បន្ទាប់ពីលើកទំនប់

បានមួយរយៈ អង្គការក៏ចាត់តាំងឲ្យ សារ៉ែម ចូលក្នុងកងស្ទូង នៅជិតទំនប់រំលេច ។ សារ៉ែម អត់ធ្មត់ទ្រាំទ្រនឹងការងារដ៏សែនលំបាកនេះអស់រយៈពេលប្រហែលជាងមួយឆ្នាំ ទើបអង្គការផ្លាស់គាត់ឲ្យធ្វើការផ្សេងទៀត ។ ចេញពីរំលេច សារ៉ែម ត្រូវអង្គការចាត់ឲ្យទៅធ្វើការនៅទំនប់កោះស្លា ក្នុងខេត្តកំពត ។ នៅទំនប់កោះស្លា សារ៉ែម ធ្វើការងារធ្ងន់ធ្ងរជាងនៅទំនប់រំលេចទៅទៀត ព្រោះគាត់នៅក្នុងកងពិសេស ។ កុមារនៅក្នុងកងពិសេសតម្រូវឲ្យប្រឹងប្រែងធ្វើការងារជាងកុមារក្នុងកងធម្មតា ហើយពេលបំពេញការងារ ប្រធានកងនៅឈរមើលជាប់ជាប្រចាំ ។

ឆ្នាំ១៩៧៨ ដោយមើលឃើញថា សារ៉ែម ជាមនុស្សខស្សរាហ៍ព្យាយាមយកចិត្តទុកដាក់នឹងការងារ និងមានប្រវត្តិរូបល្អ អង្គការបានចាត់តាំង សារ៉ែម ឲ្យទៅធ្វើការនៅភ្នំពេញ ។ សារ៉ែម និងកុមារផ្សេងៗទៀតបានធ្វើដំណើរតាមរថយន្តទៅផ្ទះរបស់ តាម៉ុក ដែលមានទីតាំងនៅទូកមាសខេត្តកំពត ដើម្បីជួបជុំជាមួយកុមារមកពីស្រុកផ្សេងៗទៀត មុននឹងចេញដំណើរទៅភ្នំពេញ ។ បន្ទាប់ពីមកជួបជុំគ្នាហើយ ២ម៉ោងក្រោយមក សារ៉ែម ហើយនិងកុមារជាច្រើនទៀតត្រូវអង្គការនាំមកកាន់ទីក្រុងភ្នំពេញតាមរថភ្លើង ។ មកដល់ទីក្រុងភ្នំពេញភ្លាម កុមារត្រូវបានបែងចែកទៅតាមអង្គភាពនានា ។ សារ៉ែម ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរពេទ្យ៦មករានៅជិតវត្តភ្នំ (ពេទ្យព្រះកេតុមាលា) ។ ដំបូងសារ៉ែម ត្រូវបានអង្គការប្រើឲ្យបោសសំរាមនិងលាងបន្ទប់មន្ទីរពេទ្យ ។ បន្ទាប់មកទៅប្រមូលកំប្រេះដែលរុំរបួស រួចយកទៅបោកគក់ ។ គាត់មានការខ្ពើមរអើមជាខ្លាំង ពីព្រោះកំប្រេះទាំងនោះប្រឡាក់សុទ្ធតែខ្ទុះឈាម ។ ក្រៅអំពីការងារនេះ គាត់មានការកិច្ចលាងរបួសនិងចាក់ថ្នាំឲ្យអ្នកជំងឺថែមទៀត ។ សារ៉ែម មិនដែលចេះវិជ្ជាពេទ្យពីមុនមកទេ ។ សារ៉ែម បំពេញតួនាទីជាពេទ្យលាងរបួសនេះជារៀងរាល់ថ្ងៃ ។ គាត់តែងតែនឹកគិតអំពីសុខទុក្ខឪពុកម្តាយនិងបងប្អូនរបស់គាត់ដែលរស់នៅខេត្តកំពតជានិច្ច ។ សារ៉ែម ខស្សរាហ៍សុំអង្គការមកលេងផ្ទះដែរ ប៉ុន្តែគាត់មិនដែលបានទទួលការអនុញ្ញាតម្តងណាឡើយ ។ សារ៉ែម រស់នៅមន្ទីរពេទ្យ៦មករាបានរយៈពេលប្រហែលមួយឆ្នាំ ។

ដោយមានការវាយប្រហាររបស់កងទ័ពវៀតណាមនៅចុងឆ្នាំ១៩៧៨ សារ៉ែម និងបុគ្គលិកនៅមន្ទីរពេទ្យ៦មករាទាំងអស់ត្រូវបានអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញទៅខេត្តពោធិសាត់ និងបាត់ដំបងដោយរថភ្លើង ។ សារ៉ែម មានការភ័យខ្លាចខ្លាំងណាស់ ព្រោះខ្មែរក្រហមបានបំផុសថា "កាលណាកងទ័ពវៀតណាមចាប់បាននឹងអារ-កគ្រប់ៗគ្នា ដូច្នេះយើងត្រូវតែនាំគ្នាទៅមុខដើម្បីជួយជាកម្លាំងវាយប្រានពួកឈ្លានពានវៀតណាមចេញឲ្យអស់ពីទឹកដីវិញ" ។ ធ្វើដំណើរពេញមួយយប់ រថភ្លើងបានទៅដល់ខេត្តបាត់ដំបង ហើយទាំងអស់គ្នាត្រូវធ្វើដំណើរដោយថ្មើរជើងបន្តទៀត ។ សារ៉ែម បានធ្វើដំណើរទៅសហករណ៍ដើម្បីស្នាក់នៅ និងគេចពីគ្រាប់កាំភ្លើងដែលបាញ់តគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម ។ នៅតាមផ្លូវមានការបាញ់ប្រហារយ៉ាងខ្លាំងរវាងកងទ័ពទាំងពីរ ។ សារ៉ែម រត់បណ្តើរ សែងអ្នករបួសបណ្តើរ និងមិនមានស្បៀងសម្រាប់ទទួលទានទេ គឺមានតែស្ទឹកឈើវល្លិ៍ឈើដែលដុះក្នុងព្រៃសម្រាប់ហូបជំនួសបាយប៉ុណ្ណោះ ។ សារ៉ែម ធ្វើដំណើរមកដល់ខេត្តពោធិសាត់ ហើយបានស្នាក់នៅទីនោះមួយខែក្រោមការជួយឧបត្ថម្ភពីប្រជាជន ។

នៅខែមីនា ឆ្នាំ១៩៧៩ សារ៉ែម បានមកដល់ស្រុកកំណើតនៅខេត្តកំពតវិញ ។ សារ៉ែម មានការនឹករឭកឪពុកម្តាយនិងបងប្អូនជាខ្លាំង ។ សព្វថ្ងៃ អ៊ុន សារ៉ែម អាយុ៤៦ឆ្នាំ រស់នៅ ឃុំត្រពាំងប្រៃ (អតីតឃុំការពារ) ស្រុកជុំគីរី (អតីតស្រុកឈូក) ។ ប្តីរបស់គាត់ឈ្មោះ សម្បត្តិ អាយុ៥៤ឆ្នាំ និងមានកូនចំនួន ៧នាក់ ។ សារ៉ែម មានឪពុកឈ្មោះ មេឃ យ៉ាន់ និងម្តាយឈ្មោះ ជុំ ញ៉ែម ។

សារ៉ែម មានការសោកស្តាយជាខ្លាំងចំពោះអំពើដែលខ្មែរក្រហមធ្វើមកលើគាត់ ។ សារ៉ែម តែងតែគិតថាប្រសិនបើគ្មានរបបខ្មែរក្រហមនោះទេ ម្ល៉េះសមគាត់បានរៀនសូត្រមានចំណេះដឹងខ្ពស់ និងមានកម្រិតជីវភាពធូរធារជាងសព្វថ្ងៃមិនខាន ។ សារ៉ែម បានគាំទ្រការបង្កើតឲ្យមានតុលាការដើម្បីជំនុំជម្រះទោសទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលបានប្រព្រឹត្តអំពើព្រៃផ្សៃមកលើប្រជាជនខ្មែរទាំងអស់ ។

**សារិន ឌីរ:**




លលាដ៍ក្បាលជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



# ជម្លោះនៅដាហ្វួរៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅប្រទេសស៊ូដង់

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៣ ខេត្តភាគខាងលិចនៃប្រទេសស៊ូដង់ហៅថា ខេត្តដាហ្វួរ គឺជាទីតាំងនៃជម្លោះដ៏ធ្ងន់ធ្ងររវាងកុលសម្ព័ន្ធចរកជនជាតិពន្ធអារ៉ាប់គាំទ្រដោយរដ្ឋាភិបាលនៅទីក្រុងខាទុមទល់នឹងកុលសម្ព័ន្ធជនជាតិដើមអាហ្វ្រិកដែលជាកសិករមានទីលំនៅអចិន្ត្រៃយ៍ ។

**ឫសគល់នៃជម្លោះ**

ខេត្តដាហ្វួរស្ថិតនៅភាគខាងលិចបំផុតនៃប្រទេសស៊ូដង់ ជាប់នឹងប្រទេសលីប៊ីនិងប្រទេសឆាដ មានផ្ទៃក្រឡាជិត៨សែនគីឡូម៉ែត្រក្រឡា ព្រមទាំងមានប្រជាជនរស់នៅប្រហែល៨លាននាក់ គឺច្រើនជាងខេត្តផ្សេងៗទៀតនៅនៃប្រទេសស៊ូដង់ ។ ខេត្តនេះមានទីតាំងនៅលើតំបន់ខ្ពង់រាបនៃភ្នំភ្លើង ជីបែល ម៉ារ៉ា ។ បរិមាណទឹកភ្លៀងជាកត្តាកំណត់ការផ្លាស់ទីនៃប្រជាជនពីភាគខាងជើងទៅភាគខាងត្បូង ដែលក្នុងនោះមានអ្នកគង្វាលអូដ្ឋនៅក្នុងតំបន់ខ្វះដីជាតិនៅភាគខាងត្បូង ប្រជាកសិករមានទីលំនៅអចិន្ត្រៃយ៍នៅភាគកណ្តាល និងចរកជនចិញ្ចឹមគោក្របីនៅភាគខាងត្បូងជាប់នឹងខេត្តបារ៉ែលហ្កាហ្សែល ។ កុលសម្ព័ន្ធហ្វួរស្បែកខ្មៅមានចំនួនជាង៥០ភាគរយនៃប្រជាជនទាំងមូលក្នុងខេត្ត ហេតុនេះឈ្មោះ ដាហ្វួរ (ដា=ផ្ទះ) មានន័យថា ជាផ្ទះរបស់ជាតិពន្ធហ្វួរ ។ ប្រជាជនប្រហែលពាក់កណ្តាលទៀតគឺជាបណ្តុំជាតិពន្ធជាង១៥ក្រុមដែលមានភាសានិងទំនៀមទម្លាប់ដើមផ្សេងៗគ្នា ។ ប្រជាជនទាំងអស់សុទ្ធតែកាន់សាសនាឥស្លាមស៊ុននី ។

ខេត្តនេះជាទីតាំងដើមនៃតំបន់ឯករាជ្យសុលតង់ណេតនៃការីយ៉ារវាងពាក់កណ្តាលសតវត្សរ៍ទី១៧ ហើយនៅឆ្នាំ១៩១៦ ខេត្តនេះត្រូវបានរាប់បញ្ចូលទៅក្នុងប្រទេសស៊ូដង់អង់គ្លូ- អេហ្ស៊ីប ។ ទម្លាប់រស់នៅដោយឯករាជ្យដ៏យូរលង់ពីទីប្រជុំអំណាចនៅតំបន់ជ្រលងទន្លេនីល បានធ្វើឲ្យមានការបែងចែកគ្នារវាងខេត្តដាហ្វួរនិងខេត្តផ្សេងទៀតដែលមានទីតាំងនៅភាគខាងជើងនៃប្រទេសស៊ូដង់ ។ នៅក្នុងឆ្នាំ១៩៥៦ដែលជាឆ្នាំទទួលបានឯករាជ្យរបស់ប្រទេសស៊ូដង់ ខេត្តដាហ្វួបានក្លាយទៅជាមូលដ្ឋាននៃចលនាសាសនាដឹកនាំដោយ ម៉ាឌីស និងជាទីបញ្ជាការនៃគណបក្សនយោបាយរបស់ចលនានេះមានឈ្មោះថា គណបក្ស អ៊ុមម៉ា ។ ពីរលើកនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសស៊ូដង់ (នៅឆ្នាំ១៩៦៨និង១៩៨៦) ខេត្តនេះជាបុកដ៏រឹងមាំនៃអ្នកបោះឆ្នោតគាំទ្រគណបក្សអ៊ុមម៉ាដែលបានផ្តល់ឲ្យគណបក្សនិងមេដឹកនាំគណបក្សនេះ ដាឌីត អាល់ម៉ាឌីនូវជ័យជម្នះនៅក្នុងការបោះឆ្នោត ។

កត្តាពីរទៀតនៅក្នុងនយោបាយរបស់ខេត្តដាហ្វួរបានបង្កឲ្យមានជម្លោះបច្ចុប្បន្ន ។ ទីមួយ ប្រជាជននៅក្នុងខេត្ត ទាំងកសិករអាហ្វ្រិកមានទីលំនៅអចិន្ត្រៃយ៍ ទាំងកុលសម្ព័ន្ធចរកជន គាំទ្រសាសនិកឥស្លាមនៅភាគខាងជើងនៃប្រទេសនៅក្នុងជម្លោះរវាងឥស្លាមសាសនិកទល់នឹងគ្រិស្តសាសនិកនិងពួកអ្នកមានជំនឿទៅលើធម្មជាតិនៅភាគខាងត្បូង ។ ជម្លោះនេះចេះតែកើតមានមិនឈប់ឈរតាំងពីឆ្នាំ១៩៥៥ ។ សមាជិកនៃក្រុមជាតិពន្ធផ្សេងៗនៃខេត្តដាហ្វួរ ដែលភាគច្រើនមានប្រភពមកពីកុលសម្ព័ន្ធអាហ្វ្រិកមានចំនួនពី៤០ទៅ៦០ភាគរយនៃទាហានភាគខាងជើងដែលប្រយុទ្ធទល់នឹងក្រុមអ្នកបះបោរនៅភាគខាងត្បូងរវាងឆ្នាំ១៩៥៥និងឆ្នាំ១៩៧២ និងម្តងទៀតរវាងឆ្នាំ១៩៨៣មកទល់បច្ចុប្បន្ន ។ ហេតុនេះ សាសនាឥស្លាមបានក្លាយទៅជាអត្តសញ្ញាណពិសេសជាងសាសនាដើមដទៃទៀត ។

នៅក្នុងពេលជាមួយគ្នានេះ គម្លាតនយោបាយនៅក្នុងខេត្តដាហ្វួររវាងក្រុមមនុស្សដែលហៅខ្លួនឯងថា "អារ៉ាប់" និងក្រុមដែលហៅខ្លួនឯងថា "អាហ្វ្រិក" មានទំហំកាន់តែធំតាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០មក ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ការប៉ះទង្គិចគ្នាជាញឹកញយរវាងក្រុមជាតិពន្ធបានបញ្ចប់ដោយកិច្ចព្រមព្រៀងសន្តិភាពនៅក្នុងស្រុកនៅឆ្នាំ១៩៨៩ ។ ឆ្នាំ១៩៨៩ជាឆ្នាំដែលរណសិរ្សឥស្លាមជាតិអង្គការឥស្លាមមានគោលនយោបាយនិយមជ្រុលធ្វើរដ្ឋប្រហារដណ្តើមអំណាចនៅទូទាំងប្រទេស ។ ហេតុនេះវាធ្វើឲ្យមានភាពចម្រូងចម្រាស់គ្នារវាងគោលជំហរនយោបាយជាតិនៃកុលសម្ព័ន្ធអាហ្វ្រិកដែលសម្រេបខ្លួន

តាមនយោបាយរបស់ក្រុមអារ៉ាប់នៅជ្រលងទន្លេនីលនៅក្នុងការតស៊ូដើម្បីរក្សាអំណាចដឹកនាំប្រទេសទល់នឹងក្រុមជាតិពន្ធនៅភាគខាងត្បូង និងគោលដៅហរប្រយុទ្ធនៅក្នុងខេត្តដែលក្រុមនេះខំប្រឹងទល់នឹងតំណាងក្នុងស្រុករបស់ក្រុមអារ៉ាប់ខាងលើ ។

នៅក្នុងឆ្នាំ១៩៩១ ដត បូឡាត សកម្មជនហ្វ៊ូរដែលធ្លាប់គាំទ្ររបបដឹកនាំដោយរណសិរ្សឥស្លាមជាតិ បានព្យាយាមរៀបចំការបះបោរប្រឆាំងនឹងអតីតមិត្តរួមអាវុធរបស់ខ្លួនក្រោយពីបានដឹងថា ក្នុងនាមជាជាតិពន្ធអាហ្វ្រិក ខ្លួនមិនមានសមភាពនៅក្នុងសង្គមជាមួយនឹងពួកអារ៉ាប់សូម្បីតែនៅក្នុងគោលការណ៍នៃការប្រកាន់យកសមភាពនៃរដ្ឋាភិបាលឥស្លាមជ្រុលនិយមក៏ដោយ ។ ដត បូឡាត បានទទួលបរាជ័យនិងបាត់បង់ជីវិតនៅក្នុងការព្យាយាមនេះ ប៉ុន្តែការបះបោររបស់គាត់ជាចំណុចរបត់មួយនៅក្នុងគំនិតរបស់ប្រជាជនជាច្រើននៅក្នុងខេត្តដាហ្វ៊ូរ ។

## ការបះបោរនិងការគាបសង្កត់

ជម្លោះបច្ចុប្បន្នបានចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៣ ហើយបានក្លាយយ៉ាងឆាប់រហ័សទៅជាជម្លោះប្រដាប់អាវុធដ៏ឃោរឃៅបំផុតមួយនៅក្នុងទ្វីបអាហ្វ្រិក ។ តាមការសន្និដ្ឋានមនុស្សប្រមាណ៣ម៉ឺននាក់បានស្លាប់បាត់បង់ជីវិត ប្រជាជនចំនួន១លាននាក់បាត់បង់ទីលំនៅ ហើយប្រជាជនចំនួន១២ម៉ឺននាក់បានភៀសខ្លួនទៅក្នុងប្រទេសឆាដដែលមានព្រំប្រទល់ជាប់គ្នា ។ ការប្រយុទ្ធគ្នាគឺផ្ទើឡើងរវាងខ្មាំមអាហ្វ្រិកស្បែកខ្មៅទល់នឹងរដ្ឋាភិបាលខារទុមនិងភ្នាក់ងារនៅក្នុងខេត្តគឺក្រុមជីវពលអារ៉ាប់ ។ មូលហេតុដ៏ធំនៃការបះបោរនេះគឺការយល់ឃើញថាជនជាតិ "អារ៉ាប់" មានឧត្តមភាពនិងវប្បធម៌ប្រសើរជាង រួមទាំងការមិនពេញចិត្តនិងការយល់ថាមានការគាបសង្កត់និងមិនយកចិត្តទុកដាក់ចំពោះជនជាតិ "អាហ្វ្រិក" ។ ខ្មាំមអាហ្វ្រិកចង្អុលបង្ហាញថា ទោះបីដាហ្វ៊ូរជាផ្នែកមួយដែលស្មោះស្ម័គ្រចំពោះជនជាតិឥស្លាមនៅភាគខាងជើង ក៏ដាហ្វ៊ូរមានភាពឱនថយខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធការអប់រំ និងសេដ្ឋកិច្ច ដូចគ្រិស្តសាសនានៅភាគខាងត្បូងដែរ ។

មានចលនាខ្មាំមចំនួនពីរដែលផ្ទើឡើងប្រឆាំងនឹងកងកម្លាំង


វិចិត្រករៈ វ៉ាន់ ណាត អតីតអ្នកទោសនៅមន្ទីរ ស-២១

របស់រដ្ឋាភិបាលទីក្រុងខារទុម ។ ចលនាទីមួយគឺចលនារំដោះជាតិប្រទេសស៊ូដង់ដែលពីដំបូងមានឈ្មោះថាចលនារំដោះដាហ្វ៊ួរ ហើយក្រោយមកបានជ្រើសរើសយកឈ្មោះដែលមានលក្ខណៈជាតិដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួន ។ ចលនានេះផ្តែកសំខាន់ទៅលើកុលសម្ព័ន្ធហ្វ៊ួរនិងកុលសម្ព័ន្ធម៉ាសាលីត ហើយប្រកាន់យកគោលនយោបាយមិននិយមជ្រុល ។ ចលនានេះបានព្យាយាមចងសម្ព័ន្ធភាពជាមួយនឹងបក្សសម្ព័ន្ធប្រជាធិបតេយ្យជាតិដែលមានទីតាំងនៅអាស់ម៉ារ៉ា ហើយបង្រួបបង្រួមរាល់គណបក្សប្រឆាំងទាំងអស់នៅក្នុងប្រទេសស៊ូដង់ ទោះជាបក្សនោះនៅភាគខាងត្បូងឬខាងជើងក្តី ។

ក្រុមបះបោរទីពីរគឺចលនាយុត្តិធម៌និងសមធម៌ដែលផ្អែកសំខាន់ទៅលើកុលសម្ព័ន្ធហ្សាហ្កាវ៉ា ។ ចលនានេះមានទំនាក់ទំនងជាមួយនឹងគណបក្សសមាជជាតិនិយមនៃប្រជាជនដែលដឹកនាំដោយសាសនិកឥស្លាមដ៏ល្បីឈ្មោះមួយរូបគឺ ហាស់សាន់ អាល់ទូរ៉ាប៊ី ដែលបច្ចុប្បន្ននេះបានផ្តាច់ទំនាក់ទំនងជាមួយនឹងសមាជិកនៃបក្សរណសិរ្សជាតិឥស្លាមដែលធ្លាប់គាំទ្រគាត់ ។ (នៅចុងខែមីនា ឆ្នាំ២០០៤ អាជ្ញាធរនៃប្រទេសស៊ូដង់បានចាប់ខ្លួន អាល់ទូរ៉ាប៊ី ពីបទជាប់ពាក់ព័ន្ធក្នុងផែនការផ្តួលរំលំប្រធានាធិបតី) ។ ទំនាក់ទំនងរវាងចលនាយុត្តិធម៌និងសមធម៌និងចលនារំដោះប្រទេសស៊ូដង់គឺជាចំណុចមួយនៃភាពស្រពេចស្រពិលនៅក្នុងជម្លោះដាហ្វ៊ួរ ទោះបីជាអង្គភាពទាំងពីរបានប្រកាសខ្លួនថាមានកិច្ចសហការគ្នាខាងផ្នែកយោធាក៏ដោយ ។ ចលនាយុត្តិធម៌និងសមធម៌មានធនធានហិរញ្ញវត្ថុច្រើនជាងចលនារំដោះជាតិស៊ូដង់ ហើយមានការទទួលស្គាល់ច្រើនជាងនៅក្នុងប្រព័ន្ធសារពត៌មានអន្តរជាតិ ទោះបីជាទំនាក់ទំនងរបស់បក្សជាមួយនឹងក្រុមឥស្លាមជ្រុលនិយមធ្វើឲ្យបក្សនេះមិនសមជាបេក្ខជនសម្រាប់ប្រយុទ្ធនឹងរដ្ឋាភិបាលឥស្លាមជ្រុលនិយមក៏ដោយ ។

ការបះបោរបានចាប់ផ្តើមយឺតៗនៅក្នុងខែកុម្ភៈនិងខែមីនា ឆ្នាំ២០០៣ ហើយឡើងដល់កំពូលនៅថ្ងៃទី២៥ ខែមេសា នៅពេលដែលអ្នកបះបោរនៃចលនារំដោះប្រទេសស៊ូដង់វាយលុកទៅលើក្រុងអាល់ហ្វាហ្ស៊ឺ សម្លាប់ទាហានការពារក្រុងអស់៧២នាក់ កម្ទេចយន្តហោះកំពុងចតនៅលើដី៤គ្រឿង ហើយចាប់ខ្លួនឧត្តម-សេនីយ៍ អ៊ីប្រាហ៊ីម ប៊ូស្រា ដែលជាមេបញ្ជាការទាហានការពារក្រុង ។ ប្រតិកម្មរបស់រដ្ឋាភិបាលខារទុមមានលក្ខណៈចម្រុះ ។ រដ្ឋាភិបាលនេះបានបដិសេធមិនទទួលស្គាល់គថភាពនយោបាយជាក់ស្តែង ហើយបានចោទប្រកាន់ទាំងមិនសមហេតុផលនិងទាំងភិតភ័យថា អ៊ីស្រាអែល សហរដ្ឋអាមេរិក ចលនាតស៊ូនៅភាគខាងត្បូងប្រទេសស៊ូដង់ អេស.ភី.អិល.អេ និងអេរីត្រេ ជាអ្នកបង្កឲ្យមានការបះបោរ ។ រដ្ឋាភិបាលបានហៅអ្នកបះបោរថាជា“ពួកខុទ្ទាមប្រដាប់អាវុធ” ឬជាក្រុមចរកជនដែលប្រកាប់ប្រចាក់គ្នានៅក្នុង“ជម្លោះដ៏យូរអង្វែងអំពីសិទ្ធិកាន់កាប់វាលស្មៅ” ។ ទោះបីជាសម្តីនេះមានភាពពិតខ្លះ ប៉ុន្តែវាមិនមែនជាមូលហេតុពិតប្រាកដនៃជម្លោះនោះទេ ។ ការបំបិទសិទ្ធិផ្នែកសេដ្ឋកិច្ច ជម្លោះវប្បធម៌ និងការមិនអើពើនៅក្នុងការដឹកនាំ ទើបជាមូលហេតុចម្បងនៃជម្លោះ ។

នៅពេលដែលអន្តរាគមន៍របស់ពួកអេស.ភី.អិល.អេ មើលទៅហាក់បីដូចជាមានកម្រិតតិចតួចបំផុត ហើយអន្តរាគមន៍របស់អ៊ីស្រាអែលនិងសហរដ្ឋអាមេរិកឋិតនៅក្នុងការស្រមើស្រមៃ ការចូលរួមរបស់អេរីត្រេត្រូវបានទទួលស្គាល់ទោះជាមានកម្រិតតិចតួចក្តី ។ ជំនួយហិរញ្ញវត្ថុសំខាន់ៗរបស់ចលនារំដោះប្រទេសស៊ូដង់មានប្រភពមកពីវិភាគទានរបស់ជាតិពន្ធហ្វ៊ួរនៅក្រៅប្រទេស រីឯជំនួយរបស់ចលនាយុត្តិធម៌និងសមធម៌ទទួលបានពីអង្គការធំៗនៅបរទេសដែលឋិតក្រោមការបង្គាប់បញ្ជារបស់ ហាស់សាន់ អាល់ទូរ៉ាប៊ី ។ គឺដោយសារប្រភពហិរញ្ញវត្ថុនេះហើយដែលធ្វើឲ្យទាហានបះបោរមានសព្វាវុធទំនើបៗមួយកម្រិត ។

នៅក្នុងអំឡុងខែឧសភានិងខែមិថុនា ឆ្នាំ២០០៣ ការប្រយុទ្ធគ្នាកាន់តែមានភាពស៊ិតស្វាញឡើង ហើយកងកម្លាំងរបស់រដ្ឋាភិបាលបានតបតវិញដោយការវាយប្រហារកាន់តែឃោរឃៅទៅលើប្រជាជនស៊ីវិល ។ យុវជននៃជាតិពន្ធហ្សាហ្កាវ៉ានិងហ្វ៊ួរដែលរស់នៅឆ្ងាយពីខេត្តដាហ្វ៊ួរ បានវិលត្រឡប់មកដាហ្វ៊ួរវិញដើម្បីចូលរួមនៅក្នុងការប្រយុទ្ធ ។ ពួកខុទ្ទាមបានបង្កើតជំរំហ្វឹកហ្វឺននៅលើតំបន់ ជីបែល ម៉ារ៉ា ហើយជីវពលថ្មីៗជាច្រើនរូបបានមកចូលរួម ។ ដោយសារតែមានទ័ពមិនគ្រប់គ្រាន់ (ទ័ពមួយផ្នែកធំគឺជាពួកខាងលិចដែលបានបដិសេធមិនចង់ប្រយុទ្ធជាមួយបងប្អូនឯង) រដ្ឋាភិបាលខារទុមបានប្រើប្រាស់កលយុទ្ធចំនួនបី

ដើម្បីទប់ទល់ជាមួយនឹងកងកម្លាំងខុទ្ទាម÷

១) បង្កើនការវាយប្រហារតាមផ្លូវអាកាស ។ ឧទ្ធម្ភាគចក្រប្រយុទ្ធ អ៊ិមអាយ-២៤ ត្រូវបានប្រើប្រាស់ក្នុងការទម្លាក់គ្រាប់បែក និងបាញ់រះមិនរើសមុខទៅលើជនស៊ីវិល ។ ចំណែកយន្តហោះដឹកជញ្ជូន អេអិន-១២ ត្រូវបានប្រើប្រាស់ដើម្បីទម្លាក់គ្រាប់បែកទៅលើភូមិឋាននិងទីតាំងផ្សេងទៀត ។

២) កេណ្ឌកងជីវពលអារ៉ាប់ដែលប្រយុទ្ធដោយជិះសេះ ឬអូដ្ឋ ។ ជួនកាលក្រុមនេះត្រូវបានជ្រើសរើសមកពីប្រទេសឆាដដែលនៅជិតខាង ហើយមកប្រយុទ្ធដោយសារយល់ថាខ្លួនត្រូវបានរើសអើងខាងផ្នែកវប្បធម៌ និងដោយសង្ឃឹមថាអាចទទួលជយភណ្ឌសង្គ្រាម ។ ក្រុមនេះសម្លាប់ជនស៊ីវិលដោយគ្មានមេត្តា ។

៣) បំផ្លិចបំផ្លាញមធ្យោបាយរស់នៅរបស់ប្រជាជន ។ អណ្តូងត្រូវបានលុបជិត គោក្របីត្រូវសម្លាប់ ឃ្លាំងស្តុកចំណីអាហារត្រូវបានបំផ្លាញចោល ។ ទង្វើនេះបណ្តាលឲ្យជនស៊ីវិលភៀសខ្លួនចេញពីទីលំនៅទៅកាន់តំបន់មាន"សុវត្ថិភាព"នៅក្នុងខេត្តដាហ្វួរ ឬទៅកាន់ប្រទេសឆាដ ។

រដ្ឋាភិបាលរំពឹងថាការធ្វើដូចនេះនឹងជំរុញឲ្យជនស៊ីវិលមានការភិតភ័យនិងលែងគាំទ្រកងកម្លាំងខុទ្ទាមតទៅទៀត ហើយធ្វើឲ្យប្រភពជំនួយភ័ស្តុភារនិងនយោបាយដែលពួកខុទ្ទាមពឹងពាក់ត្រូវរីងស្ងួត ។ គ្មានគោលបំណងណាមួយខាងលើទទួលបានជោគជ័យឡើយ ។ ការព្យាយាមដោះស្រាយជម្លោះនៅលើតុចរចាបានធ្វើឡើងនៅដើមខែកញ្ញា ។ ខាងរដ្ឋាភិបាលដឹកនាំដោយសកម្មជនដ៏ល្បីឈ្មោះមួយរូបនៃរណសិរ្សឥស្លាមជាតិ អាល់គាយិប ម៉ូហាម៉េដ ខៀវ ឈ្មោះក្រៅ "ស៊ីកខា" (មានន័យថា "របារដែក" មានប្រភពមកពីអាវុធដែលគាត់ប្រើប្រាស់) បានចុះហត្ថលេខាលើបទឈប់បាញ់គ្នានៅក្នុងទីក្រុងអាបេឆេនៃប្រទេសឆាដ ។ មិនយូរប៉ុន្មានវាត្រូវបានសម្លឹងឃើញថា អ្វីដែលរដ្ឋាភិបាលចង់បានពិតប្រាកដនោះគឺជាការចុះចាញ់របស់ពួកខុទ្ទាមដោយពុំមានការចរចានយោបាយអ្វីទាំងអស់ ។ នៅពេលដែលការទាមទារឲ្យចុះចាញ់មិនទទួលបានផ្លែផ្កា ប្រតិបត្តិការយោធាដ៏ឃោរឃៅបានចាប់ផ្តើមសាជាថ្មីទៅលើជនស៊ីវិលដូចពេលមុន ។

រដ្ឋាភិបាលខាទុមបានប្រើប្រាស់រាល់ហេតុផលទាំងអស់ដើម្បីទប់ស្កាត់មិនឲ្យជំនួយមនុស្សធម៌អន្តរជាតិធ្លាក់ដល់ដៃប្រជាជននៅក្នុងខេត្តដាហ្វួរទេ ។ ឧទាហរណ៍ នៅថ្ងៃទី១៦ ខែវិច្ឆិកា រដ្ឋាភិបាលនេះបានបដិសេធមិនឲ្យនាំចូលជំនួយម្ហូបអាហាររបស់សហរដ្ឋអាមេរិកសម្រាប់ខេត្តដាហ្វួរ ដោយទាញហេតុផលថាស្រូវសាឡីដែលជាជំនួយនោះមានជាតិគីមីច្រើន ។ ហេតុផលនេះមិនត្រឹមត្រូវទេ ហើយជំនួយម្ហូបអាហារមិនត្រូវបានចែកចាយដល់ប្រជាជនដាហ្វួរឡើយ ។ នៅដើមខែមករា ឆ្នាំ២០០៤ អង្គការក្រៅរដ្ឋាភិបាលស្វីសចំនួនពីរបានរៀបចំសន្និសីទមនុស្សធម៌មួយនៅក្នុងទីក្រុងហ្សឺណែវដើម្បីរៀបចំផែនការផ្តល់ជំនួយដល់ខេត្តដាហ្វួរ ។ ក្រោយពីអង្គការទាំងពីរសន្យាថានឹងបញ្ជូនម្ហូបអាហារទៅដាហ្វួរ រដ្ឋាភិបាលស៊ូដង់បានបដិសេធដោយលើកហេតុផលថាខ្លួនមិនចង់ធ្វើឲ្យជម្លោះនេះរីករាលដាលដល់កម្រិតអន្តរជាតិនោះទេ ហើយសន្និសីទបែបនោះគួរតែត្រូវធ្វើឡើងនៅក្នុងប្រទេសស៊ូដង់ និងរៀបចំដោយរដ្ឋាភិបាលនៃប្រទេសនេះខ្លួនឯង ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៤ ប្រធានាធិបតីស៊ូដង់ អូម៉ា អេលបេសៀ បានប្រកាសថា រដ្ឋាភិបាលលោកបានឈ្នះសង្គ្រាមហើយ ដូច្នេះគួរតែរៀបចំសន្និសីទមួយស្តីអំពីការផ្សះផ្សានយោបាយនៅទីក្រុងខាទុម ។ ក្រុមខុទ្ទាមបានបដិសេធចោលនូវគំនិត "ផ្សះផ្សាដោយគ្មានការចរចា" ហើយបានបាញ់ទម្លាក់ឧទ្ធម្ភាគចក្ររបស់រដ្ឋាភិបាលចំនួនពីរគ្រឿងទៀតនៅថ្ងៃទី១២ ខែកុម្ភៈ ។ នៅក្នុងពេលដែលអត្ថបទនេះកំពុងសរសេរឡើង ជម្លោះមិនត្រឹមតែកំពុងប្រព្រឹត្តទៅនោះទេ ប៉ុន្តែថែមទាំងមានសភាពកាន់តែធ្ងន់ធ្ងរឡើងថែមទៀត ដោយសារតែមានការបាត់បង់ជីវិតមនុស្សជាច្រើន ជាពិសេសជនស៊ីវិល ។

## ផលប៉ះពាល់នៃជម្លោះ

ប្រទេសទីមួយដែលទទួលផលប៉ះពាល់ពីវិបត្តិនៅដាហ្វួរគឺប្រទេសឆាដ ប៉ុន្តែផលប៉ះពាល់ធំជាងគេមិនមែនជារឿងមនុស្សធម៌ទេទោះបីជាមានបញ្ហាធំធេងទាក់ទងទៅនឹងជនភៀសខ្លួនក៏ដោយ ។ ផលប៉ះពាល់ចម្បងនោះគឺទៅលើផ្នែកនយោបាយ ។ ប្រធានាធិបតីអ៊ីឌ្រីស ដឺប៊ី មានប្រភពមកពីជាតិពន្ធុប៊ីឌេ ។ ប៊ីឌេយ៉ាត់ ជាកុលសម្ព័ន្ធមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជាតិពន្ធុហ្សាហ្គាវ៉ា និង គេប៊ូ ដែលរស់នៅតាមបណ្តោយព្រំដែនប្រទេស

ស៊ូដង់និងប្រទេសឆាដ ។ ក្រុមជាតិពន្ធខាងលើ ជាពិសេសគឺក្រុមហ្សាហ្កាវ៉ា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមបះបោរនៅដាហ្វ៊ូរ ខណៈដែលប្រធានាធិបតី ដឺប៊ី សហការយ៉ាងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាលទីក្រុងខាទុមដែលបានជួយខ្លួនឲ្យកាន់កាប់ប្រទេសនៅក្នុងខែធ្នូ ឆ្នាំ១៩៩០ ។ ក្នុងពេលជាមួយគ្នានេះ ប្រធានាធិបតី ដឺប៊ី ពឹងពាក់យ៉ាងខ្លាំងទៅលើជាតិពន្ធហ្សាហ្កាវ៉ា និង ប៊ីដាយ៉ាត់ ដើម្បីរក្សាការកាន់កាប់វាលអណ្តូងប្រេងនៅភាគខាងត្បូងប្រទេសឆាដ ។

ប្រទេសឆាដភាគខាងត្បូងដែលមានជាតិពន្ធនិងសាសនាខុសគ្នាពីភាគខាងជើង គឺជាទីតាំងដែលធ្លាប់មានការបះបោរកើតឡើងជាញឹកញយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ ។ ការរក្សាសម្ព័ន្ធភាពជាមួយនឹងជាតិពន្ធផ្តល់នូវការធានារ៉ាប់រងដល់ប្រធានាធិបតី ដឺប៊ី ទល់នឹងការគំរាមកំហែងទៅលើអណ្តូងប្រេងនៅភាគខាងត្បូង ។ ក៏ប៉ុន្តែ ដោយសារជាតិពន្ធនៅភាគខាងត្បូងគាំទ្រការបះបោររបស់ពួកជាតិពន្ធនៅក្នុងខេត្តដាហ្វ៊ូរ ករណីនេះបានបណ្តាលឲ្យមានការខ្វែងគំនិតគ្នាដ៏ធំមួយរវាងប្រមុខរដ្ឋនិងប្រជាជន ។ ជាលទ្ធផល របនាសម្ព័ន្ធអំណាចនៅទីក្រុងង៉្យាមេណា (ប្រទេសឆាដ) ត្រូវរង្គោះរង្គើ ហើយបែងចែកទៅពីរជាក្រុមមួយក្រុមប្រយុទ្ធទល់នឹងខ្មាំងនៅដាហ្វ៊ូរ (កងទ័ពនៃប្រទេសឆាដធ្លាប់បានធ្វើអន្តរាគមន៍ជាច្រើនលើកនៅក្នុងទឹកដីស៊ូដង់ដើម្បីជួយដល់រដ្ឋាភិបាលស៊ូដង់) និងមួយក្រុមទៀតគាំទ្រដល់ការបះបោរ ។ ស្ថានភាពនេះបានធ្វើឲ្យរដ្ឋាភិបាលប្រទេសឆាដបាត់បង់ប្រជាប្រិយភាព ហើយរដ្ឋាភិបាលទីក្រុងប៉ារីសនិងខាទុមព្រួយបារម្ភថាប្រធានាធិបតី ដេប៊ី អាចធ្លាក់ពីតំណែងដោយសារការខ្វែងគំនិតគ្នានេះ ។

ឥទ្ធិពលទីពីរនៃជម្លោះនៅក្នុងខេត្តដាហ្វ៊ូរទៅលើនយោបាយក្នុងតំបន់គឺជាឥទ្ធិពលនៃអំពើហិង្សាទៅលើកិច្ចចរចាសន្តិភាពនៅក្នុងប្រទេសស៊ូដង់ដែលកំពុងតែធ្វើឡើងនៅក្នុងទីក្រុងណៃរ៉ូប៊ី (ប្រទេសកេនយ៉ា) ។ សំណួរសំខាន់នោះគឺថា តើការចរចាដើម្បីសន្តិភាពសម្រាប់ភាគមួយនៅក្នុងប្រទេសអាចទទួលយកបានដែរឬទេនៅពេលដែលភាគមួយទៀតកំពុងតែឆាបឆេះដោយភ្លើងសង្គ្រាម? កន្លងមកមិនមានចម្លើយទៅនឹងសំណួរនេះទេ ពីព្រោះថាចលនាបះបោរនៅភាគខាងត្បូងនៃប្រទេសស៊ូដង់ (អេស.ភី.អិល.អេ) ដែលបានប្រយុទ្ធជាមួយនឹងរដ្ឋាភិបាលទីក្រុងខាទុមអស់រយៈពេលជាង២០ឆ្នាំមកហើយនោះ ចង់បានសន្តិភាពដូចរដ្ឋាភិបាលដែរ (ទោះជារដ្ឋាភិបាលនេះមិនចង់បានសន្តិភាពពិតប្រាកដក៏ដោយ) ។ ក្រោយពីបានធ្វើសង្គ្រាមជាយូរមកហើយ ចលនាបះបោរនៅភាគខាងត្បូងបានចុះថយធនធាន ហើយរំពឹងថាសន្តិភាពប្រភេទណាមួយ ទោះបីជាមិនល្អក៏ដោយ នឹងធ្វើឲ្យចលនានោះមានជំហរកាន់តែរឹងមាំឡើងនៅក្នុងថ្ងៃអនាគត ។ ចំណែករដ្ឋាភិបាលខាទុមមិនមានបញ្ហាផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសទេ ប៉ុន្តែត្រូវការសន្តិភាពជានិមិត្តរូបមួយដើម្បីរក្សាអំណាចនយោបាយនៅភាគខាងជើងដែលមានការគាំទ្រតិចតួចតាំងតែពីបានកាន់កាប់ប្រទេសនៅក្នុងឆ្នាំ១៩៨៩មក ។ ក្រៅពីតម្រូវការចង់បានសន្តិភាពខាងលើ នៅមានចំណុចរួមតូចៗផ្សេងទៀតរវាងភាគីទាំងពីរ ។

ជម្លោះនៅក្នុងខេត្តដាហ្វ៊ូរបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើទំនាក់ទំនងរវាងភាគខាងជើងនិងភាគខាងត្បូង ។ ក្រុមអេស.ភី.អិល.អេ បានយល់ព្រមមិននិយាយអំពីវិបត្តិនៅដាហ្វ៊ូរនៅលើតុចរចា ចំណែករដ្ឋាភិបាលខាទុមកំពុងតែព្យាយាមពន្យារពេលការចុះហត្ថលេខាទៅលើរាល់ការព្រមព្រៀងជាមួយនឹងភាគីខាងត្បូងឲ្យបានយូរល្មមដើម្បីវាយកម្ទេចការបះបោរនៅភាគខាងលិចទាំងស្រុង ។ អ្នកសង្កេតការណ៍មួយចំនួនបានទស្សន៍ទាយថារដ្ឋាភិបាលខាទុមអាចចុះហត្ថលេខាយ៉ាងឆាប់រហ័សដើម្បីដកទ័ពចំនួន៧ម៉ឺននាក់នៅភាគខាងត្បូងទៅវាយនៅភាគខាងលិចវិញ ។ ក៏ប៉ុន្តែ ទាហានទាំងនេះភាគច្រើនមានប្រភពមកពីខេត្តដាហ្វ៊ូរ ហើយអាចរត់ចោលជួរប្រសិនបើត្រូវបញ្ជូនឲ្យទៅប្រយុទ្ធជាមួយនឹងបងប្អូនឯងនៅដាហ្វ៊ូរ ។ ហេតុនេះរដ្ឋាភិបាលខាទុមបានពន្យារពេលចុះហត្ថលេខា ទោះបីជាមានសម្ពាធពីសហរដ្ឋអាមេរិកឲ្យមានការព្រមព្រៀងគ្នាមុនបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកនៅខែវិច្ឆិកា ឆ្នាំ២០០៤ ក៏ដោយ ។ (ពួកអ្នកគាំទ្រផ្នែកសាសនារបស់ប្រធានាធិបតី ប៊ូស ចង់ឲ្យមានកិច្ចព្រមព្រៀងដើម្បី“ការពារគ្រិស្តសាសនិក” នៅក្នុងប្រទេសស៊ូដង់) ។

# សុន្ទរកថារបស់ឯកឧត្តម កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៤ នៅក្នុងទិវាអន្តរជាតិរំឭកដល់ អំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាឆ្នាំ១៩៩៤

*អគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់ផែនការដើម្បីការពារមិនឲ្យមានអំពើប្រល័យពូជសាសន៍តាមរយៈប្រព័ន្ធអង្គការសហប្រជាជាតិ នៅក្នុងសុន្ទរកថាទៅកាន់គណៈកម្មការសិទ្ធិមនុស្ស ។ សុន្ទរកថានេះត្រូវបានធ្វើឡើងក្រោយពេលដែលអង្គប្រជុំទាំងមូលបានគោរពវិញ្ញាណក្ខន្ធជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាដោយស្ងៀមស្ងាត់រយៈពេលពីរនាទី ។*


ឯកឧត្តម កូហ្វី អាណាន់

«ខ្ញុំសប្បាយចិត្តណាស់ដែលយើងទាំងអស់គ្នាបានស្ងឹងស្ងាធអស់រយៈពេលពីរនាទី ។ យើងមិនត្រូវភ្លេចជាដាច់ខាតនូវបរាជ័យរួមគ្នារបស់យើងក្នុងការការពារបុរស ស្ត្រី និងកុមារគ្មានកំហុស យ៉ាងហោចណាស់៨សែននាក់ដែលបានបាត់បង់ជីវិតនៅក្នុងប្រទេសរ៉្វាន់ដាកាលពី១០ឆ្នាំមុន ។ ឧក្រិដ្ឋកម្មនេះមិនអាចត្រឡប់ក្រោយវិញបាន ហើយបរាជ័យរបស់យើងក៏មិនអាចកែកុនបានដែរ ។ មនុស្សដែលស្លាប់ហើយមិនអាចរស់ឡើងវិញទេ ។ ហេតុនេះតើយើងត្រូវធ្វើយ៉ាងដូចម្តេច?

ដំបូង យើងត្រូវទទួលស្គាល់កំហុសរបស់យើងដែលមិនបានចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីការពារឬបញ្ឈប់អំពើប្រល័យពូជសាសន៍ ។ ទាំងលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ទាំងក្រុមប្រឹក្សាសន្តិសុខ ទាំងរដ្ឋជាសមាជិក ទាំងសារពត៌មានអន្តរជាតិ សុទ្ធតែពុំបានចាប់អារម្មណ៍ទៅលើសញ្ញាដែលបញ្ជាក់ពីការមកដល់នៃមហន្តរាយ ។ លើសពីនេះ យើងថែមទាំងមិនបានចាត់វិធានការឲ្យបានទាន់ពេលវេលាទៀត ។

នៅពេលដែលយើងរំឭកដល់ព្រឹត្តិការណ៍នោះហើយសួរថា "ហេតុអ្វីបានជាគ្មាននរណាធ្វើអន្តរាគមន៍?" យើងមិនត្រូវសួរតែចំពោះអង្គការសហប្រជាជាតិឬរដ្ឋជាសមាជិកប៉ុណ្ណោះទេ ។ គ្មាននរណាម្នាក់អាចនិយាយថាមិនមានអំពើប្រល័យពូជសាសន៍កើតឡើងឡើយ ។ រាល់អង្គភាពទាំងអស់ដែលបានរួមចំណែកនៅក្នុងកិច្ចការពិភពលោកនៅក្នុងពេលនោះ គួរតែសួរខ្លួនឯងថា "តើពេលនោះខ្ញុំគួរតែធ្វើអ្វីថែមទៀតទើបល្អ? តើខ្ញុំគួរតែធ្វើយ៉ាងដូចម្តេចនៅពេលក្រោយ? តើនៅពេលនេះខ្ញុំគួរតែធ្វើអ្វី ដើម្បីធានាថាពេលក្រោយមិនកើតមានម្តងទៀត?"

សំណួរទាំងនេះបានគ្របដណ្តប់ទៅលើឧត្តមគតិរបស់ខ្ញុំតាំងតែពីពេលដែលខ្ញុំក្លាយខ្លួនជាអគ្គលេខាធិការអង្គការសហប្រជាជាតិម្ល៉េះ ។ ប្រសិនបើមានកេរដំណែលមួយដែលខ្ញុំនឹងបន្សល់ទុកជូនអ្នកបន្តតំណែងពីខ្ញុំ កេរដំណែលនោះគឺជាអង្គភាពមួយដែលរៀបចំខ្លួនជាស្រេចដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ហើយមានលទ្ធភាពធ្វើសកម្មភាពដាច់ណាត់ដើម្បីបញ្ឈប់អំពើប្រល័យពូជសាសន៍នៅពេលដែលការទប់ស្កាត់បរាជ័យ ។

សកម្មភាពជាច្រើនរបស់ខ្ញុំក្នុងនាមជាអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានធ្វើឡើងដោយប្រកាន់យកគំនិតនេះ ប៉ុន្តែខ្ញុំដឹងថាកិច្ចប្រឹងប្រែងរបស់ខ្ញុំតែម្នាក់ឯងមិនគ្រប់គ្រាន់ទេ ។ អំពើប្រល័យពូជសាសន៍នៅតែអាចកើតឡើងគួរឲ្យព្រួយបារម្ភ ។ ហេតុនេះ ជាតំណាងឲ្យប្ជុនីយកិច្ចដ៏សមរម្យតែមួយគត់ដែលអង្គការសហប្រជាជាតិអាចផ្តល់ទៅឲ្យជនទាំងឡាយដែលបានបាត់បង់ជីវិតដោយសារកង្វះវិធានការរបស់

អង្គការសហប្រជាជាតិ ហើយដូចដែលបានដាក់ស្នើនៅឆ្នាំ ១៩៩៩ ដោយក្រុមស៊ើបអង្កេតឯករាជ្យមួយទៅលើទង្វើរបស់អង្គការសហប្រជាជាតិចំពោះអំពើប្រល័យពូជសាសន៍នៅរវ៉ាន់ដា ថ្ងៃនេះ ខ្ញុំសូមប្រកាសអំពីផែនការសកម្មភាពដើម្បីការពារអំពើប្រល័យពូជសាសន៍ដោយប្រើប្រាស់ប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល ។

ខ្ញុំសូមសង្ខេបផែនការសកម្មភាពនេះជាប្រាំចំណុចធំៗ÷

ទីមួយ ការពារមិនឲ្យមានជម្លោះប្រដាប់អាវុធ ។ អំពើប្រល័យពូជសាសន៍ស្ទើរតែទាំងអស់បានកើតឡើងក្នុងអំឡុងពេលមានសង្គ្រាម ។ នៅក្នុងសង្គ្រាម សូម្បីតែបុគ្គលមួយរូបដែលមើលទៅស្លូតបូត បានចាត់ទុកមនុស្សដូចគ្នាជាសត្រូធាតុ ហើយបញ្ឈប់ជាបណ្ដោះអាសន្ននូវការគោរពសីលធម៌សង្គមដែលហាមប្រាមមិនឲ្យមានការសម្លាប់ជីវិតមនុស្សដោយចេតនា ។ នៅស្ទើរគ្រប់ករណីទាំងអស់ បុគ្គលប្រភេទនេះទទួលស្គាល់ថាជនស៊ីវិលអាចត្រូវបានសម្លាប់ឬធ្វើឲ្យឈឺចាប់ ទោះបីជាមានការព្យាយាមមិនឲ្យមាន«ការខូចខាតដោយចេតនា»ក៏ដោយ ។ លុះត្រាតែយើងមានការប្រុងប្រយ័ត្នណាស់ ។ ផ្នត់គំនិតខាងលើអាចជាចំណុចចាប់ផ្ដើមនៃការធ្លាក់ចុះយ៉ាងលឿនទៅក្នុងពិភពចម្លែកមួយដែលសហគមន៍មួយទាំងមូលត្រូវបានចាត់ទុកថាជាសត្រូវហើយជីវិតរបស់សមាជិកសហគមន៍ត្រូវបានចាត់ទុកថាគ្មានន័យអ្វីទាំងអស់ ។ ចេញពីចំណុចនេះតែមួយជំហានទៀតនឹងទៅដល់ដំណាក់កាលនៃការលុបបំបាត់ចោលជាក់ស្ដែងនិងដោយចេតនានូវសហគមន៍ទាំងមូល ឬអាចនិយាយម៉្យាងទៀតថាមួយជំហានឆ្ពោះទៅកាន់អំពើប្រល័យពូជសាសន៍ ។ ហេតុនេះមធ្យោបាយដ៏ល្អបំផុតដើម្បីកាត់បន្ថយឱកាសដែលអំពើប្រល័យពូជសាសន៍អាចកើតមានគឺត្រូវវិភាគទៅលើមូលហេតុនៃជម្លោះប្រដាប់អាវុធ ។

ចំណុចទីមួយនេះនឹងគាំទ្រហើយពង្រីកបន្ថែមនូវសំណើដែលបានរៀបរាប់ជាស្រេចនៅក្នុងរបាយការណ៍របស់ខ្ញុំអំពីការការពារមិនឲ្យមានជម្លោះប្រដាប់អាវុធ ដែលបានទទួលគាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាសន្តិសុខនិងមហាសន្និបាតទាំងមូល ។

យើងត្រូវតែជួយប្រទេសទាំងឡាយណាដែលប្រឹងប្រែងទប់ស្កាត់ជម្លោះក្នុងស្រុក ។ យើងត្រូវចាត់វិធានការបន្ថែមទៀតនៅក្នុងកម្រិតតំបន់ដើម្បីការពារជម្លោះកុំឲ្យសាយភាយពីប្រទេសមួយទៅប្រទេសមួយទៀត ។ យើងត្រូវផ្ដល់ការយកចិត្តទុកដាក់កាន់តែខ្ពស់ទៅលើបញ្ហាបរិស្ថាននិងភាពតានតឹងទាក់ទងទៅនឹងការប្រកួតប្រជែងគ្នាដណ្ដើមយកធនធានធម្មជាតិ ។ យើងត្រូវសហការគ្នាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ សង្គមស៊ីវិល និងស្ថាប័នឯកជន ដើម្បីធានាថាក្មេងជំនាន់ក្រោយមានឱកាសកសាងអនាគតភ្លឺស្វាងតាមរយៈការអប់រំនិងការធ្វើការងារសុចរិត ។ ការអប់រំនឹងអាចការពារពួកគេមិនឲ្យចូលរួមនៅក្នុងក្រុមជនពាលនិងជីវពលប្រព្រឹត្តអំពើទុច្ចរិតបានដោយងាយ ។ យើងត្រូវការពារសិទ្ធិរបស់ក្រុមមនុស្សភាគតិច ពីព្រោះក្រុមជនភាគតិចតែងតែជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។

តាមរយៈមធ្យោបាយទាំងនេះនិងមធ្យោបាយផ្សេងទៀត យើងត្រូវតែវែកញែកទៅលើឫសគល់នៃអំពើហិង្សានិងអំពើប្រល័យពូជសាសន៍ នោះគឺការស្អប់ខ្ពើមគ្នា ការមិនចេះអត់ធ្មត់រួមរស់ជាមួយគ្នា ការប្រកាន់ពូជសាសន៍ ការប្រើប្រាស់អំណាចផ្ដាច់ការ និងការប្រើប្រាស់ជាសាធារណៈនូវភាសាបន្ថោកតម្លៃមនុស្ស ។ ខ្ញុំនឹងធ្វើរបាយការណ៍ពិស្ដារមួយជូនមហាសន្និបាតនាចុងឆ្នាំនេះ ។

ទីពីរ ការការពារជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ ។ នៅពេលដែលយើងបរាជ័យក្នុងទប់ស្កាត់មិនឲ្យមានជម្លោះ អាទិភាពចម្បងទីមួយរបស់យើងគឺការពារជនស៊ីវិល ។ ភាគីចូលរួមនៅក្នុងជម្លោះ ទាំងភាគីរដ្ឋ ទាំងភាគីមិនមែនរដ្ឋ ចាំបាច់ត្រូវទទួលការក្រើនរំឭកជាប្រចាំនូវការទទួលខុសត្រូវរបស់ខ្លួននៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិដើម្បីការពារជនស៊ីវិលពីអំពើហិង្សា ។ សំណើនេះត្រូវបានទទួលយកដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយអង្គការសហប្រជាជាតិកំពុងតែពិចារណាទៅលើវិធានការដើម្បីការពារជនស៊ីវិល ។ ក៏ប៉ុន្តែការយកផែនការនេះទៅអនុវត្តជាក់ស្ដែងឲ្យចេញជាលទ្ធផលនឹងមិនងាយស្រួលនោះទេ ។ នៅក្នុងជម្លោះជាច្រើនយើងឃើញថា ជនស៊ីវិលរួមទាំងស្ត្រីនិងកុមារមិនមែនគ្រាន់តែ“ជុំងខ្លួននៅ

ក្រោមគ្រាប់ផ្លោង» ប៉ុណ្ណោះទេ ប៉ុន្តែបានក្លាយទៅជាជនរងគ្រោះដោយផ្ទាល់នៃអំពើហិង្សានិងការរំលោភផ្លូវភេទនៅពេលដែលសង្គ្រាមត្រូវបានបញ្ឆេះឡើងប្រឆាំងនឹងសង្គមទាំងមូល ។

នៅទីណាដែលជនស៊ីវិលត្រូវបានជ្រើសជាគោលដៅនៃអំពើហិង្សាដោយសារអ្នកទាំងនោះជាផ្នែកមួយនៃសហគមន៍ណាមួយ យើងគួររំពឹងថាមានអំពើប្រល័យពូជសាសន៍ហៀបនឹងកើតឡើងហើយ ។ យើងមិនអាចធ្វើជាខ្វាក់មើលមិនឃើញការវិវត្តន៍ដ៏គ្រៀមក្រំពីដំណាក់កាលមួយទៅដំណាក់មួយឡើយ ។ យើងក៏មិនត្រូវសង្ឃឹមដែរថា ការអន្តរាគមន៍ឲ្យបញ្ឈប់អំពើហិង្សាដោយប្រើហេតុផលសីលធម៌ឬមេត្តាធម៌នឹងមានឥទ្ធិពលទៅលើក្រុមមនុស្សដែលបានជ្រើសយកការកាប់សម្លាប់ដោយចេតនានិងបណ្តេញប្រជាជនចេញពីទឹកដីមួយទៅទឹកដីមួយទៀត ។

នេះគឺជាមូលហេតុដែលបច្ចុប្បន្ននេះភ្នាក់ងាររក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិមិនត្រឹមតែត្រូវបានដាក់កំហិតឲ្យប្រើប្រាស់អាវុធសម្រាប់តែការការពារខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានអំណាចធ្វើដូច្នោះដើម្បីបំពេញភារកិច្ចរបស់ខ្លួន ហើយភារកិច្ចនោះតែងតែរាប់បញ្ចូលនូវការការពារជនស៊ីវិលដែលកំពុងទទួលរងការគំរាមកំហែងពីអំពើហិង្សា ។

ឧទាហរណ៍ជាក់ស្តែងមួយគឺខេត្តអ៊ីតួរីនៅប្រទេសកុងហ្គោ ។ ខេត្តនេះជាកន្លែងដែលជម្លោះរវាងជាតិពន្ធច្រើនអាចរាលដាលទៅជាអំពើប្រល័យពូជសាសន៍ ។ កាលពីឆ្នាំមុនស្ថានការណ៍នៅទីនោះត្រូវបានធ្វើឲ្យមានស្ថិរភាពដោយការធ្វើអន្តរាគមន៍យ៉ាងទាន់ពេលវេលាពីសហភាពអឺរ៉ុបអនុញ្ញាតដោយក្រុមប្រឹក្សាសន្តិសុខ ។ សព្វថ្ងៃ កងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិកំពុងតែទប់ស្កាត់មិនឲ្យកងជីវពលក្នុងស្រុកធ្វើអ្វីតាមទំនើងចិត្ត ។

ក៏ប៉ុន្តែ ស្ថានការណ៍នៅតែមិនច្បាស់លាស់ ហើយក៏មិនមែនទើបតែកើតឡើងនៅក្នុងប្រទេសកុងហ្គោដែរ ។ ផែនការទីពីររបស់យើងទាមទារឲ្យលេខាធិការដ្ឋាននិងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិរក្សាសិទ្ធិអំណាចនិងធនធាននៃរាល់កងរក្សាសន្តិភាពឲ្យឋិតនៅក្រោមការត្រួតពិនិត្យជាប់ជានិច្ច ជាពិសេសដោយមានការយកចិត្តទុកដាក់ខ្ពស់ចំពោះអំពើប្រល័យពូជសាសន៍ ហើយឲ្យក្រុមប្រឹក្សាសន្តិសុខរៀបចំខ្លួនជាស្រេចដើម្បីផ្តល់ជំនួយទាន់ពេលវេលា ។

ទីបី បញ្ចប់វប្បធម៌នៃការរួចទោស ។ ប្រសិនបើបុគ្គលដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ត្រូវបានបណ្តែតបណ្តោយឲ្យមានសេរីភាពនៅក្រៅច្បាប់ យើងមានក្តីសង្ឃឹមតិចតួចណាស់ថានឹងអាចការពារមិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងបាន ឬធ្វើឲ្យជនរងគ្រោះដែលរស់នៅដោយក្តីបារម្ភចំពោះការកើតឡើងសាជាថ្មីនៃអំពើប្រល័យពូជសាសន៍ធូរស្បើយចិត្ត ។ ហេតុនេះ យើងចាំបាច់ត្រូវបង្កើតប្រព័ន្ធតុលាការដ៏រឹងមាំមួយទាំងលក្ខណៈជាតិនិងអន្តរជាតិ ដើម្បីធានាថានៅក្នុងថ្ងៃអនាគតប្រជាជននឹងមិនឃើញការរួចទោសសម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍តទៅទៀតទេ ។

ដោយដើរទន្ទឹមនឹងប្រព័ន្ធយុត្តិធម៌នៃប្រទេសរ៉្វាន់ដាដែលបានកាត់ទោសបុគ្គលជាច្រើនដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានដាក់ចេញនូវសាលក្រមជាប្រវត្តិសាស្ត្រដែលជាសារគ្រើនរំឭកមួយចំពោះជនទាំងឡាយដែលកំពុងតែរៀបចំគម្រោងប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសផ្សេងទៀត ។

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាគឺជាតុលាការអន្តរជាតិទីមួយហើយដែលបានកាត់ទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍ ជាតុលាការទីមួយដែលបានដាក់អតីតប្រមុខរដ្ឋាភិបាលឲ្យទទួលខុសត្រូវពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ជាតុលាការទីមួយដែលបានសម្រេចថាការរំលោភផ្លូវភេទជាទង្វើមួយនៃអំពើប្រល័យពូជសាសន៍ ហើយជាតុលាការទីមួយដែលរកឃើញថាអ្នកសារព័ត៌មានមានទោសពីបទប្រល័យពូជសាសន៍ដោយបានញុះញង់ប្រជាជនឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

ផែនការទីបីនេះទាមទារឲ្យមានការត្រួតពិនិត្យឡើងវិញទៅលើការងាររបស់តុលាការរ៉្វាន់ដានិងតុលាការផ្សេងទៀត ទាំងតុលាការជាតិនិងអន្តរជាតិ ក្នុងការដាក់ទណ្ឌកម្មនិងបង្ក្រាបការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដើម្បីឲ្យយើងអាចរៀនសូត្រសម្រាប់អនាគត ។ វាទាមទារឲ្យមានការយកចិត្តទុកដាក់ទៅលើប្រទេសដែលបានឆ្លងកាត់ជម្លោះឬនឹងមានជម្លោះ ។ ផែនការនេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងជាច្រើនថែមទៀត

ដើម្បីជំរុញដល់ការផ្ដល់សច្ចានុម័តទៅឲ្យលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ឲ្យបានទូលំទូលាយថែមទៀត ដើម្បីធ្វើឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិអាចដោះស្រាយយ៉ាងមានប្រសិទ្ធភាពនូវបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ នៅពេលណាដែលតុលាការជាតិមិនមានលទ្ធភាពឬខ្វះឆន្ទៈក្នុងការកាត់ក្ដី ។

ទីបួន ការប្រកាសអាសន្នទាន់ពេលវេលានិងច្បាស់លាស់ ។ មូលហេតុមួយនៃបរាជ័យរបស់យើងនៅក្នុងប្រទេសរ៉្វាន់ដាគឺ យើងមិនបានទទួលស្គាល់ជាមុនថា អំពើប្រល័យពូជសាសន៍អាចនឹងកើតមានឡើង ។ នៅពេលដែលវាបានចាប់ផ្ដើមរួចទៅហើយ យើងមិនអាចពន្យល់ខ្លួនឯងឲ្យទាន់ពេលវេលាថា នោះជាអំពើប្រល័យពូជសាសន៍ពិតប្រាកដ ឬមិនបានហៅអំពើនោះថាជាអំពើប្រល័យពូជសាសន៍ ។

ប្រសិនបើយើងពិតជាមានបំណងការពារមិនឲ្យមាន និងចង់បញ្ឈប់អំពើប្រល័យពូជសាសន៍នៅថ្ងៃមុខ យើងមិនត្រូវរារាំងដោយហេតុផលច្បាប់ថា តើអំពើឃោរឃៅមួយបំពេញតាមនិយមន័យនៃអំពើប្រល័យពូជសាសន៍ទេ ។ ទម្រាំតែយើងដឹងច្បាស់ វាអាចហួសពេលនឹងធ្វើសកម្មភាពទៅហើយ ។ យើងត្រូវតែខំប្រឹងកត់សម្គាល់អំពីសញ្ញានៃអំពើប្រល័យពូជសាសន៍ដែលហៀបនឹងកើតឡើងដើម្បីឲ្យយើងអាចធ្វើសកម្មភាពទប់ស្កាត់ទាន់ពេលវេលា ។

នៅក្នុងចំណុចនេះ សង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ ។ ជាទូទៅ ដោយសាររបាយការណ៍របស់សង្គមស៊ីវិលនេះហើយដែលដាស់តឿនយើងឲ្យបានដឹងអំពីការមកដល់នៃមហន្តរាយ ប៉ុន្តែរបាយការណ៍ទាំងនេះមិនត្រូវបានអើពើជាច្រើនលើកច្រើនសា ។

ប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិក៏មានការទទួលខុសត្រូវពិសេសដែរ ។ តាមរយៈអ្នកសង្កេតការណ៍ពិសេសរបស់គណៈកម្មការសិទ្ធិមនុស្ស អ្នកជំនាញការឯករាជ្យនិងក្រុមការងារក៏ដូចជាអង្គភាពដែលបង្កើតឡើងដោយសន្ធិសញ្ញានិងការិយាល័យឧត្ដមស្នងការ គួរតែរៀបចំខ្លួនជាស្រេចដើម្បីប្រកាសអាសន្ន ។ តាមការពិត គណៈកម្មការសិទ្ធិមនុស្សបានផ្ដល់របាយការណ៍បញ្ជាក់អំពីសញ្ញានៃអំពើប្រល័យពូជសាសន៍ជាច្រើនលើកនៅក្នុងប្រទេសរ៉្វាន់ដារយៈពេលមួយឆ្នាំមុនពេលអំពើនេះបានកើតឡើង ប៉ុន្តែគ្មាននរណាម្នាក់ចាប់អារម្មណ៍ ។

ចំណុចសំខាន់គឺត្រូវប្រមូលពត៌មានទាំងអស់មកផ្គុំគ្នា ហើយវិភាគឲ្យយល់អំពីចំណុចពិស្ដារនៃស្ថានភាពជាក់ស្ដែង ដើម្បីឲ្យយើងអាចចាត់វិធានការសមស្របទៅតាមហេតុការណ៍ ។ បច្ចុប្បន្ននៅមានចន្លោះប្រហោងខ្វះនៅក្នុងការវិភាគនិងគ្រប់គ្រងពត៌មានដែលយើងមាន ។ ផែនការទីបួននេះមានបំណងកែប្រែនិងបំពេញចន្លោះប្រហោងនេះ ។

ការសម្រេចចិត្តមួយដែលខ្ញុំបានធ្វើគឺតែងតាំងទីប្រឹក្សាពិសេសមួយរូបសម្រាប់ការពារអំពើប្រល័យពូជសាសន៍ដែលនឹងរាយការណ៍តាមរយៈខ្ញុំទៅក្រុមប្រឹក្សាសន្តិសុខនិងមហាសន្និបាតក៏ដូចជាទៅគណៈកម្មការសិទ្ធិមនុស្ស ។

កាតព្វកិច្ចរបស់ទីប្រឹក្សារូបនេះនឹងមិនគ្រាន់តែគ្របដណ្ដប់ទៅលើអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំ ព្រមទាំងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀតដូចជាការកាប់សម្លាប់ជាតិពន្ធជាដើម ។ ទីប្រឹក្សារូបនេះនឹងមានតួនាទី ទីមួយសហការយ៉ាងជិតស្និទ្ធជាមួយឧត្ដមស្នងការដើម្បីប្រមូលពត៌មានអំពីស្ថានការណ៍ជាក់ស្ដែង ឬការគំរាមកំហែងពីអំពើប្រល័យពូជសាសន៍ និងទំនាក់ទំនងរបស់ចំណុចទាំងនេះទៅនឹងសន្តិភាពនិងសន្តិសុខអន្តរជាតិ ។ ទីពីរ ដើរតួជាយន្តការប្រកាសអាសន្នទៅកាន់ក្រុមប្រឹក្សាសន្តិសុខនិងផ្នែកផ្សេងទៀតនៃអង្គការសហប្រជាជាតិ ។ ទីបីផ្ដល់អនុសាសន៍ទៅកាន់ក្រុមប្រឹក្សាសន្តិសុខអំពីវិធានការដែលត្រូវចាត់ដើម្បីទប់ស្កាត់ឬបញ្ឈប់អំពើប្រល័យពូជសាសន៍ ។

ចំណុចទីប្រាំនៃផែនការសកម្មភាពគឺទាមទារឲ្យមានអន្តរាគមន៍ឆាប់រហ័សនិងមានប្រសិទ្ធភាពក្រោយពីបានដឹងថាអំពើប្រល័យពូជសាសន៍កំពុងតែប្រព្រឹត្តឡើង ឬហៀបនឹងកើតឡើងនៅពេលដែលការទប់ស្កាត់របស់យើងទទួលបរាជ័យ ។ ជាច្រើនលើកច្រើនសា នៅពេលដែលមានការប្រកាសឲ្យដឹងមុនយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ យើងខ្វះឆន្ទៈនយោបាយដើម្បីធ្វើសកម្មភាព ។

ជនទាំងឡាយណាដែលចាប់ផ្ដើមប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ មនុស្សជាតិត្រូវតែឆ្លើយតបវិញដោយចាត់វិធានការដើម្បីការពារខ្លួន ។

ឧបករណ៍របស់មនុស្សជាតិសម្រាប់សម្រេចការងារនេះគឺអង្គការសហប្រជាជាតិ ជាពិសេសគឺក្រុមប្រឹក្សាសន្តិសុខ ។

ខ្ញុំសូមថ្លែងនៅទីនេះឥឡូវនេះថា ខ្ញុំមានការព្រួយបារម្ភជាខ្លាំងដោយសាររបាយការណ៍ដែលបានបញ្ចេញកាលពីសប្តាហ៍មុនដោយអ្នកជំនាញការឯករាជ្យចំនួន៨រូបដែលតែងតាំងដោយគណៈកម្មការសិទ្ធិមនុស្សបង្ហាញថាមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនិងវិបត្តិមនុស្សធម៌ដែលកំពុងតែកើតមាននៅដាហ្វួរប្រទេសស៊ូដង់ ។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៤ អ្នកសម្របសម្រួលជំនួយបន្ទាន់របស់អង្គការសហប្រជាជាតិបានរាយការណ៍ទៅក្រុមប្រឹក្សាសន្តិសុខថា សកម្មភាពដោយចេតនាមួយចំនួនត្រូវបានសង្កេតឃើញថាហាក់ដូចជាធ្វើឡើងដើម្បីសម្រេចគោលដៅជាក់លាក់មួយ នោះគឺការបណ្តេញប្រជាជនចេញពីលំនៅឋានដោយបង្ខំសម្រាប់រយៈពេលយូរដែលអាចហៅបានថាជា“ការបោសសម្អាតជាតិពន្ធុ” ។ ការវាយតម្លៃរបស់អ្នកសម្របសម្រួលរូបនេះគឺផ្អែកទៅលើរបាយការណ៍របស់បុគ្គលិកអន្តរជាតិប្រចាំនៅដាហ្វួរដែលបានឃើញដោយផ្ទាល់នូវអ្វីដែលកំពុងតែកើតឡើងនៅទីនោះ និងពីតំណាងពិសេសសម្រាប់កិច្ចការមនុស្សធម៌របស់ខ្ញុំផ្ទាល់នៅក្នុងប្រទេសស៊ូដង់ ។ របាយការណ៍នេះបានធ្វើឲ្យខ្ញុំព្រួយបារម្ភយ៉ាងខ្លាំង ។ ទោះបីជាស្ថានភាពនៅដាហ្វួរត្រូវគេហៅដូចម្តេចក៏ដោយ ក៏សហគមន៍អន្តរជាតិមិនអាចឈរឱបដៃមើលបានដែរ ។

ដោយមានការអញ្ជើញពីរដ្ឋាភិបាលប្រទេសស៊ូដង់ ខ្ញុំសូមស្នើឲ្យបញ្ជូនក្រុមពិសេសមួយក្រុមធ្វើដំណើរទៅដាហ្វួរដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីទំហំនិងលក្ខណៈនៃវិបត្តិនៅទីនោះ និងដើម្បីស្វែងរកមធ្យោបាយទៅជួបនឹងប្រជាជនដែលត្រូវការជំនួយនិងការការពារ ។ បុគ្គលិកមនុស្សធម៌អន្តរជាតិនិងអ្នកជំនាញការសិទ្ធិមនុស្សគួរតែទទួលបានសិទ្ធិពេញលេញក្នុងការធ្វើដំណើរទៅតំបន់ដាហ្វួរនិងទៅជួបជនរងគ្រោះដោយពុំមានការពន្យារពេលតទៅទៀត ។ ប្រសិនបើសំណើនេះត្រូវបានបដិសេធ សហគមន៍អន្តរជាតិត្រូវតែរៀបចំខ្លួនជាស្រេចដើម្បីចាត់វិធានការឲ្យបានឆាប់រហ័សនិងត្រឹមត្រូវ ។

“វិធានការ”នៅក្នុងស្ថានភាពបែបនេះមានន័យថាជាជំហានមួយសំណុំដែលអាចរាប់បញ្ចូលទាំងការប្រើប្រាស់កម្លាំងទ័ពផងក៏ប៉ុន្តែ ការប្រើប្រាស់កម្លាំងទ័ពគួរតែជាវិធានការចុងក្រោយសម្រាប់ករណីធ្ងន់ធ្ងរ ។ យើងត្រូវការនូវសេចក្តីណែនាំច្បាស់លាស់អំពីវិធីកត់សម្គាល់ករណីធ្ងន់ធ្ងរនិងប្រតិកម្មចំពោះករណីទាំងនោះ ។ សេចក្តីណែនាំបែបនោះនឹងធានាថា យើងគ្មានហេតុផលនឹងធ្វើមិនដឹងមិនឮចំពោះអំពើប្រល័យពូជសាសន៍ដែលកំពុងកើតឡើងឡើយ ។ សេចក្តីណែនាំគួរតែផ្តល់ភាពច្បាស់លាស់ថែមទៀតហើយជួយកាត់បន្ថយការចោទប្រកាន់ថាយកអំពើប្រល័យពូជសាសន៍ជាលេសសម្រាប់បញ្ជូនទ័ព ។

ការព្យាយាមដើម្បីផ្តល់នូវសេចក្តីណែនាំបែបនោះត្រូវបានធ្វើឡើងដោយគណៈកម្មការអន្តរជាតិនៃការធ្វើអន្តរាគមន៍និងអធិបតេយ្យភាពរដ្ឋនៅក្នុងរបាយការណ៍របស់គណៈកម្មការសិទ្ធិមនុស្សអំពីការទទួលខុសត្រូវក្នុងការការពារ ។ គណៈកម្មការសិទ្ធិមនុស្សបានបំពេញការងារគ្រឹះយ៉ាងសំខាន់សម្រាប់“គណៈកម្មការជាន់ខ្ពស់ស្តីអំពីការគំរាមកំហែងបញ្ហាចំពោះមុខនិងការផ្លាស់ប្តូរ” ដែលមិនអាចគេចវេះពីបញ្ហានេះបានឡើយ នៅពេលដែលគណៈកម្មការសិទ្ធិមនុស្សពិចារណាអំពីវិធីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធសន្តិសុខរួមរបស់យើង ។

ខ្ញុំសង្ឃឹមថាអនុសាសន៍របស់គណៈកម្មការសិទ្ធិមនុស្សនឹងបង្កើតឲ្យមានសម្បទាន ហើយខ្ញុំទាមទារឲ្យរដ្ឋជាសមាជិកទាំងអស់ប្រឹងប្រែងដោយស្មោះត្រង់ដើម្បីសម្រេចឲ្យបាននូវសម្បទាននោះ ។

យើងមិនត្រូវរង់ចាំរហូតទាល់តែអំពើប្រល័យពូជសាសន៍កើតឡើងបុកន្លងទៅនោះទេ ។ យើងមិនត្រូវឈរឱបដៃមើលឬមិនរវីរវល់នោះទេ ។

យើងទាំងអស់គ្នាត្រូវទប់ស្កាត់អំពើប្រល័យពូជសាសន៍ឲ្យបាន ។ ទាល់តែធ្វើយ៉ាងនេះទើបយើងអាចគោរពដល់វិញ្ញាណក្ខន្ធជនរងគ្រោះនាថ្ងៃនេះ ។ ទាល់តែធ្វើយ៉ាងនេះទើបយើងអាចជួយសង្គ្រោះជីវិតអ្នកដែលអាចក្លាយទៅជាជនរងគ្រោះនាថ្ងៃស្អែកបាន ។

# ការផ្សះផ្សានៅកម្ពុជា

## មូលន័យសង្ខេប

### I. មូលដ្ឋាន

#### ១) សេចក្តីផ្តើម

*រវាងខែមករានិងខែកញ្ញា ឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទាបស្ទង់មតិមិត្តអ្នកអានទស្សនាវដ្តី«ស្វែងរកការពិត» ជាភាសាខ្មែរ ។ សំណួរទាំង២៧នៅក្នុងកម្រងសំណួរបានសួរអំពីប្រធានបទផ្សេងៗទាក់ទងទៅនឹងយុត្តិធម៌ ការសងសឹក ការទទួលខុសត្រូវ និងការផ្សះផ្សា ពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ឬបក្សកុម្មុយនិស្តកម្ពុជា ក៏ដូចជាការចង់ដឹងពីមតិរិះគន់របស់មិត្តអ្នកអានទស្សនាវដ្តី«ស្វែងរកការពិត» ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយកម្រងសំណួរចំនួន៧០០០ច្បាប់ ហើយទទួលបានចម្លើយមកវិញចំនួន៧១២ច្បាប់ ។ ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែមិថុនា ឆ្នាំ២០០៣ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំពត៌មាននិងដកស្រង់ពត៌មានដែលទទួលបាន ហើយពិនិត្យអំពីភាពត្រឹមត្រូវ រួចបញ្ចូលទិន្នន័យទាំងអស់ទៅក្នុងកំព្យូទ័រ ។ បន្ទាប់មក បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការវិភាគជាបឋមទៅលើទិន្នន័យវិភាគចេញជាក្រាហ្វិក ហើយបកប្រែចម្លើយទាំងអស់ពីភាសាខ្មែរទៅភាសាអង់គ្លេស ។ ការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការបកស្រាយស៊ីជម្រៅត្រូវបានធ្វើឡើងរវាងខែមករានិងខែធ្នូ ឆ្នាំ២០០៣ ។ «ការផ្សះផ្សានៅកម្ពុជា» គឺជាការវិភាគយ៉ាងពិស្តារដោយប្រើប្រាស់គោលការណ៍ច្រើនបែបទៅលើផ្នែកសំខាន់ៗនៃយុត្តិធម៌សម័យអន្តរកាល ដោយមានការសង្កត់ធ្ងន់ទៅលើការផ្សះផ្សានិងរបបខ្មែរក្រហម ។ ការសិក្សានេះបានវិភាគយ៉ាងទូលំទូលាយទៅលើទ្រឹស្តីនិងវិធីសាស្ត្រដែលជាតិទាំងឡាយប្រឈមមុខនឹងកេរដំណែលនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមុននឹងឈានទៅកាន់លទ្ធិប្រជាធិបតេយ្យ ព្រមទាំងផ្តោតអារម្មណ៍ទៅលើជ្រុងមួយនៃស្ថានភាពប្រទេសកម្ពុជា ។ នោះគឺជាចំណុចសំខាន់នៃការសិក្សាដែលជាការវិភាគទៅលើទិន្នន័យដ៏ធំដែលប្រមូលនិងរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈការស្ទាបស្ទង់មតិ ។ ទិន្នន័យនេះផ្តល់នូវចម្លើយកម្ររកបានអំពីអ្វីដែលប្រជាជនយល់ឃើញទាក់ទងទៅនឹងចំណុចជាច្រើននៃការផ្សះផ្សានៅកម្ពុជា ពិសេសអំពីទស្សនៈគួរឲ្យចាប់អារម្មណ៍របស់ប្រជាជនទៅលើប្រភេទនៃជាតិនិងសង្គមដែលពួកគេចង់បាន ។ បន្ថែមទៅលើការស្ទាបស្ទង់មតិអ្នកអានទស្សនាវដ្តី«ស្វែងរកការពិត» គោលគំនិតចំនួនប្រាំពីរដែលបានលេចចេញក្នុងទិន្នន័យ ត្រូវបានវិភាគនៅក្នុងសៀវភៅនេះគឺផលប៉ះពាល់ដោយផ្ទាល់នៃរបបខ្មែរក្រហម ការផ្លាស់ប្តូរគំនិតយោបល់អំពីរបបខ្មែរក្រហម អាកប្បកិរិយាចំពោះរបបខ្មែរក្រហម យន្តការនៃការទទួលខុសត្រូវ ការចាត់ចែងសំណល់ជនរងគ្រោះ ការផ្សព្វផ្សាយឬការអប់រំ និងការផ្សះផ្សានិងបង្រួបបង្រួមជាតិ ។ ក្រៅពីនេះ មិត្តអ្នកអានអាចផ្តល់ជាយោបល់ផ្ទាល់ខ្លួន ។*

#### ២) ការផ្សះផ្សាក្នុងទិដ្ឋភាពទូទៅ

*ការផ្សះផ្សាគឺជាពាក្យដែលត្រូវបានប្រើប្រាស់ជាទូទៅដើម្បីបកស្រាយអំពីការរួបរួមគ្នាឡើងវិញនៃភាគីទាំងឡាយនៅក្នុងវិវាទ និងជាដំណើរការដែលភាគីទាំងអស់បញ្ចប់វិវាទហើយចងគ្នាជាមិត្តវិញ ។ ការផ្សះផ្សាជាការបង្កើតឡើងវិញនូវទំនាក់ទំនងល្អនិងធម្មតាបន្ទាប់ពីការប្រឈមមុខដាក់គ្នា ឬការទទួលស្គាល់នូវអ្វីដែលបានកើតឡើងពីអតីតកាលហើយធ្វើដំណើរទៅមុខដោយគ្មានភាពអវិជ្ជមាននៅក្នុងចិត្ត ។ ប្រសិនបើពាក្យនេះឈរតែឯង វាមិនមែនជាអ្វីដែលមានភាពស្មុគស្មាញប៉ុន្មានទេ ប៉ុន្តែអត្ថន័យរបស់ពាក្យនេះត្រូវបានធ្វើឲ្យកាន់តែស្មុគស្មាញដោយសារមានការចាប់អារម្មណ៍យ៉ាងទូលំទូលាយ តែអាចជ្រុលពេកពីវិស័យសិក្សាធិការ ព្រមទាំងការការពិភាក្សាវែកញែកអំពីអត្ថន័យពិតប្រាកដនៃពាក្យនេះនៅក្នុងបរិបទជាក់លាក់ណាមួយ ។*

*ការផ្សះផ្សានៅក្នុងប្រទេសទាំងឡាយដែលបានប្រឈមមុខ*

ទៅនឹងការផ្លាស់ប្តូរសង្គមនិងនយោបាយ ក្រោយពីរបបគាបសង្កត់មួយបានបញ្ចប់ បានក្លាយទៅជាប្រធានបទសំខាន់នៅក្នុងទំនាក់ទំនងអន្តរជាតិ ការកសាងសន្តិភាពប្រជាធិបតេយ្យភាវូបនីយកម្ម ការដោះស្រាយជម្លោះ និងយុត្តិធម៌សម័យអន្តរកាល ។ គ្មានប្រទេសពីរមានបទពិសោធន៍ដូចគ្នាឡើយ នៅក្នុងការសម្រេចឲ្យបាននូវការផ្សះផ្សាក្រោយជម្លោះ ទោះបីជាមេរៀននិងគំនិតអាចត្រូវបានរៀនសូត្របានយ៉ាងច្បាស់ក្រឡែតពីវិធីដែលប្រទេសមួយបានជ្រើសយកក៏ដោយ ។

ទស្សនៈបុគ្គលអំពីអត្ថន័យនៃពាក្យនេះ អ្វីដែលមនុស្សម្នាក់នៅតាមផ្លូវយល់ឃើញ និងវិធីសម្រេចឲ្យបាននូវការផ្សះផ្សាមិនមែនមានទំនាក់ទំនងទៅនឹងអ្វីដែលរដ្ឋយល់ឃើញនោះទេ ។ នៅកូសូវ៉ូ ការផ្សះផ្សាគឺជាទស្សនៈដែលពោរពេញទៅដោយទំនាស់ដោយសារទំនាក់ទំនងរវាងជាតិពន្ធុ ស៊ែប៊ី និង អាល់បានី នៅតែមានភាពតឹងតែងនិងងាយមានបញ្ហា ។ នៅក្នុងប្រទេសអាហ្សង់ទីន ការផ្សះផ្សាត្រូវបានយល់ថាជា “ពាក្យកាត់ដែលប្រើប្រាស់ដោយអ្នកដែលមិនចង់ឲ្យមានអ្វីចេញជាលទ្ធផល” ។

ពាក្យនេះត្រូវបានជនរងគ្រោះយល់ថា “យើងកំពុងតែត្រូវស្នើសុំឲ្យផ្សះផ្សាជាមួយនឹងអ្នកដែលបានធ្វើទារុណកម្មមកលើយើង ឯអ្នកធ្វើទារុណកម្មត្រូវបានប្រាប់ថាមិនចាំបាច់ធ្វើអ្វីទាំងអស់” ។ អ្នកនៅរស់មួយចំនួនពីរបបអាប៉ាថេតនៅអាហ្វ្រិកខាងត្បូង មានកំហឹងចំពោះប្រទេសរបស់ខ្លួនដែលជ្រើសរើសការផ្សះផ្សាជាការអត់ឱន ។ “ការផ្សះផ្សាគ្រាន់តែជាពាក្យដែលប្រើប្រាស់ដោយមនុស្សមួយចំនួន ប៉ុន្តែវាគ្មានខ្លឹមសារអ្វីទាំងអស់សម្រាប់មនុស្សម្នាក់ដែលសេចក្តីថ្លៃថ្នូររបស់ខ្លួនត្រូវបានដកហូតហើយភាពក្រីក្រគោកយ៉ាកគឺជារបួសមិនងាយជាដែលយាយីព្រលឹងរបស់អ្នកនោះ” ។

មតិទូទៅក្នុងចំណោមប្រជាជនស្បែកខ្មៅនៅអាហ្វ្រិកខាងត្បូងគឺថា ការយកចិត្តទុកដាក់ចំពោះការផ្សះផ្សានិងការអត់ឱនបានបង្ខំឲ្យប្រជាជនទាំងនេះឆ្ពោះទៅរកការបំភ្លេចចោលនិងទទួលស្គាល់នូវអ្វីដែលបានកើតឡើងទាំងបិទភ្នែកមិនដឹង ។

ការព្រួយបារម្ភមួយទៀតគឺថា ទស្សនៈនៃការផ្សះផ្សាត្រូវបាន“កែប្រែឲ្យទៅជាប្រភេទមួយនៃមនោគមវិជ្ជាស្នេហាជាតិ” ហើយពេលខ្លះវាលេចចេញជា“ពាក្យកាត់ប្រើសម្រាប់បង្ខំឲ្យប្រជាជនរណបតាមការដឹកនាំរបស់ពួកអ្នកកាន់អំណាច” ។

តុលាការអន្តច្បាប់មិនទាន់ត្រូវបានប្រើប្រាស់ជាទូទៅជាយន្តការនៃការផ្សះផ្សារវាងសហគមន៍និងសហគមន៍នោះទេ ប៉ុន្តែតុលាការអន្តរជាតិ ដូចជាតុលាការពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉ាវ៉ាន់ដា (បង្កើតឡើងនៅក្រោមជំពូកទី៧នៃធម្មនុញ្ញអង្គការសហប្រជាជាតិជាយន្តការដើម្បីធ្វើឲ្យមានសន្តិភាពនិងស្ថិរភាពអន្តរជាតិឡើងវិញ) មានប្រយោជន៍ច្រើនជាងការរំពឹងទុក ។ យុត្តិធម៌នៅក្នុងរឿងក្តីនីមួយៗត្រូវតែទាមទារឲ្យបាន ប៉ុន្តែអ្នកខ្លះទាញហេតុផលថាតុលាការទាំងនេះត្រូវបានបង្កើតឡើងដើម្បីរួមវិភាគទានដល់ការផ្សះផ្សានៅក្នុងសហគមន៍ដែលបានទទួលការខូចខាត ។ ក៏ប៉ុន្តែការផ្សះផ្សាដែលជាវត្ថុបំណងនៃគោលនយោបាយមានអត្ថន័យផ្សេងទៀតចំពោះគណៈកម្មការស្វែងរកការពិត ។ គណៈកម្មការស្វែងរកការពិតរបស់ប្រទេសអាហ្សង់ទីនជាគណៈកម្មការទីមួយដែលទីបំផុតត្រូវបានស្គាល់ជាទូទៅថាជាគណៈកម្មការស្វែងរក“ការពិត” ដោយសារតែគណៈកម្មការនេះផ្តោតការយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការផ្នែកចិត្តសាស្ត្ររបស់ជនរងគ្រោះក្នុងការចង់ដឹងអំពីវាសនារបស់ជនរងគ្រោះដែល“បាត់ខ្លួន” ។ ហេតុនេះ ការស្រាវជ្រាវរក“ការពិត”ក្លាយទៅជាចំណុចសំខាន់មួយ ។ ក្រោយមកទៀតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សារបស់ប្រទេសឈីលីបង្កើតឡើង៨ឆ្នាំក្រោយប្រទេសអាហ្សង់ទីន (គឺនៅឆ្នាំ១៩៩១) ត្រូវបានប្រគល់តួនាទីឲ្យបកស្រាយពន្យល់អំពី“ការពិត” នៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត...ដើម្បីបង្កឲ្យមានការផ្សះផ្សាជូនដល់ប្រជាជនឈីលីទាំងអស់ ។

បន្ទាប់ពីមានការបង្កើតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង ឥឡូវនេះការផ្សះផ្សាត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាមួយនឹងពាក្យ “យុត្តិធម៌” “សន្តិភាព” និងពាក្យស័ព្ទគួរឲ្យកន្ត្រាក់អារម្មណ៍ចម្លងចេញពីផ្នែកចិត្តសាស្ត្រ និងសាសនា ដូចជា “ការអត់ឱន” “ការស្តាបនាឡើងវិញ” “ការផ្លាស់ប្តូរ” “ការព្យាបាល” “ការបញ្ចប់អតីតកាល” និង “ការរំដោះឲ្យចេញពីអតីតកាល” ជាដើម ។ “ការពិត”ត្រូវបានប្រកាសយ៉ាង

ពេញទំហឹងថាជាវិធីឆ្ពោះទៅការផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង ឯ«ការលើកលែងទោស» គឺជាផ្លូវសម្រាប់អន្តរកាលសន្តិភាពពីរបបអាប៉ាថេតទៅរបបប្រជាធិបតេយ្យពហុបក្ស ។

ទោះបីជាមានព្រឹត្តិការណ៍ដែលមានសារសំខាន់គួរឲ្យចាប់អារម្មណ៍នៅឯគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាក៏ដោយ មិនទាន់មានការយល់ជាទូទៅថាការធ្វើដូចនេះមានន័យដូចម្តេចទេ ឬថាតើការពិតអាចផ្សះផ្សាសង្គមដ៏សែនប្រេះស្រាំមួយតាមវិធីបែបណាដែរ ។ របាយការណ៍របស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបានទទួលស្គាល់ថា ការបកស្រាយខាងលើគឺពោរពេញទៅដោយទំនាស់ ។

ស្ថានការណ៍កាន់តែយ៉ាប់យឺនថែមទៀតនៅពេលដែលប្រើប្រាស់អត្ថន័យច្រើនមកបកស្រាយពាក្យផ្សះផ្សាដោយសារ «មិនមានទស្សនៈដាច់ស្រេចនិងមិនប្រែប្រួល» ។

ថ្វីបើសម្តីនេះមានលក្ខណៈរស់រវើកនិងជាសាធារណៈ គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាដែលជាការដកពិសោធន៍វិសាមញ្ញមួយនៃការជួសជុលផ្នែកសង្គមនយោបាយហាក់មិនទាន់សម្រេចបាននូវបេសកកម្មដ៏សែនលំបាករបស់ខ្លួនក្នុងការផ្សះផ្សាប្រជាជនអាហ្វ្រិកខាងត្បូងនៅឡើយ ។ មេដឹកនាំសាសនា ទូទូទទួលស្គាល់ការពិតថា ការធ្វើដំណើររបស់ប្រទេសអាហ្វ្រិកខាងត្បូងតាមបណ្តោយផ្លូវនៃការផ្សះផ្សាដ៏វែងមិនទាន់បញ្ចប់នៅឡើយទេ ។ ចៅក្រម រីឆាត ហ្គូលស្តូន អតីតរដ្ឋអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉ាន់ដា និងជាចៅក្រមតុលាការកំពូលនៃប្រទេសអាហ្វ្រិកខាងត្បូង បានអះអាងថា ដោយសារការងាររបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា «ប្រជាជនស្បែកសនៃអាហ្វ្រិកខាងត្បូងមួយចំនួនធំដែលសុទ្ធតែបានទទួលផលប្រយោជន៍ដោយចេតនាឬអចេតនាពីប្រព័ន្ធដ៏កំណាចនេះមានការសោកស្តាយនិងអាម៉ាស់» ។ សម្តីគួរឲ្យចាប់អារម្មណ៍ដូចគ្នានេះនិយាយដោយអតីតប្រធានាធិបតី ដឺ ក្លឺក ដែលត្រូវបានចោទប្រកាន់នៅក្នុងរបាយការណ៍ចុងក្រោយរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាថាពុំបាន«លាតត្រដាងឲ្យអស់សាច់រឿង» នៅពេលដែល ដឺ ក្លឺក បកស្រាយអំពីការរំលោភសិទ្ធិមនុស្ស ។ តាមរយៈ ដឺ ក្លឺក «ដំណើរការរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា មិនបានធ្វើឲ្យសម្រេចនូវគោលដៅនៃការបង្កើតឲ្យមានការពិតទាំងស្រុងទាក់ទងទៅនឹងជម្លោះពីអតីតកាល ហើយមិនបានជំរុញឲ្យមានការផ្សះផ្សានៅអាហ្វ្រិកខាងត្បូងដូចដែលបានព្រាងទុកទេ» ។

គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាថែមទាំងត្រូវបានចោទប្រកាន់ថាបានធ្វើឲ្យទំនាក់ទំនងពូជសាសន៍នៅប្រទេសអាហ្វ្រិកខាងត្បូងកាន់តែយ៉ាប់យឺនតាមរយៈការផ្សព្វផ្សាយទូទាំងប្រទេសនូវចំណុចពិស្តារទាក់ទងទៅនឹងទំហំនៃការជិះជាន់និងភាពឃោរឃៅរបស់ពួកស្បែកសនៅក្រោមរបបអាប៉ាថេត ។ អ្វីដែលច្បាស់លាស់នោះគឺថាគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាគឺគ្រាន់តែជាការវិវឌ្ឍន៍ដ៏សំខាន់មួយនៅលើវិថីឆ្ពោះទៅកាន់ការព្យាបាលសង្គមអាហ្វ្រិកខាងត្បូងប៉ុណ្ណោះ ។

ការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ជាច្រើនបានធ្វើឡើងទៅលើការផ្សះផ្សា ។ ក៏ប៉ុន្តែក្តីសង្ឃឹមត្រូវបានធ្វើឲ្យច្រឡំជាមួយនឹងការពិត ។ អ្នកអត្ថាធិប្បាយមួយរូបបានសង្កេតឃើញបាតុភូតមួយនៃ«ការប្រើប្រាស់មិនប្រុងប្រយ័ត្ននូវពាក្យទាក់ទងនឹងយុត្តិធម៌សម័យអន្តរកាលដោយមិនបានពន្យល់ឲ្យបានច្បាស់លាស់ថាពាក្យទាំងនេះចូលគ្នាចុះតាមវិធីណា» ។ ការធ្វើបែបនោះនាំឲ្យគេយល់ថាការអះអាងគ្មានហេតុផលច្បាស់លាស់គឺជាការពិត «នៅពេលដែលការអះអាងនោះគ្រាន់តែជាគោលគំនិត ការទាយទុកការសង្ឃឹម និងជាសុបិនប៉ុណ្ណោះ» ព្រមទាំងលាក់បាំងការខ្វះខាតភាពច្បាស់លាស់នៃទ្រឹស្តីជុំវិញពាក្យ«ផ្សះផ្សា»ផង ។

អ្នកខ្លះបានសង្កេតឃើញថា ភាគច្រើននៃអ្វីៗទាំងនេះគឺពិតជាអំពីជំនឿអរូបី ។

ទស្សនៈដ៏ពិបាកយល់នេះគឺពិតជាកំពុងត្រូវបានពិភាក្សាយ៉ាងមិនយកចិត្តទុកដាក់ដោយយល់ថាងាយពេក ដែលបង្កឲ្យមានការរំពឹងទុកជុយពីការពិតថាការផ្សះផ្សាជាលទ្ធផលស្វ័យប្រវត្តិនិងពីធម្មជាតិនៃសកម្មភាពជាក់ជាក់ណាមួយ ។

សុភនិច្ឆ័យពន្យល់ថា វិធីសាស្ត្រកាន់តែជាក់ស្តែងជាងនេះសម្រាប់ការផ្សះផ្សានឹងមានប្រយោជន៍ជាង ហើយអ្នកនិពន្ធសៀវភៅនេះបានព្យាយាមនាំយកទាំងការពិតនិយមនិងសុភនិច្ឆ័យ

មកសិក្សា ។ អ្នកជំនាញការមួយរូបបានទាញហេតុផលយ៉ាង ត្រឹមត្រូវថា "ទស្សនៈអំពីការផ្សះផ្សាណាក៏ដោយ ក្នុងទ្រង់ទ្រាយ ធំឬតូចក្តី ដែលធ្វើឲ្យការផ្សះផ្សាពឹងផ្អែកទៅលើការអត់ឱនឬ ដែលសង្កត់ធ្ងន់ទៅលើភាពចុះសម្រុងគ្នានិងការគិតវិជ្ជមានរវាង បុគ្គលនិងបុគ្គល នឹងមិនក្លាយជាគំរូជាក់ស្តែងនៃការផ្សះផ្សា សម្រាប់សត្វលោកដូចជាយើងទាំងអស់គ្នានេះទេ ។ ប្រសិនបើ យើងពិតជាខ្វាយខ្វល់អំពីការផ្សះផ្សា សូមឲ្យយើងពន្យល់ពីអត្ថន័យ នៃការផ្សះផ្សាតាមទម្រង់មួយដែលសមស្របចំពោះភាគីពាក់ព័ន្ធ ទាំងអស់" ។ អ្នកជំនាញការរូបនេះព្យាយាមវែកញែកទស្សនៈនៃ ការផ្សះផ្សាឲ្យដល់ឫសគល់ហើយពន្យល់ថា "ការផ្សះផ្សាគឺការ កាត់បន្ថយភាពតានតឹង (ភាពតានតឹងរវាងជំនឿពីរឬច្រើន ភាព តានតឹងរវាងការបកស្រាយព្រឹត្តិការណ៍ខុសគ្នាពីរឬច្រើន ឬ ភាព តានតឹងរវាងតម្លៃមិនស្មើគ្នាពីរឬច្រើន) និងការឆ្លើយតបរបស់ យើងចំពោះភាពតានតឹងទាំងនេះ" ។ អ្នកជំនាញការរូបនេះបាន ចង្អុលបង្ហាញថា រាល់ករណីទាំងអស់ភាពដែលអាចទៅរួចថា ការផ្សះផ្សាអាចនាំមកនូវសន្តិភាពផ្លូវចិត្តមិនបានផ្តល់នូវហេតុផល សីលធម៌សម្រាប់ការព្យាយាមផ្សះផ្សាទេ ។

ការផ្សះផ្សាមិនមែនជាទឹកអម្រឹតដែលនឹងព្យាបាលរាល់ វិបត្តិផ្លូវចិត្តរបស់មនុស្សម្នាក់ៗ និងភាពខុសឆ្គងនៅក្នុងសង្គម មនុស្សឡើយ ។ មានពាក្យមានន័យធៀបមួយដែលគេតែងតែ ប្រើដើម្បីពន្យល់ថាជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស ធ្ងន់ធ្ងរមានតម្រូវការឲ្យខ្លួនឯងរួចចាកផុតពីភាពរន្ធត់ ។ តាម វិធីសាស្ត្រដូចគ្នាដែលយើងត្រូវតែវះខុះចេញពីរបួសដើម្បីធ្វើឲ្យ របួសឆាប់ជា មានការទាញហេតុផលថាជនរងគ្រោះទាមទារឲ្យ មានការ"លាតត្រដាង"នូវអ្វីដែលបានកើតឡើងចំពោះខ្លួនដើម្បី ព្យាបាលរបួសផ្លូវចិត្ត ។ ជីវិតនឹងកាន់តែងាយស្រួលគ្រប់គ្រង ប្រសិនបើដួងព្រលឹងដ៏ពិបាកយល់របស់មនុស្សអាចជាសះស្បើយ ដូចជារបួសលើសាច់នៅពេលដែលរបួសនេះត្រូវបានលាងសម្អាត ដោយថ្នាំផ្សះ ដែលករណីនេះជាការរៀបរាប់អំពីរឿងរ៉ាវ ហើយ បន្ទាប់មកអ្វីៗក្លាយទៅជាប្រសើរឡើងវិញ ។ ប៉ុន្តែមនុស្សមិន មែនជារបួសទេ ។ ដូចគ្នាដែរ យើងគួរប្រុងប្រយ័ត្នក្នុងការផ្តល់ សមភាពដល់ការផ្សះផ្សាក្នុងកម្រិតបុគ្គលជាមួយនឹងការផ្សះផ្សា ក្នុងកម្រិតសង្គម ។ បុគ្គលគួរតែជាដំណាក់កាលទីមួយនៃការ ផ្សះផ្សាទូទាំងប្រទេស ពីព្រោះបុគ្គលដែលមានការកែប្រែអាច កែប្រែសង្គមមួយ ។ ប្រសិនបើមានបុគ្គលបែបនេះច្រើន បុគ្គល ទាំងនេះប្រហែលជាអាចផ្លាស់ប្តូរចរិតលក្ខណៈរបស់សង្គមទាំង មូល ។ ហេតុផលនេះបាននាំមកនូវបញ្ហាជាក់ស្តែងដ៏ធំនៅពេល ដែលប្រជាជនជាច្រើន (ជួនកាលរហូតដល់ទៅរាប់លាននាក់ដូច នៅក្នុងករណីប្រទេសកម្ពុជានិងរ៉្វាន់ដា) ជាជនរងគ្រោះហើយបង្ក ឲ្យមានការខិតខំប្រឹងប្រែងរួមនៅក្នុងកម្រិតជាតិដូចជាគណៈកម្មការ ស្វែងរកការពិតដែលបង្កើតឲ្យមានសវនាការជាសាធារណៈដើម្បី ឲ្យដឹងឮជាទូទៅ ។

ភាពខុសគ្នាក្នុងកម្រិតជាក់លាក់មួយ ភាពតានតឹងនិងភាព ស្អប់ខ្ពើមរវាងបុគ្គលគឺជារឿងធម្មតានិងសមស្របនៅក្នុងសង្គម ទាំងអស់ ។ ក៏ប៉ុន្តែរាល់សំណើដែលថា មនុស្សទាំងអស់នឹងរស់នៅ ក្នុងសេចក្តីស្រឡាញ់ សន្តិភាព និងភាពសុខដុម ក្រោយពីបាន ប្រារព្ធពិធីជាសាធារណៈនៃការទទួលស្គាល់ទុក្ខសោករបស់នរណា ម្នាក់និងបង្ហាញពីការអត់ឱន គឺមានលក្ខណៈឆ្ងាយពីការពិតបន្តិច ។ អំពើហិង្សាត្រូវបានស្អប់ខ្ពើមជាសកល តែប្រវត្តិសាស្ត្របាន បង្ហាញថាវាជាអ្វីដែលយើងត្រូវតែរស់ជាមួយដែលខុសគ្នាពីការ និយាយថាយើងគួរតែឈប់ដោះស្រាយជម្លោះតាមរយៈមធ្យោ- បាយសន្តិវិធី ។ មនុស្សលោក ពិសេសមនុស្សដែលធ្លាប់មាន ភាពភ័យរន្ធត់និងការឈឺចាប់ដោយអំពើហិង្សានិងឃោរឃៅទ្រង់ ទ្រាយធំ ជាក់ស្តែងមិនអាចបំភ្លេចចោលនូវរឿងរ៉ាវពីអតីតកាល ដូចជាមនុស្សយន្តបានទេ ។ សោកនាដកម្មដែលចេះតែបន្តមិនចេះ ចប់នោះគឺថា ជនរងគ្រោះតែងតែពាំនាំជាប់នឹងខ្លួននូវរបួស ទោះ មានភាពជារូបវន្ត ជាផ្នែកចិត្តសាស្ត្រឬផ្លូវអារម្មណ៍ក្តី ទោះជា មានឬគ្មានការជួយជ្រោមជ្រែងក្តី ក៏អ្នកខ្លះអាចគ្រប់គ្រងអារម្មណ៍ ប្រសើរជាងអ្នកខ្លះទៀត ។ យើងក៏មិនត្រូវបំភ្លេចថាជនដៃដល់ខ្លះ នឹងពាំនាំនូវអារម្មណ៍ល្មើសចំពោះតួនាទីរបស់ខ្លួនក្នុងការបង្កឲ្យ មានការឈឺចាប់ដល់អ្នកដទៃ ក៏ដូចជាបទពិសោធន៍ឈឺចាប់ផ្ទាល់ ខ្លួន ព្រមទាំងអំពើហិង្សានៅក្រោមកណ្តាប់ដៃរបស់អ្នកផ្សេង ។ ដូច្នេះការផ្សះផ្សានៅក្នុងកម្រិតបុគ្គលអាចក្តោបការផ្តាច់ចេញពី "ចិត្តគំនិតរបស់ជនរងគ្រោះ" ទោះជាចិត្តគំនិតនោះឋិតនៅក្នុង

ទម្រង់ជាការខឹងប្រឡោត អសកម្ម ភាពកន្តើយ ការឈ្លក់វង្វេងនឹងអតីតកាល ឬភាពឥតជំនួយក៏ដោយ ។ បើមិនដូច្នោះទេ ត្រូវដោះស្រាយជាមួយនឹងអ្វីដែលបានកើតឡើងដើម្បីបង្កឲ្យមានការឆ្លើយតបទាំងនេះ ហើយសម្រុះសម្រួលជាមួយនឹងការឆ្លើយតបទាំងនេះដើម្បីបង្កឲ្យមានតុល្យភាពកាន់តែប្រសើរ ។

ការផ្សះផ្សាក្នុងទម្រង់ជាទំនាក់ទំនងរវាងមនុស្សបន្ទាប់ពីមានអំពើហិង្សានិងការគាបសង្កត់ក្នុងទ្រង់ទ្រាយធំ អាចថាមានភាពសាមញ្ញដូចការរៀនរស់នៅដោយសុខស្រួលជាមួយនឹងអ្នកដែលយើងមិនចូលចិត្ត ឬដោយនរណាម្នាក់ដែលគេស្អប់ ។ មនុស្សម្នាក់អាចមានទស្សនៈនយោបាយខុសគ្នាជាមួយអ្នកផ្សេង ។ មនុស្សម្នាក់អាចស្អប់ខ្ពើមជាតិពន្ធ សាសនា ឬវប្បធម៌របស់មនុស្សម្នាក់ទៀត ។ មនុស្សម្នាក់អាចមានមនសិការល្មើស ។ មនុស្សម្នាក់អាចជាជនរងគ្រោះនៃទុក្ខវេទនាដែលបង្កឡើងដោយអ្នកផ្សេង ។ ការរៀបរាប់ខាងលើមិនមែនចង់និយាយអំពីការហាមប្រាមមិនឲ្យមានការពិភាក្សាអំពីអតីតកាលឬត្រូវបង្ខំចិត្តទទួលយកស្ថានភាពមួយដែលឫសគល់នៃជម្លោះមិនត្រូវបានជីកកកាយនោះទេ ។ ផ្ទុយទៅវិញ យើងចង់និយាយអំពីការយល់ឃើញថាជីវិតរស់នៅប្រចាំថ្ងៃអាចប្រសើរជាងនេះ បើមនុស្សម្នាក់អាចបំភ្លេចចោលការឈឺចាប់ដែលអាចយល់បាននិងភាពអវិជ្ជមានខ្លះដែលជាលទ្ធផលនៃអំពើហិង្សានិងការគាបសង្កត់ ។ នៅក្នុងករណីនេះ ការចង់បានយុត្តិធម៌នៅក្នុងតុលាការអង្គច្បាប់មិនគួរត្រូវបានមើលឃើញថាជាឧបសគ្គនៃការជួសជុលសង្គមទេ លុះត្រាតែការចង់បាននេះត្រូវបានបង្កដោយការសងសឹកជាបុគ្គល ការស្តីបន្ទោសចំពោះអ្វីដែលបានកើតឡើង ការរើសអើង ឬអ្វីស្រដៀងគ្នាផ្សេងទៀត ។ ការចង់បានយុត្តិធម៌នេះត្រូវបានសម្រេចឲ្យបានតាមវិធីមួយដែលមានលក្ខណៈផ្លូវច្បាប់ពេកចន្លៀតពេក និងមិនមានការពិតពេក ដែលបានកាត់ផ្តាច់ទាំងស្រុងពីការពិតផ្នែកនយោបាយ ។ ការទាមទារនេះមានលក្ខណៈបែងចែកពេកដែលអាចបង្កឲ្យមានជម្លោះកាន់តែធ្ងន់ធ្ងរថែមទៀត ។

សម្រាប់មនុស្សមួយចំនួន ជំនឿសាសនាជាជំនួយដ៏វិសេសវិសាល ។ សម្រាប់អ្នកផ្សេង ការព្យាបាលជាការសំខាន់ ។ អ្នកខ្លះមានអារម្មណ៍ធូរស្បើយនៅពេលបាននិយាយបញ្ចេញនូវអ្វីដែលបានឆ្លងកាត់ ។ អ្នកខ្លះយល់ថាដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ឬការស្វែងរកការពិតដែលយករឿងដាក់ស្តែងមកដោះស្រាយ អាចជាជំនួយក្នុងការបំភ្លេចចោលនូវអតីតកាល ។ អ្នកខ្លះទាមទារឲ្យមានការសុំទោសដោយស្មោះត្រង់ ។ សម្រាប់អ្នកខ្លះ ការសុំទោស ការសោកស្តាយ និងការកែប្រែ ជាការប្រសើរ ។ អ្នកខ្លះទៀតយល់ថាពេលវេលាជាការព្យាបាលដ៏ប្រសើរបំផុត ។ ដូច្នេះសម្រាប់បុគ្គលម្នាក់ៗ ការផ្សះផ្សាជាដំណើរការមានលក្ខណៈបុគ្គលដែលអាចឬមិនអាចត្រូវបានប៉ះប៉ូវដោយកិច្ចប្រឹងប្រែងរបស់រដ្ឋធ្វើឡើងដើម្បីជួសជុលសង្គម ។

យើងគួរប្រុងប្រយ័ត្នចំពោះការសន្យាថាអាចព្យាបាលបានទាំងស្រុង ក្នុងករណីមាន"អ្នកជំងឺ"ជាច្រើនប្រភេទដែលមានបញ្ហានិងតម្រូវការខុសគ្នា ហើយឆ្លើយតបផ្សេងគ្នាទៅនឹងការបង្កាប់ ។ ហេតុនេះ ការផ្សះផ្សាជាដំណើរការមួយអាចត្រូវបានមើលឃើញថាជាការជួយប្រជាជន ហើយតាមរយៈនេះគឺសង្គមទាំងមូល ដើម្បីឲ្យមនុស្សទាំងអស់អាចរស់នៅក្នុងជីវិតធម្មតាដូចដែលអាចធ្វើទៅបាន ។ ម្យ៉ាងទៀត ការផ្សះផ្សាគឺជាដំណើរការមួយដែលធ្វើឲ្យសង្គមបាក់បែកមួយរួបរួមគ្នានាថ្ងៃអនាគត ឬជាមធ្យោបាយមួយដែលអតីតកាលត្រូវបានដោះស្រាយដើម្បីធ្វើដំណើរទៅអនាគត ។ គាំទ្រចំពោះទស្សនៈដ៏សាមញ្ញនៃការផ្សះផ្សាគឺជាការវាយតម្លៃមួយដែលថា "តាមរយៈទស្សនៈនៃការដោះស្រាយជម្លោះការផ្សះផ្សាត្រូវបានមើលឃើញថាជាដំណើរការរយៈពេលយូរនៃការគ្រប់គ្រងភាពប្រទូសរ៉ាយនិងការមិនជឿទុកចិត្តគ្នារវាងក្រុមប្រជាជន ។ ការផ្សះផ្សាជាការពង្រឹងទំនាក់ទំនងសង្គមឲ្យល្អប្រសើររវាងក្រុមផ្សេងៗនៃមនុស្សរួមទាំងភាគីនៃជម្លោះផង ។ ការផ្សះផ្សាបូករួមទាំងការទទួលស្គាល់នៅក្នុងចំណោមភាគីនៃសេចក្តីត្រូវការឲ្យមានការយល់ឃើញរួមមួយអំពីមូលហេតុ និងសារជាតិនៃជម្លោះនិងបង្កើតសញ្ញាណមួយនៃការទទួលខុសត្រូវ" ។

## II. ការរកឃើញ

ចម្លើយដែលទទួលបានពីមិត្តអ្នកអាននិងប្រជាជនត្រូវបានបែងចែកជាប្រាំបីគោលគំនិតឬផ្នែកដូចខាងក្រោម÷

## លទ្ធផលរួមនៃការស្ទាបស្ទង់មតិ

### ផ្នែកទីមួយៈ ទស្សនាវដ្ដីស្វែងរកការពិត

**សំណួរ១៤ៈ តើលោកអ្នកយល់ពីគោលបំណងនៃការបង្កើតទស្សនាវដ្ដីស្វែងរកការពិតដែរឬទេ?**

៤១.៧១% ខ្ញុំយល់ច្បាស់

៣១.៦០% ខ្ញុំយល់មិនសូវច្បាស់

១៧.៤១% ខ្ញុំមិនយល់ទាល់តែសោះ

៩.២៧% គ្មានចម្លើយ

**សំណួរ១៥ៈ តើលោកអ្នកមានចំណាប់អារម្មណ៍យ៉ាងដូចម្ដេចខ្លះចំពោះទស្សនាវដ្ដីស្វែងរកការពិតដែលបានចេញផ្សាយអស់រយៈពេលពីរឆ្នាំកន្លងមកនេះ?**

៨៧.២២% មានប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាទូទៅ

៦.៧៤% ធ្វើឲ្យប្រជាជនស្អប់អារម្មណ៍

៧.៣០% រៀបរាប់តែពីរឿងចាស់មិនគួររំពុកឡើងវិញ

២.២៥% មានពត៌មានសំខាន់សម្រាប់អ្នកស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ ច្បាប់ វប្បធម៌ និងសិល្បៈ

០.៤២% គ្មានអ្វីសំខាន់

៧២.៧៥% រៀបរាប់យ៉ាងត្រឹមត្រូវអំពីជីវិតរបស់ប្រជាជនកម្ពុជានៅក្រោមរបបខ្មែរក្រហម

១.១២% រំពុករឿងចាស់ បន្តឲ្យមានបញ្ហាសង្គមឡើងវិញ

២៦.៩៧% បង្ហាញពីតម្លៃនៃការផ្សះផ្សាជាតិ

**សំណួរ១៦ៈ តើប្រជាជននៅតាមភូមិឃុំដឹងឮច្បាស់ពីការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិតឬទេ?**

៣៥.៥៣% មិនដែលឮសោះកាលពីមុន

២៤.៧២% អាជ្ញាធរភូមិឃុំមិនដែលចែកជូនទស្សនាវដ្ដី (ឬនិយាយអំពីទស្សនាវដ្ដី)

៥.៤៨% អាជ្ញាធរមូលដ្ឋានចែកជូនប្រជាជនរៀងរាល់ខែ

៣៤.២៧% ឃើញម្ដងម្កាលតែប៉ុណ្ណោះ

**សំណួរ១៧ៈ តើលោកអ្នកយល់ថាទស្សនាវដ្ដីស្វែងរកការពិតរួមចំណែកដល់ការព្យាបាលរបួសសង្គមដែរឬទេ?**

៦២.៥% បាទ/ចាស

៧.០២% ទេ

៣០.៤៨% គ្មានចម្លើយ

**សំណួរ១៩ៈ តើទស្សនាវដ្ដីស្វែងរកការពិតគួរបោះពុម្ពផ្សាយអំពីអ្វីដើម្បីជាជំនួយដល់ការផ្សះផ្សាជាតិ?**

១៣.០៦% អំពីជនដៃដល់បានហើយ

៨.៨៥% អំពីជនរងគ្រោះបានហើយ

៦.០៧% អំពីទង្វើបានហើយ

៦៧.៦៣% ចំណុចទាំងបីខាងលើ

៤.៣៩% គ្មានចម្លើយ

**សំណួរ២១ៈ តើទស្សនាវដ្ដីស្វែងរកការពិតគួរមានតួនាទីយ៉ាងណាខ្លះក្នុងអំឡុងនិងក្រោយពេលមានតុលាការ?**

២០.២២% គួរដើរតួនាទីជាសំឡេងរបស់ជនរងគ្រោះនិងជនដៃដល់

៥៤.៦៣% គួរដើរតួនាទីជាប្រភពឯកសារនិងពត៌មានផ្នែកច្បាប់ទាក់ទងទៅនឹងតុលាការ

១៥.៣១% គួរដើរតួនាទីជាអាជ្ញាកណ្ដាលសម្រាប់សម្របសម្រួលរវាងជនរងគ្រោះនិងជនដៃដល់

៤៥.២២% គួរដើរតួនាទីជាស្ពានឆ្លងទៅរកការផ្សះផ្សានិងបង្រួបបង្រួមជាតិ

**សំណួរ២២ៈ បើគួរមានទស្សនាវដ្ដីស្វែងរកការពិតបន្តទៀត តើទស្សនាវដ្ដីស្វែងរកការពិតគួរផ្សាយអំពីអ្វីខ្លះ?**

៥២.៩១% អំពីមូលហេតុដែលខ្មែរក្រហមធ្វើបាបនិងកាប់សម្លាប់ប្រជាជន

៣៧.៨០% ការទទួលខុសត្រូវរបស់ខ្មែរក្រហម

១២.៧២% ស្នើសុំឲ្យប្រជាជនអត់ឱនទោសឲ្យខ្មែរក្រហម

៥៥.០៧% តុលាការខ្មែរក្រហម

២៥.០៥% ការបកស្រាយពន្យល់របស់ខ្មែរក្រហម

### ផ្នែកទីពីរៈ ផលប៉ះពាល់ផ្ទាល់នៃរបបខ្មែរក្រហម

**សំណួរ១ៈ តើលោកអ្នកមានសមាជិកគ្រួសារប៉ុន្មាននាក់ស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម?**

៨៩.៤២% បានបាត់បង់

១.៣០% មិនបានបាត់បង់

៩.២៨% គ្មានចម្លើយ

***សំណួរ២៖ តើការស្លាប់បាត់បង់ជីវិតនេះប៉ះពាល់យ៉ាងម៉េចខ្លះចំពោះរូបអ្នក?***

៥៧.០២% ធ្វើឲ្យខ្ញុំកំព្រារស់នៅយ៉ាងលំបាកលំបិនរហូតដល់សព្វថ្ងៃ

២៧.៤៣% មិនមានអ្វីប៉ះពាល់ដល់រូបខ្ញុំឡើយ

១៥.៥៥% គ្មានចម្លើយ

***សំណួរ៣៖ តើអ្នកឬបងប្អូនក្រុមគ្រួសារធ្លាប់ត្រូវខ្មែរក្រហមធ្វើទារុណកម្មឬទេ?***

៧៧.៣២% បាទ/ចាស

១១.៦៦% ទេ

១១.០២% គ្មានចម្លើយ

ផ្នែកទី៣៖ ការពិភាក្សាអំពីរបបខ្មែរក្រហម

***សំណួរ៤៖ តើលោកអ្នកចង់និយាយអំពីរបបខ្មែរក្រហមឬទេ?***

៦៧.៦០% បាទ/ចាស

២៨.០១% ទេ

៤.៣៩% គ្មានចម្លើយ

***សំណួរ៥៖ តើអ្វីដែលលោកអ្នកនឹកឃើញមុនគេនៅពេលនិយាយដល់របបខ្មែរក្រហម?***

២៩.៨០% ការងារពលកម្ម

៣១.៥៣% អាហារ

២៣.១១% ការរស់នៅដាច់ដោយឡែកពីគ្នា

៦៣.២៨% ការបាត់បង់ជីវិតរបស់សមាជិកគ្រួសារ

១២.៣១% ផ្សេងៗ

***សំណួរ៦៖ តើលោកអ្នកនៅតែនឹកឃើញអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមឬទេ?***

៥៨.៧៥% បាទ/ចាស

២៥.៧០% ទេ

១៥.៥៥% គ្មានចម្លើយ

***សំណួរ១១៖ នៅពេលដែលលោកអ្នករៀបរាប់អំពីរឿងរ៉ាវដែលបានកើតឡើងចំពោះលោកអ្នកនៅក្នុងរបបខ្មែរក្រហម តើលោកអ្នកមានអារម្មណ៍បែបណា?***

៧.៥៦% ធ្វើឲ្យខ្ញុំមានអារម្មណ៍ប្រសើរឡើង

៦០.៩១% ធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អ

១០.៨០% អារម្មណ៍ធម្មតា

២០.៧៣% គ្មានចម្លើយ

***សំណួរ១២៖ តើលោកអ្នកចង់ដឹងអំពីការពិតនៃរបបខ្មែរក្រហមឬទេ?***

៧៣.៨៧% ចង់ដឹង ព្រោះសំខាន់

៧.៧៧% មិនចង់ដឹង ព្រោះជារឿងចាស់

១៨.៣៦% គ្មានចម្លើយ

ផ្នែកទី៤៖ អាកប្បកិរិយាចំពោះរបបខ្មែរក្រហម

ការអត់ឱន

***សំណួរ៧៖ តើលោកអ្នកអាចអត់ឱនឲ្យកម្មាភិបាលខ្មែរក្រហមដែលបានធ្វើឲ្យលោកអ្នកឈឺចាប់ឬទេ?***

២៦.៥៦% បាទ/ចាស

៦៧.១៧% ទេ

៦.២៧% គ្មានចម្លើយ

***សំណួរ៨៖ តើលោកអ្នកអត់ឱនកម្មាភិបាលខ្មែរក្រហមដែលបានធ្វើទារុណកម្មលើរូបអ្នកយ៉ាងដូចម្តេច?***

១៦.២% ឲ្យមានការរៀបរាប់កំហុស និងសុំការអភ័យទោសជាសាធារណៈ

៥៦.៥៩% ឲ្យមានតុលាការដើម្បីកាត់ទោស

១០.៣៧% ផ្សេងៗ

១៦.៨៤% គ្មានចម្លើយ

ការសងសឹក

***សំណួរ៩៖ នៅពេលដែលលោកអ្នកដឹងថាអ្នកភូមិដែលនៅរស់គឺជាអ្នកដែលបានសម្លាប់ញាតិសន្តានរបស់លោកអ្នក តើលោកអ្នកខឹងហើយចង់សងសឹកឬទេ?***

៦៨.៩៦% ទេ

២៣.៧៣% បាទ/ចាស

៧.៣១% គ្មានចម្លើយ

***សំណួរ១០៖ ប្រសិនបើលោកអ្នកដឹងថាកូនរបស់បុគ្គលដែលបានសម្លាប់ឪពុកម្តាយឬសាច់ញាតិអ្នកគឺជាមិត្តរួមថ្នាក់កូនរបស់អ្នក តើលោកអ្នកហ្វឹកហ្វឺនកូនអ្នកឲ្យរើសអើងឬទេ?***

៣.៦៥% ត្រូវតែបណ្តុះកំហឹងនិងរើសអើងជានិច្ច

៦៧.៧០% ខ្ញុំមិនចង់ចងកម្មចងពៀរទេ ព្រោះនៅពេលណាមួយ កូនជនដៃដល់នឹងសងសឹកមកលើកូនចៅរបស់ខ្ញុំវិញមិនខាន

៣៧.៧៨% ផ្សេងៗ

### អាកប្បកិរិយាចំពោះកម្មាភិបាលថ្នាក់ទាប

**សំណួរ២៣៖ ទស្សនាវដ្តីស្វែងរកការពិតបានបោះពុម្ពផ្សាយអំពីជីវប្រវត្តិនិងសកម្មភាពរបស់អ្នកសួរចម្លើយនិងកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ។ តើលោកអ្នកវិនិច្ឆ័យបុគ្គលទាំងនោះជាជនដៃដល់ឬជាជនរងគ្រោះ?**

២៣.៨៩% ជនដៃដល់

២៩.៩៥% ជនរងគ្រោះ

៤១.២៩% ទាំងពីរ

៤.៨៧% គ្មានចម្លើយ

**សំណួរ២៤៖ តើលោកអ្នកមានអារម្មណ៍យ៉ាងណាចំពោះជនដៃដល់ខ្មែរក្រហមថ្នាក់ទាប?**

១៦.៦% ខ្ញុំអាណិត

៥៣.៨៥% ខ្ញុំមិនអាណិត

២៤.៧០% ផ្សេងៗ

៤.៨៥% គ្មានចម្លើយ

### ផ្នែកទី៥៖ យន្តការនៃការទទួលខុសត្រូវ

**សំណួរ១៣៖ តើលោកអ្នកចង់បានការកាត់ទោសប្រភេទណា?**

៧០.១៩% តុលាការដែលមានការចូលរួមពីអង្គការសហប្រជាជាតិ

៧.១៣% តុលាការដែលមានការចូលរួមពីប្រទេសផ្សេងៗ

១៨.៥៧% តុលាការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាសុទ្ធសាធ

៤.១១% គ្មានចម្លើយ

**សំណួរ១៨៖ នៅពេលដែលលោកដឹងឮអំពីប្រវត្តិនិងទង្វើរបស់មេដឹកនាំខ្មែរក្រហម តើលោកអ្នកយល់យ៉ាងណា?**

៧២.០៥% ខ្ញុំចង់ឲ្យមានតុលាការកាត់ទោសឲ្យបានឆាប់ដើម្បីជាគំរូដល់ក្មេងជំនាន់ក្រោយ

១១.០៩% ខ្ញុំចង់ឲ្យមានតុលាការ ប៉ុន្តែខ្លាចមានការច្របូកច្របល់សាជាថ្មី

២.៥៨% ខ្ញុំមិនចង់ឲ្យមានតុលាការទេព្រោះថ្នាក់លើមិនបានប្រព្រឹត្តខ្លួនឯងផង

៨.៧១% យោបល់ផ្សេងទៀត

៥.៦២% គ្មានចម្លើយ

### ផ្នែកទី៦៖ ការចាត់ចែងសំណល់ជនរងគ្រោះ

**សំណួរ២៥៖ ទស្សនាវដ្តីស្វែងរកការពិតបានបោះពុម្ពផ្សាយរូបថតជាច្រើននៃសំណល់ជនរងគ្រោះ ។ តើលោកអ្នកយល់ស្របតាមសម្តីមួយណានៅខាងក្រោម?**

៥៧.០៨% ការផ្សព្វផ្សាយជាការបង្ហាញអំពីទំហំនៃអំពើហិង្សារបស់ខ្មែរក្រហម

១៣.៧៦% ការផ្សព្វផ្សាយជាការមិនគោរពព្រលឹងជនរងគ្រោះ

២៨.៧៤% ផ្សេងៗ

០.៤២% គ្មានចម្លើយ

### ផ្នែកទី៧៖ ការផ្សព្វផ្សាយឬការអប់រំ

**សំណួរ២០៖ តើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមគួរផ្សព្វផ្សាយឲ្យបានទូលំទូលាយជាងនេះតាមវិធីណា?**

៦៣.៦២% តាមប្រព័ន្ធសារព័ត៌មាន ដូចជាកាសែត វិទ្យុ ទូរទស្សន៍ ជាដើម

១៣.៦២% តាមរយៈទីភ្នាក់ងាររដ្ឋាភិបាលនៅតាមខេត្តក្រុង

២២.៨៩% តាមរយៈទីភ្នាក់ងារឯកជននានាដូចជាអង្គការក្រៅរដ្ឋាភិបាល សិទ្ធិមនុស្ស

៤៥.៦៥% បង្កើតយុទ្ធនាការអប់រំនៅតាមមូលដ្ឋានតាមរយៈសាលារៀន

**សំណួរ២៦៖ តើសាលាវិទ្យាល័យឬអនុវិទ្យាល័យគួរទទួលការអប់រំក្រៅកម្មវិធីសិក្សាអំពីអ្វីដែលបានចុះក្នុងទស្សនាវដ្តីស្វែងរកការពិតឬទេ?**

៨៥.០២% បាទ/ចាស

៣.២៤% ទេ

១១.៧៤% គ្មានចម្លើយ

## ផ្នែកទី៨: ការផ្សះផ្សានិងបង្រួបបង្រួមជាតិ

***សំណួរ២៧: តើការផ្សះផ្សានិងបង្រួបបង្រួមមានន័យដូចម្តេច? តើគួរធ្វើយ៉ាងដូចម្តេចខ្លះដើម្បីសម្រេចនូវគោលដៅទាំងនេះ?***

◆ អ្នកឆ្លើយមួយភាគធំយល់ថាការផ្សះផ្សានិងបង្រួបបង្រួមជាដំណើរការមួយនៃការទទួលយកនូវចំណុចខាងក្រោមតាមរយៈការប្រឹងប្រែងរួមរបស់ប្រជាជនកម្ពុជាទាំងមូល÷

១) ប្រទេសតែមួយដែលមានការរួបរួមគ្នា រីកចម្រើននិងរុងរឿង ដោយមានការស្តារឡើងវិញនូវទំនាក់ទំនងធម្មតានិងសាមគ្គីភាពរវាងពលរដ្ឋទាំងអស់ ព្រមទាំងការបង្កើតឡើងនូវទស្សនវិស័យរួមសំដៅកសាងអនាគតកាន់តែរុងរឿង ។

២) សេរីភាពនៃការរស់នៅដោយគ្មានអំពើហិង្សានិងជម្លោះ ការទទួលបាននូវសន្តិភាព ភាពរុងរឿង ការអភិវឌ្ឍន៍ ព្រមទាំងយុត្តិធម៌សង្គម ។

៣) សង្គមមួយដែលបានផ្លាស់ប្តូរនិងធ្វើឲ្យមានតុល្យភាពឡើងវិញ គ្រប់គ្រងដោយធម្មាធិបតេយ្យ ។ នៅក្នុងកម្រិតបុគ្គល សហគមន៍អន្តរសហគមន៍និងជាតិ ប្រជាជនខ្មែរកែប្រែនូវអត្តចរិតអវិជ្ជមានប្កបំផ្លិចបំផ្លាញ ហើយធ្វើឲ្យទំនាក់ទំនងរវាងបុគ្គលកាន់តែប្រសើរឡើង ។ ប្រជាជនទាំងអស់ដាក់មួយឡែកនូវទុក្ខសោកជាបុគ្គលនិងអតីតកាលដ៏ជូរចត់ ហើយជ្រើសយកការប្រឹងប្រែងសម្រេចឲ្យបាននូវទស្សនវិស័យរួមនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ មេដឹកនាំនយោបាយបានយកប្រយោជន៍ជាតិជាអាទិភាពទីមួយ ។

◆ អ្នកឆ្លើយមួយភាគធំទៀតយល់ថាការផ្សះផ្សានិងការបង្រួបបង្រួមនៅកម្ពុជាអាចសម្រេចបាន ប្រសិនបើ÷

១) ប្រជាជនខ្មែរផ្លាស់ប្តូរនូវការគិតនិងអាកប្បកិរិយារបស់ខ្លួនដែលបន្តឲ្យជីវិតរស់នៅកាន់តែប្រសើរឡើង ។ ប្រជាជនខ្មែរចាំបាច់ត្រូវរួមរស់ជាមួយគ្នាដោយសុខសាន្ត ហើយមិនអនុញ្ញាតឲ្យអតីតកាលមកចងពៀរបានឡើយ ប៉ុន្តែត្រូវលះបង់ចោលនូវការចងពៀរ ការគុំកួន ការស្អប់ខ្ពើម ការរើសអើង និងកំហឹងផ្ទុយមកវិញ ត្រូវជ្រើសយកសេចក្តីស្រលាញ់និងការអត់ឱនរវាងគ្នានឹងគ្នា ។

២) ប្រជាជនកម្ពុជាខំប្រឹងសហការគ្នានៅក្នុងកាតព្វកិច្ចកសាងអនាគតកាន់តែប្រសើរឡើងសម្រាប់ប្រទេសកម្ពុជា (ប្រទេសមួយដែលមានសន្តិភាព ការអភិវឌ្ឍន៍ ធម្មាធិបតេយ្យ យុត្តិធម៌ផ្នែកច្បាប់ យុត្តិធម៌សង្គមជាដើម)

៣) ប្រជាជនកម្ពុជាអាចបង្កើតសង្គមមួយបែបផ្សេង ។ សង្គមនេះពឹងផ្អែកទៅលើពលរដ្ឋដែលមានការយល់ឃើញដូចគ្នានិងទស្សនវិស័យតែមួយ ជាសង្គមដែលពលរដ្ឋទាំងអស់សហការគ្នានិងសម្រុះសម្រួលឲ្យគ្នាចូលរួមនៅក្នុងការពិភាក្សាយោបល់ល្អជាមួយគ្នា គាំទ្រចំពោះការដោះស្រាយជម្លោះដោយសន្តិវិធី បេះស្រលាញ់ប្រទេសជាតិ ខំប្រឹងគោរពច្បាប់ (ការទទួលខុសត្រូវចំពោះមុខច្បាប់ យុត្តិធម៌សង្គម ច្បាប់ និងសណ្តាប់ធ្នាប់) ហើយដាក់ប្រយោជន៍ជាតិឲ្យខ្ពស់ជាងប្រយោជន៍បុគ្គល ។

៤) មានការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងការគោរពច្បាប់នៅគ្រប់កាលៈទេសៈ ។

៥) ប្រជាជនកម្ពុជាទទួលការអប់រំល្អ ពិសេសអំពីប្រវត្តិសាស្ត្រសម័យទំនើប ដើម្បីឲ្យបានដឹងកាន់តែច្បាស់អំពីរបបខ្មែរក្រហមនិងអំពើប្រល័យពូជសាសន៍ ហើយការពារអំពើឃោរឃៅទាំងអស់មិនឲ្យកើតមានជាថ្មីម្តងទៀត ក៏ដូចជាការថែរក្សានូវការចងចាំអំពីអ្វីដែលបានកើតឡើងដើម្បីក្មេងជំនាន់ក្រោយ ។

### ក) ការផ្សះផ្សានៅកម្ពុជា

### អ្នកឆ្លើយកម្រងសំណួរ

អស់រយៈពេលជាង២៥ឆ្នាំកន្លងមកហើយ កម្ពុជានៅតែមានមិនត្រឹមតែវប្បធម៌នៃការរួចទោសប៉ុណ្ណោះទេ (អង្គជំនុំជម្រះវិសាមញ្ញមិនទាន់ចាប់ផ្តើមដំណើរការនៅឡើយនៅពេលដែលអត្ថបទនេះកំពុងសរសេរឡើង) ថែមទាំងនៅមានអវត្តមាននៃវិធានការដឹកនាំដោយរដ្ឋក្នុងការដោះស្រាយទៅនឹងតម្រូវការផ្នែកចិត្តសាស្ត្ររបស់ប្រជាពលរដ្ឋកម្ពុជា ឬការព្យាយាមដើម្បីស្តាបនាសង្គមឡើងវិញផង ។ រដ្ឋាភិបាលហាក់បីដូចជាកំពុងតែប្រយុទ្ធជាមួយបញ្ហាយុត្តិធម៌ ក៏ដូចជាការព្រួយបារម្ភចំពោះគ្រោះថ្នាក់នៃការធ្លាយចេញការពិតច្រើនពេក ។ ដោយសាររដ្ឋាភិបាលយល់ថាខ្មែរក្រហមបាន «ធ្វើសមាហរណកម្ម» ជាមួយរដ្ឋាភិបាលហើយគ្មានជម្លោះប្រដាប់អាវុធតទៅទៀត អ្វីទាំងនេះត្រូវបាន

ហៅថាជា«ការផ្សះផ្សា» ។ ដូចនេះប្រជាជនទាំងអស់ត្រូវឈប់គិតអំពីអតីតកាល អត់ឱន ហើយបំភ្លេចចោល ឬធ្វើតាមសម្តីរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា «ជីករណ្តៅកប់អតីតកាល» ។

តាំងតែពីការធ្លាក់ចុះនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនខ្មែរត្រូវបានជម្រាបម្តងហើយម្តងទៀតថា ភាពរន្ធត់នៅក្នុងរបបខ្មែរក្រហមត្រូវបានបង្កឡើងដោយពួកខ្មែរក្រហម ដឹកនាំដោយ «បនប្រល័យពូជសាសន៍ ប៉ុល ពត» ។ ទោះបីជាដោយសារការពិតដែលថា មានប្រជាជនតិចតួចប៉ុណ្ណោះដែលដឹងឮអំពីភ័ស្តុតាងផ្នែកច្បាប់ ស្ទើរគ្រប់អ្នកឆ្លើយនឹងកម្រងសំណួរទាំងអស់យល់ថាមេដឹកនាំទាំងនេះពិតជាមានទោសចំពោះបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុតរបស់មនុស្សជាតិ ។ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនខ្មែរត្រូវបានប្រាប់ថា ការផ្សះផ្សាជាមួយនឹងខ្មែរក្រហមគឺជាថ្នូរនឹងសន្តិភាព ។ អ្នកនយោបាយខ្មែរបានប្រើប្រាស់ដោយសេរីនូវពាក្យ «ការផ្សះផ្សា» នៅពេលនិយាយដល់រឿងខ្មែរក្រហម ប៉ុន្តែប្រែប្រួលមិនច្បាស់លាស់ ជួនកាលទាក់ទាញខ្មែរក្រហមឲ្យមកចុះចូលដោយផ្តល់ឲ្យនូវការអភ័យទោសនិងជំនួយ ជួនកាលប្រើប្រាស់កម្លាំងប្រដាប់អាវុធដើម្បីផ្តួលរំលំខ្មែរក្រហម ឯពេលខ្លះទៀតគំរាមគំហែងខ្មែរក្រហមដោយប្រើប្រាស់ការកាត់ទោសដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ។ ប្រជាជនកម្ពុជាបានឃើញនូវហេតុការណ៍គួរឲ្យវង្វេងវង្វាន់នៅពេលដែលឃើញការទទួលស្វាគមន៍មេដឹកនាំខ្មែរក្រហម និងកងកម្លាំងប្រដាប់អាវុធរបស់ជនទាំងនោះឲ្យចូលមករួមរស់នៅក្នុងសង្គមកម្ពុជាវិញក្រោមហេតុផលផ្សះផ្សាជាតិ ទាំងមិនបានរកយុត្តិធម៌ចំពោះការបាត់បង់ជីវិតប្រជាជនខ្មែររាប់លាននាក់និងការឈឺចាប់ដែលខ្មែរក្រហមបានបង្កឡើងផងទេ ។

ពីឆ្នាំ១៩៧៩ ថ្នាក់ដឹកនាំនយោបាយនៅកម្ពុជាមានអតីតកម្មាភិបាលខ្មែរក្រហមដែលអាចត្រូវបានរាប់បញ្ចូលថាជា «ជនដៃដល់» ឬ «អ្នកឈរទិបដៃ» ។ អ្នកជំនាញការមួយរូបបានចង្អុលបង្ហាញថា តាំងតែពីដំបូង សាធារណរដ្ឋប្រជាមានិតកម្ពុជា (រដ្ឋាភិបាលដែលបានបង្កើតឡើងដោយវៀតណាមក្រោយពេលផ្តួលរំលំពួកខ្មែរក្រហម) បានពឹងផ្អែកទៅលើអតីតកម្មាភិបាលខ្មែរក្រហមដែលជាអ្នកកាន់អំណាចក្នុងស្រុក ហើយត្រូវយល់ថាមានសារសំខាន់ក្នុងការឈ្នះសង្គ្រាម និងពង្រឹងអំណាចរបស់របបនេះ «នៅទូទាំងប្រទេស អតីតកម្មាភិបាលភូមិភាគបូព៌ាបានក្លាយទៅជាចៅហ្វាយក្រុងនិងលេខាធិការបក្ស» «កម្មាភិបាលជាច្រើនទទួលបាននូវបទពិសោធន៍ផ្នែករដ្ឋបាលនិងយោធាពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានសារសំខាន់ក្រោយឆ្នាំ១៩៧៩ ។ កម្មាភិបាលទាំងនេះបានបន្សាំខ្លួនទៅនឹងវិន័យសង្គមនិយមនិងរបៀបវារៈសង្គមនិយមមួយ ។ នៅក្រោមកាលៈទេសៈជាហេតុផលធ្វើឲ្យគ្មានដំណើរការ «វិណាហ្សុីនិយម» (ការកែប្រែសង្គមពីរបបដឹកនាំឃោរឃៅឲ្យមកជាភាពធម្មតាវិញ) កើតឡើងទាល់តែសោះនៅកម្ពុជា» ។ អ្នកជំនាញការមួយរូបទៀតបានសង្កេតឃើញថាគ្មានអតីតកម្មាភិបាលខ្មែរក្រហមណាមួយដែលឥឡូវនេះជាសសរទ្រូងនៃរបបថ្មី រៀបរាប់អំពីការសោកស្តាយនៃអតីតកាលឡើយ ។ កម្មាភិបាលទាំងនេះបានកែតម្រូវការចងចាំរបស់ខ្លួនតាមវិធីមួយដែលជនរងគ្រោះជាច្រើនមិនអាចទទួលយកបាន ។ «ពេលមុនគឺពេលមុន» បន្ថែមពីនេះដូចជាចង់និយាយថា «ឥឡូវវាផ្សេង» ។ ផ្ទុយទៅវិញ សម្រាប់ជនរងគ្រោះជាច្រើននៃរបបខ្មែរក្រហម «ពេលមុនអាចកើតឡើងម្តងទៀតគួរឲ្យខ្លាចផ្សាជារៀងរាល់ថ្ងៃ» ។

ក្រៅពីការបំផ្លិចបំផ្លាញ មកទល់បច្ចុប្បន្នមិនទាន់មានការទទួលខុសត្រូវអ្វីក្រៅពីការកាត់ទោសដើម្បីបម្រើផលប្រយោជន៍នយោបាយ និងការព្រមព្រៀងគ្នាដើម្បីបង្កើតឲ្យមានការកាត់ទោសដោយមានការចូលរួមពីអង្គការសហប្រជាជាតិឡើយ ។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ម្នាក់ៗអះអាងអំពី «ការខំប្រឹងគោរពសិទ្ធិមនុស្សនិងអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស» ប៉ុន្តែគ្មាននរណាម្នាក់ពន្យល់ថាមានអ្វីខុសឆ្គងជាមួយនឹងជំនឿពីមុន ឬហេតុអ្វីបានជាមកដល់ពេលឥឡូវទើបដឹងថាខ្លួនខុស ។ ទោះបីជាពាក្យ«លទ្ធិប្រជាធិបតេយ្យ» ត្រូវបានលើកមកនិយាយជាច្រើនលើកច្រើនសាក៏ដោយ ក៏មនុស្សជាច្រើនហាក់មិនដឹងថា លទ្ធិប្រជាធិបតេយ្យមានអត្ថន័យលើសពីការបោះឆ្នោតនិងការគ្រប់គ្រងដោយសំឡេងភាគច្រើនទៅទៀត ។ លទ្ធិប្រជាធិបតេយ្យរួមបញ្ចូលទាំងការបំបែកអំណាចប្រព័ន្ធតុលាការឯករាជ្យមិនប្រកាន់បក្សពួក ការការពារប្រជាជនភាគតិច ការគោរពរបស់រដ្ឋាភិបាលចំពោះសេរីភាព និងសមភាព ព្រមទាំងការទទួលខុសត្រូវ

ចំពោះទង្វើរបស់ខ្លួន និងភាពអត់ធ្មត់ចំពោះការមិនគាំទ្រ ការគាំទ្រពហុនិយម និងការប្រឆាំងដោយអហិង្សា ។

នៅទសវត្សរ៍ឆ្នាំ១៩៩០ ការផ្សះផ្សានៅកម្ពុជាជាពាក្យឯកទេសដែលសំដៅចំពោះការតស៊ូមិនឈប់ឈរ (តែតាមវិធីមិនសូវហិង្សា) ដើម្បីអំណាចរវាងថ្នាក់ដឹកនាំយោបាយរបស់កម្ពុជា ។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៧ សម្តេចនាយករដ្ឋមន្ត្រីទាំងពីររូបបានផ្ញើលិខិតសុំជំនួយពីអង្គការសហប្រជាជាតិ (សំណើនេះត្រូវបានព្រាងដោយបុគ្គលិករបស់អង្គការសហប្រជាជាតិនៅកម្ពុជា) ដែលបានរៀបរាប់ថា យុត្តិធម៌មានសារសំខាន់ណាស់សម្រាប់ការធ្វើឲ្យមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តថភាពនយោបាយជាក់ស្តែងនៅកម្ពុជាដែលរួមបញ្ចូលទាំងការដណ្តើមអំណាចគ្នារវាង សម្តេច ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ការប្រកួតប្រជែងចំពោះការតែងតាំងខ្មែរក្រហម ការប្រើប្រែងធ្វើរដ្ឋប្រហារ និងការដួលរលំនៃចលនាខ្មែរក្រហម មានន័យថា យុត្តិធម៌ដែលមនុស្សភាគច្រើនយល់ថាមិនអាចមាន ត្រូវបានទុកមួយអន្លើដោយយកពាក្យ «ការផ្សះផ្សា» មកដាក់ជំនួសវិញ ។ មកទល់ចុងឆ្នាំ១៩៩៨ «ការផ្សះផ្សា»នេះបានទាត់ចោលយុត្តិធម៌ទាំងស្រុង ហើយបានក្លាយទៅជារបៀបវារៈនយោបាយសំខាន់បំផុត ហើយ«ការផ្សះផ្សា»នេះត្រូវបានលើកឡើងជាប្រចាំថា ជាឱសថទិព្វសម្រាប់ព្យាបាលជំងឺគ្រប់ប្រភេទនៅកម្ពុជា ។ «ការផ្សះផ្សា» ជាហេតុផលដែលមេដឹកនាំទាំងអស់ត្រូវតែដោះស្រាយឲ្យបានប្រុងប្រយ័ត្នបំផុតចំពោះការទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

អ្នកឆ្លើយសំណួរចំនួន៥៣១នាក់ក្នុងចំណោម៧១២ដែលបានចូលរួមនៅក្នុងការស្ទាបស្ទង់មតិ បានផ្តល់យោបល់ចំពោះអត្ថន័យនៃការផ្សះផ្សានិងបង្រួបបង្រួមជាតិ និងធ្វើដូចម្តេចទើបអាចសម្រេចបាននូវគោលដៅនេះ ។ យោបល់ខ្លះមានអត្ថន័យខ្ពស់ ខ្លះទៀតពោរពេញទៅដោយន័យធៀបយ៉ាងក្បោះក្បាយ ។ ពុំសូវមានយោបល់ដែលជាវោហារសាស្ត្រគ្មានភាពស្មោះត្រង់ប៉ុន្មានទេ ។ គ្រប់ចម្លើយទាំងអស់សុទ្ធតែអាចទទួលយកបាននិងស្មោះត្រង់ ។ ទោះបីជាមានភាពលំបាកលំបិនជាប្រចាំនៃជីវិតអ្នកឆ្លើយសំណួរនៅតែអាចប្រមើលអំពីជីវិតរស់នៅក្នុងសង្គមដ៏សាមញ្ញ មានសន្តិភាព និងភាពរុងរឿងមួយ ។ នោះគឺជាសង្គមដែលប្រជាជនទាំងអស់ផ្សះផ្សាគ្នា ហើយអាចរស់នៅនិងប្រកបការងារជាមួយគ្នាដោយសុខស្រួលគ្មានការប្រើប្រាស់អំពើហិង្សា ។ ប្រជាជនកម្ពុជាពោរពេញទៅដោយចក្ខុវិស័យសម្រាប់អនាគតទាំងនេះ មានយោបល់រួមចង់ឲ្យកម្ពុជារីកចម្រើន ហើយរួមគ្នាកសាងប្រទេសជាតិឡើងវិញ ធ្វើឲ្យកម្ពុជាមានវិបុលភាពនិងភាពរីកចម្រើន ហើយអនុវត្តលទ្ធិប្រជាធិបតេយ្យពហុបក្ស ។ ទស្សនវិស័យនៃការចង់បានអនាគតកាន់តែប្រសើរគឺចង់សំដៅទៅលើជីវិតរស់យ៉ាងសាមញ្ញនៅក្នុងប្រទេសរបស់ខ្លួនដោយមិនមានអំពើពុករលួយនិងអំពើហិង្សានិងជាប្រទេសដែលសន្តិភាពនិងយុត្តិធម៌ត្រូវបានបង្កើតឡើងនិងការពារដោយធម្មាធិបតេយ្យ ។

ការអត់ឱននិងការសន្តោសប្រណីបានមកជំនួសការសងសឹកនិងការស្អប់ខ្ពើម ក្រោយពីមានការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ការផ្សព្វផ្សាយជាសាធារណៈនូវការពិតនិងការអប់រំឲ្យបានត្រឹមត្រូវពិសេសអំពីប្រវត្តិសាស្ត្រកម្ពុជា ។ នោះគឺជាប្រទេសកម្ពុជាមួយដែលប្រជាពលរដ្ឋទាំងអស់មានអំនួតហើយស្រលាញ់ ជាប្រទេសកម្ពុជាមួយដែលខុសគ្នាស្រឡះរវាងអតីតកាលនិងបច្ចុប្បន្នកាល ។

ការឆ្លើយតបនៅក្នុងកម្រងសំណួរបានបង្ហាញថា យ៉ាងហោចណាស់មានការផ្សះផ្សាចំនួន៤កម្រិតនៅក្នុងប្រទេសកម្ពុជាគឺ ក្នុងខ្លួន រវាងបុគ្គល ក្នុងសហគមន៍ និងទូទាំងប្រទេស ។ កម្រិតនីមួយៗមានទំនាក់ទំនងគ្នា ។ ការស្ទាបស្ទង់មតិបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការផ្សះផ្សានិងបង្រួមបង្រួមជាតិ គឺការផ្សះផ្សានយោបាយក្នុងទ្រង់ទ្រាយធំ ។ ពិសេសនោះគឺថា អ្នកឆ្លើយសំណួរបានរៀបរាប់អំពីឱ្ឋភាពទាំងអស់ដោយសង្កត់ធ្ងន់ទៅលើវិភាគទានបុគ្គលចំពោះការផ្សះផ្សា ។ ចម្លើយទាំងនេះបានបង្ហាញអំពីការទទួលខុសត្រូវជាបុគ្គលមុនឈានទៅរកការរីកចម្រើននិងសុខសប្បាយទាំងអស់គ្នា ។ ហេតុផលនេះបញ្ជាក់ថា អនាគតរបស់ប្រទេសកម្ពុជាគឺឋិតនៅក្នុងកណ្តាប់ដៃរបស់ពលរដ្ឋទាំងអស់ ប្រសិនបើប្រជាជនកម្ពុជាព្យាយាមធ្វើអ្វីមួយដើម្បីសម្រេចបាននូវសេចក្តីប្រាថ្នា

ទាំងនោះ ។ ខាងក្រោមជាចម្លើយមួយចំនួនដែលបានដកស្រង់÷

◆ ប្រជាជនខ្មែរទាំងអស់ជិះទូកតែមួយជាមួយគ្នា ។

◆ ការផ្សះផ្សាជាតិមានន័យថា ការផ្សារភ្ជាប់គ្នាឡើងវិញនូវទំនាក់ទំនងដែលបែកបាក់ដើម្បីឲ្យប្រជាជនទាំងអស់អាចរួមរស់ជាមួយគ្នាយ៉ាងសុខសប្បាយ ។

◆ ការផ្សះផ្សាជាតិមានន័យថា យើងទាំងអស់គ្នាគួរតែមានតុលាការមួយ ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលខ្មែរក្រហមបានប្រព្រឹត្ត ដើម្បីឲ្យប្រជាជនមានការពេញចិត្តនិងយុត្តិធម៌ ។

◆ ការផ្សះផ្សាជាតិជារឿងមួយ តែការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមជារឿងមួយផ្សេងទៀត ។ ការកាត់ទោសគួរតែធ្វើឡើងជាអន្តរជាតិ ។ ធ្វើដូចនេះទើបប្រជាជនខ្មែរមានអារម្មណ៍ធូរស្បើយ ។ ការផ្សះផ្សាជាតិមានន័យថាបញ្ចប់នូវរឿងមិនល្អអតីតកាលដែលពោរពេញទៅដោយភាពទន្ទាត់ កំហឹង ការគុំកួនជាដើម ។ ក៏ប៉ុន្តែមិនមែនមានន័យថាលុបបំបាត់ចោលអតីតកាលនោះទេ ។

◆ ការផ្សះផ្សាជាតិមានអត្ថន័យដូចគ្នានឹងការអត់ឱន ។ ការអត់ឱនជាអ្វីដែលមនុស្សទូទៅចង់បាន ពីព្រោះថាបើយើងចេះអត់ឱនឲ្យគ្នា សង្គមនឹងអភិវឌ្ឍន៍ទៅមុខ ។

◆ ការផ្សះផ្សាជាតិមិនមែនជាអ្វីដែលមនុស្សមួយនាក់ឬពីរនាក់អាចធ្វើបាននោះទេ វាទាមទារឲ្យមានការចូលរួមពីមនុស្សទាំងអស់និងរដ្ឋាភិបាល ។

លទ្ធផលនៃការស្ទាបស្ទង់បញ្ជាក់ថា សម្រាប់ប្រជាជនកម្ពុជាការផ្សះផ្សាក្តោបបញ្ចូល ទំនាក់ទំនងរវាងប្រជាជនសាមញ្ញនិងខ្មែរក្រហម ប៉ុន្តែវាទូលំទូលាយជាងនេះ ។ ការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរមិនមែនគ្រាន់តែជាការផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះប៉ុណ្ណោះទេ ។ គ្មាននរណាដឹងច្បាស់អំពីអត្តសញ្ញាណរបស់ជនដៃដល់ ដែលមានចំនួនដល់ច្រើនពាន់នាក់ ហើយភាគច្រើនជាកុមារ ។ នៅក្នុងស្ថានភាពបែបនោះ តើត្រូវផ្សះផ្សាជាមួយនរណា? ការផ្សះផ្សារួមបញ្ចូលទាំងទំនាក់ទំនងបុគ្គល សហគមន៍និងជាតិ ហើយមានទំនាក់ទំនងទៅនឹងទស្សនៈនៃការរួបរួមគ្នាជាបុគ្គលផ្នែកនយោបាយ សង្គមសេដ្ឋកិច្ចនិងវប្បធម៌ ។ យ៉ាងហោចណាស់ ការផ្សះផ្សានៅកម្ពុជាក្តោបបញ្ចូលទំនាក់ទំនងរវាងប្រជាជនទូទាំងខេត្តក្រុង អតីតទាហាននៃភាគីទាំងសងខាង ជនរងគ្រោះនិងជនដៃដល់ ទោះបីជននោះចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដោយពេញចិត្តឬមិនពេញចិត្ត ឬជាអ្នកឈរឱបដៃមើលចាំតែគាំទ្រ (តាមរយៈពាក្យសម្តីនិងការនៅស្ងៀមមិនជំទាស់) នៅក្នុងគ្រួសារនិងនៅក្នុងសហគមន៍ក៏ដោយ ។ ការផ្សះផ្សាត្រូវរាប់បញ្ចូលទាំងទំនាក់ទំនងរវាងអ្នកនៅរស់ដែលត្រូវរដ្ឋាភិបាលរឹបអូសយកដីផ្តល់ឲ្យអ្នកចូលសារភាពនិងអ្នកដែលមិនពេញចិត្តចំពោះបរិមាណនៃជំនួយពីបរទេសដែលអ្នកចូលសារភាពទទួលបាន ។ លើសពីនេះ មិនមែនត្រឹមតែអ្នកនៅរស់ទេដែលចាត់ទុកថាខ្លួនជាជនរងគ្រោះ កម្មាភិបាលមួយចំនួននិងបុគ្គលផ្សេងទៀតដែលបានទទួលផលវិបាកពីការចូលរួមនៅក្នុងចលនាខ្មែរក្រហម ក៏មានអារម្មណ៍ថាខ្លួនទទួលរងនូវភាពអយុត្តិធម៌ដែរ ។ ម្យ៉ាងវិញទៀតការផ្សះផ្សានៅកម្ពុជា រួមបញ្ចូលទាំងទំនាក់ទំនងគូបក្ខជិបក្ខនយោបាយអាណិកជនមកពីបរទេស អ្នកមកពីជំរំដែលកាន់កាប់ដោយភាគីនយោបាយផ្សេងៗ និងអ្នកដែលរស់នៅក្នុងប្រទេស ។ អ្នកដែលបានទទួលមរណភាពនិងក្មេងជំនាន់ក្រោយក៏មានចំណែកនៅក្នុងដំណើរការផ្សះផ្សាជាតិនេះដែរ ។

ការរកឃើញទាំងនេះបញ្ជាក់អំពីភាពត្រឹមត្រូវនៃការសន្និដ្ឋានជាទូទៅថា ការផ្សះផ្សាជាទស្សនៈជាក់ស្តែងអាចសម្រេចបាន ។ ការផ្សះផ្សាមានទំនាក់ទំនងទៅនឹងដំណើរការរៀនសូត្រពីវិធីសាស្ត្ររួមរស់ជាមួយគ្នានិងធ្វើការជាមួយនឹងមនុស្សដែលយើងមិនចូលចិត្ត ឬគេមិនពេញចិត្តយើង ហើយជាការទទួលស្គាល់នូវអ្វីដែលបានកើតឡើងនិងលុបបំបាត់ចោលគំនិតអវិជ្ជមាន ទោះបីអ្នកនោះជាជនរងគ្រោះឬជាជនដៃដល់ ។ ការផ្សះផ្សាជាការជួយប្រជាជននិងសង្គមទូទៅឲ្យរស់នៅដោយសុខសាន្ត ។

ហាក់បីដូចជាគ្មានអាថ៌កំបាំងចំពោះការសម្រេចឲ្យបាននូវការផ្សះផ្សានិងការបង្រួបបង្រួមនៅកម្ពុជាឡើយ ។ អ្នកឆ្លើយសំណួរភាគច្រើនអាចផ្តល់យោបល់ពិស្តារជាក់ស្តែងអំពីវិធីសម្រេចឲ្យបាននូវគោលដៅនេះ ។ ទស្សនៈទាំងនេះហាក់បីដូចជាមានទំនាក់ទំនងជាមួយនឹង«ផ្លូវកណ្តាល»របស់ព្រះពុទ្ធសាសនា ។ បុរសម្នាក់មានអាយុ៥៣ឆ្នាំ (អ្នកឆ្លើយលេខ៥៣៨) រស់នៅខេត្តកំពង់ស្ពឺ

ដែលបានបាត់បង់បងប្អូន២១នាក់ រួមមាន (ឪពុកម្តាយ ប្រពន្ធ កូន បងប្អូន និងបងប្អូនជីដូនមួយ) បានសរសេរថា “ជនរងគ្រោះទាំងអស់សូមបំភ្លេចចោលនូវគំនិតចងកម្មពៀរជាមួយជនដែលបានប្រព្រឹត្ត ។ ចំណែកជនដែលបានប្រព្រឹត្តកន្លងមកគួរតែយល់ដឹងដោយខ្លួនឯងថា កន្លងមកខ្លួនបានប្រព្រឹត្តខុសឆ្គងយ៉ាងណា ហើយត្រូវលះបង់គំនិតនោះចោលងាកមករកផ្លូវល្អសាងសីលធម៌វិញ នោះទើបការផ្សះផ្សាបង្រួបបង្រួមជាតិយើងបានផ្លែផ្កាល្អ ។ អ្នកឆ្លើយលេខ១៨២ ភេទប្រុស មានទីលំនៅនៅទីក្រុងភ្នំពេញ យល់ថា “ដើម្បីសម្រេចបាននូវការផ្សះផ្សានិងការបង្រួបបង្រួមជាតិ ប្រជាជនកម្ពុជាចាំបាច់ត្រូវលុបបំបាត់ចោលនូវអំពើពុករលួយ គោរពនិងអនុវត្តតាមច្បាប់ មិនត្រូវរើសអើងឬប្រកាន់ជាតិសាសន៍ ។ យើងត្រូវនាំគ្នាជួយកែច្នៃនូវវាលទំនេរអកម្ម ។ យើងត្រូវកែទម្រង់សេដ្ឋកិច្ចនយោបាយ និងត្រូវបណ្តុះបណ្តាលពលរដ្ឋឬប្រជារាស្ត្រឲ្យមានមោទកភាពចំពោះប្រទេសខ្លួនឯង ។ ប្រសិនបើយើងធ្វើបាននូវចំណុចទាំងនេះ វានឹងបានសម្រេចនូវគោលគំនិតនៃការបង្រួបបង្រួមនិងផ្សះផ្សាប្រទេសជាតិយើងរីកចម្រើនថែមទៀត” ។ អ្នកឆ្លើយលេខ៩ រៀបរាប់អំពីការចៀសវាងជាចាំបាច់នូវ“ការសងសឹកគ្នាទៅវិញទៅមកមិនចេះឈប់ឈរ” ។ អ្នកឆ្លើយរូបនេះនិយាយអំពីសារសំខាន់នៃ“ការធ្វើអ្វីៗគ្រប់បែបយ៉ាង” និង“ដាក់ប្រយោជន៍ជាតិជាអាទិភាព” ។ សម្រាប់អ្នកឆ្លើយរូបនេះ “ការផ្សះផ្សាជាតិមានន័យថាធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីការពារភាពប្រេះឆានិងវិបត្តិមិនឲ្យកើតមានជាថ្មីម្តងទៀតតាមរយៈការបត់បែននិងការយោគយល់គ្នា មិនបង្កឲ្យមានការខឹងសម្បាដែលមានក្នុងចិត្តឲ្យពុះកញ្ជ្រោលឈានដល់ការច្របូកច្របល់ក្នុងសង្គម នោះទើបប្រទេសជាតិយើងគ្មានសង្គ្រាម គឺមានតែសន្តិភាព ភាពសុខដុមសុភមង្គល” ។ ដើម្បីសម្រេចគោលបំណងនេះ គ្រប់ថ្នាក់ដឹកនាំនិងប្រជាជនគ្រប់ស្រទាប់វណ្ណៈត្រូវតែយកប្រយោជន៍ជាតិជាធំសម្រាប់ពេលអនាគត ចៀសវាងការសងសឹកគ្នាទៅវិញទៅមកមិនចេះចប់” ។

ការវិភាគទិន្នន័យសរុបបង្ហាញយ៉ាងច្បាស់ថា អ្នកឆ្លើយភាគច្រើនយល់អំពីអ្វីជាទម្រង់សាមញ្ញនិងស្មោះត្រង់បំផុតនៃការផ្សះផ្សា ។ សម្រាប់អ្នកឆ្លើយទាំងនេះ ការផ្សះផ្សាគឺការរម្ងាប់អារម្មណ៍ដោយខ្លួនឯងចំពោះរឿងរ៉ាវផ្ទាល់ខ្លួន ខំប្រឹងរួមរស់ជាមួយគ្នា ហើយសហការគ្នាដើម្បីសម្រេចឲ្យបាននូវអនាគតដ៏ភ្លឺស្វាង ។ អ្នកឆ្លើយលេខ២៧៧បានសរសេរថា “យើងកំពុងជិះទូកតែមួយសំដៅទៅគោលដៅដូចគ្នា” ។ ស្ត្រីម្នាក់ជាកសិករនៅខេត្តកំពង់ចាម ដែលបានរៀបរាប់អំពីការចាប់ដៃគ្នានិងធ្វើដំណើរទៅមុខ ចង់ឲ្យប្រជាជនកម្ពុជាធ្វើដំណើរចាកចេញពីសង្គមមានវិបត្តិនិងបែកបាក់ទៅកាន់អនាគតរុងរឿងតែមួយជាមួយគ្នា ។ និស្សិតម្នាក់អាយុ១៨ឆ្នាំ (អ្នកឆ្លើយលេខ៣៧២) បញ្ជាក់ថា “ការផ្សះផ្សាជាតិមិនមែនជាអ្វីដែលមនុស្សមួយនាក់ឬពីរនាក់អាចធ្វើបាននោះទេ វាទាមទារឲ្យមានការចូលរួមពីរាជរដ្ឋាភិបាលនិងមនុស្សទាំងអស់” ។

ទស្សនៈអំពីការផ្សះផ្សាជាតិខាងលើជាគំនិតល្អ មិនហួសហេតុ មិនមានការពន្លើស មិនមែនជាគំនិតដែលធ្វើមិនបាន ហើយមិនមែនជាការស្រមើស្រមៃទេ ។ គំនិតខាងលើគឺចង់ឲ្យពលរដ្ឋសាមញ្ញចូលមកសហការគ្នា ហើយអាចរស់នៅធម្មតាសុខសប្បាយជាមួយគ្នា ។ ចំណុចសំខាន់ដែលអ្នកឆ្លើយចង់បាន គឺវិធីកែប្រែសង្គមពីថ្នាក់បុគ្គល ។ ប្រជាជនកម្ពុជាបានបន្សាំទៅនឹងការរស់នៅដោយបាត់បង់យ៉ាងធ្ងន់ធ្ងរ ប៉ុន្តែភាគច្រើនមិនបានទទួលស្គាល់ការពិតនូវអ្វីដែលបានកើតឡើង ហើយការបន្តឲ្យមានការឈឺចាប់ ។ អ្នកខ្លះលាក់ទុកការឈឺចាប់ក្នុងខ្លួន អ្នកខ្លះទៀតក្លាយទៅជាមានវិបត្តិមិនអាចធ្វើការងារអ្វីបាន ឬប្រព្រឹត្តអំពើហិង្សា ។ ដូច្នេះប្រជាជនខ្មែរក៏យល់ឃើញថា ខ្លួនចាំបាច់ត្រូវគ្រប់គ្រងអារម្មណ៍ចំពោះអ្វីដែលបានកើតឡើងចំពោះការឈឺចាប់និងវិបត្តិដែលចេះតែបន្តបំពុលជីវិតរបស់ខ្លួន ។ ប្រជាជនខ្មែរក៏ដឹងដែរថា ការផ្សះផ្សាមិនមែនគ្រាន់តែជាការរួមរស់ជាមួយគ្នាដោយសុខស្រួលប៉ុណ្ណោះទេ ហើយបទពិសោធន៍របស់ខ្លួននៅក្រោមសម័យខ្មែរក្រហមមិនមែនជាបទពិសោធន៍បុគ្គលទេ ប៉ុន្តែជាអ្វីដែលកើតឡើងចំពោះប្រជាជនរាប់លាននាក់ ។ ហេតុនេះប្រជាជនខ្មែរមិនត្រូវបំភ្លេចនូវអ្វីដែលបានឆ្លងកាត់នោះទេ ។

នេះគឺជាការផ្សះផ្សាពីក្រោមឡើងលើ ។ ប្រជាជនខ្មែរបានឃើញនូវការផ្សះផ្សាជាតិពីលើចុះក្រោមរវាងមេដឹកនាំនយោបាយ

ជាន់ខ្ពស់ ប៉ុន្តែវាមិនមានផ្លែផ្កា ។ អ្នកឆ្លើយសំណួរជាច្រើននាក់បានកត់សម្គាល់អំពីតួនាទីរបស់មេដឹកនាំនយោបាយក្នុងការសម្របសម្រួលដល់ការផ្សះផ្សានៅកម្ពុជា ។ ក៏ប៉ុន្តែបទពិសោធន៍មិនគួរជាទីពេញចិត្តទាក់ទងនឹង“ការផ្សះផ្សាជាតិ” រវាងអ្នកនយោបាយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងកង្វះការទុកចិត្តទៅលើអ្នកនយោបាយនៅទូទាំងប្រទេសកម្ពុជាធ្វើឲ្យប៉ះពាល់ដល់អ្វីដែលប្រជាជនចង់បានពីមេដឹកនាំ ។ អ្នកឆ្លើយភាគច្រើនបានឆ្លើយថា អ្នកនយោបាយចាំបាច់ត្រូវយកប្រយោជន៍ជាតិជាធំ ហើយឈប់គិតអំពីប្រយោជន៍ខ្លួននិងបក្សនយោបាយរបស់ខ្លួន ។

## រាជរដ្ឋាភិបាលកម្ពុជា

ការផ្សះផ្សាជាតិត្រូវបានប្រើប្រាស់ដោយមេដឹកនាំកម្ពុជាជាមធ្យោបាយបែងចែកអំណាចគ្នា ដែលជាដំណោះស្រាយទៅនឹងវិបត្តិនយោបាយ ។ ក្រោយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ការដណ្តើមអំណាចគ្នាត្រូវបានលាក់បាំងដោយការយក “ការផ្សះផ្សាជាតិ” មកប្រើប្រាស់ ។ ហេតុការណ៍នេះបានបង្កឲ្យមានស្ថានភាពមិនពេញចិត្តក្រោយពីមានការបោះឆ្នោតឆ្នាំ១៩៩៣ ដែលត្រួតពិនិត្យដោយអ៊ុនតាក់ (គណបក្សហ៊ុនស៊ិនប៉ិចឈ្នះ) ។ ក្រោយពីការបោះឆ្នោត ប្រទេសកម្ពុជាមាននាយករដ្ឋមន្ត្រីពីរ ។ នៅក្នុងក្រសួងនីមួយៗ អនុរដ្ឋមន្ត្រីត្រូវបានតែងតាំងចេញពីគណបក្សដែលមិនមែនជាគណបក្សរបស់រដ្ឋមន្ត្រី ហើយមានអនុរដ្ឋលេខាធិការសម្រាប់ក្រសួងនីមួយៗ ។ ការចង់ផ្សះផ្សាជាមួយនឹងខ្មែរក្រហមដើម្បីទាក់ទាញប្រជាប្រិយភាពសម្រាប់ការបោះឆ្នោតឆ្នាំ១៩៩៨ បានធ្វើឲ្យគណបក្សទាំងពីរទាក់ទាញខ្មែរក្រហមឲ្យចុះចូលក្នុងគណបក្សរបស់ខ្លួន ។ ការធ្វើបែបនេះបានបង្កឲ្យមានភាពប្រេះស្រាំនៅក្នុងរដ្ឋាភិបាលចម្រុះ ហើយទីបំផុតក៏ផ្ទុះឡើងជាជម្លោះប្រដាប់អាវុធនៅឆ្នាំ១៩៩៧ ។

ចំពោះបញ្ហាខ្មែរក្រហម រដ្ឋាភិបាលបានដើរតាមគោលនយោបាយមួយដែលប្រើប្រាស់ដំបូងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានប្រើវិធីសាស្ត្រតែងតាំងអតីតខ្មែរក្រហមឲ្យមានស័ក្តិយសនៅក្នុងរបបថ្មី ។ រដ្ឋាភិបាលបានព្យាយាមសម្រេចការផ្សះផ្សាជាមួយនឹងខ្មែរក្រហមដោយប្រើវិធីសាស្ត្រចផ្អៀតចផ្អុល់ និងតាមវិធីសាស្ត្រនយោបាយ ពោលគឺការបញ្ចប់សង្គ្រាមតាមរយៈការឃោសនាបញ្ចុះបញ្ចូល ឬតាមរយៈការផ្តាញ់ផ្តាលខ្មែរក្រហមនៅលើសមរភូមិ ។ រដ្ឋាភិបាលបានអះអាងថា ដោយសម្រេចបាននូវសន្តិភាពរួចហើយ ឥឡូវនេះកម្ពុជាត្រូវប្រឈមមុខនឹងភារកិច្ចទីពីរ គឺការអភិវឌ្ឍន៍ប្រទេសជាតិ និងបង្កើនកម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជន (ជួនកាលគោលដៅនេះត្រូវបានបកស្រាយថាជាដំណាក់កាលចុងក្រោយនៃការផ្សះផ្សាជាតិ) ។ ការប្រកាសរបស់លោកនាយករដ្ឋមន្ត្រីនៅដើមឆ្នាំ១៩៩៩ឲ្យមានការស៊ើបអង្កេតឲ្យបានពេញលេញទៅលើសង្គ្រាមស៊ីវិល ។ ក៏ប៉ុន្តែគំនិតនេះត្រូវបានបោះបង់ចោលក្នុងរយៈពេលដ៏ខ្លី ។ សំណាងជួសជុលការខូចខាតក្រោយសង្គ្រាម ការចងក្រងជាឯកសារច្បាស់លាស់នូវអ្វីដែលបានកើតឡើងឬការផ្តល់វេទិកាឲ្យជនរងគ្រោះឡើងបកស្រាយនិងរៀបរាប់អំពីការឈឺចាប់របស់ខ្លួនឲ្យអ្នកដទៃដឹងពុំ ក៏មិនដែលមាននៅក្នុងរបៀបវារៈនយោបាយរបស់រដ្ឋាភិបាលដែរ ។ ការណ៍នេះគឺសមស្របទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលចំពោះខ្មែរក្រហមថា “បំបែកញែកចេញ បញ្ចុះបញ្ចូល និងអភិវឌ្ឍន៍” ។ រដ្ឋាភិបាលបានបញ្ចេញអាកប្បកិរិយាហាក់ដូចជាការពិតជាអ្វីដែលគំរាមកំហែងចំពោះអត្ថិភាពរដ្ឋ ។ ប្រាកដណាស់ ការពិតអាចប៉ះពាល់ដល់បុគ្គលទាំងឡាយដែលមានអំណាចកំពូលនៅក្នុងរដ្ឋ ។

សម្រាប់យុត្តិធម៌ ទោះបីជាច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់នៅឆ្នាំ១៩៩៤រៀបរាប់ថា មានគម្រោងកាត់ទោសកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប មិនមានអ្វីបញ្ជាក់ថាអាជ្ញាធរពិតជាមានប្រព័ន្ធយុត្តិធម៌រឹងមាំ ឬសូម្បីតែជាយុត្តិសាស្ត្រទទួលខុសត្រូវមិនដូវការដើម្បីផ្តន្ទាទោសខ្មែរក្រហមក្នុងចំនួនច្រើនដែរ ។ នេះហាក់បីដូចជាលេសដើម្បីទាក់ទាញការចុះចូល ហេតុនេះយុត្តិធម៌មិនមែនជាអ្វីដែលមេដឹកនាំចង់បាននោះទេ ។ ទោះបីជាមានការកាត់ទោសកំបាំងមុខនៅឆ្នាំ១៩៧៩ ទៅលើប៉ុល ពត និង អៀង សារី យុត្តិធម៌ព្រហ្មទណ្ឌគ្រាន់តែក្លាយជាការចាប់អារម្មណ៍នយោបាយថ្មីៗនេះដោយមានការលើកលែងទោសឲ្យ អៀង សារី នៅឆ្នាំ១៩៩៦ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងទេសរដ្ឋមន្ត្រី សុខ អាន បានព្យាយាមផ្សារភ្ជាប់ការចាប់អារម្មណ៍សាជាថ្មីចំពោះការកាត់ទោសទៅនឹងការកាត់ទោសនិងការដាក់ទោសនៅ

ឆ្នាំ១៩៧៩ (ដែលសហគមន៍អន្តរជាតិបដិសេធថាជាការក្លែងបន្លំ) ដើម្បីបកស្រាយពីការចង់បានការទទួលខុសត្រូវតាំងពីយូរមកហើយនិងចៀសវាងការចោទប្រកាន់ថាចង់កេងប្រយោជន៍នយោបាយ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថាកម្ពុជាត្រូវការសន្តិភាពនិងយុត្តិធម៌ ប៉ុន្តែយុត្តិធម៌គួរធ្វើដោយឡែកពីសន្តិភាព ។ សន្តិភាពមានទំនាក់ទំនងជាមួយនឹងការផ្សះផ្សា ។ ដោយសារការផ្សះផ្សា (មានន័យថាការចុះចូលរបស់ខ្មែរក្រហម) បណ្តាលឲ្យមានសន្តិភាព យុត្តិធម៌មិនមានតួនាទីអ្វីទាំងអស់ ហើយថែមទាំងត្រូវបានយល់ថាជាមានគ្រោះថ្នាក់ដល់ប្រទេសជាតិថែមទៀត ។ ការកាត់ទោស (រដ្ឋាភិបាលបានអះអាងនៅឆ្នាំ១៩៩៧ថានឹងកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបាន) អាចត្រូវបានធ្វើឡើងជារូបរាងប៉ុន្តែមិនមែនដើម្បីយុត្តិធម៌ ។

តាមរយៈការវិភាគទៅលើសុន្ទរកថានិងសកម្មភាពរបស់មេដឹកនាំនយោបាយបង្ហាញថា ការកាត់ទោសមិនមែនជាវិធីដើម្បីធ្វើឲ្យមានការផ្សះផ្សាជាតិនោះទេ ។ មេដឹកនាំទាំងនេះគិតថា ការផ្សះផ្សាជាស្ថានភាពមួយដែលការទទួលខុសត្រូវ និងការចងក្រងជាឯកសារនូវអ្វីដែលបានកើតឡើងជាសកម្មភាពមិនអាចទទួលយកបាន ពីព្រោះការធ្វើបែបនេះអាចធ្វើឲ្យមានអស្ថិរភាព ។ ទោះជាមានវោហារសាស្ត្រទាក់ទងទៅនឹងសារសំខាន់នៃយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាក៏ដោយ ក៏ការកាត់ទោសដែលអាចជួយដល់ការជួសជុលសង្គមនិងការផ្សះផ្សាក្នុងរយៈពេលវែងហាក់បីដូចជាមិនបានប៉ះពាល់ដល់គោលនយោបាយរបស់រដ្ឋា-ភិបាលឡើយ ។ ការកាត់ទោសហាក់ដូចជាមិនបានយល់ថា មានសារសំខាន់ក្នុងការពង្រឹងធម្មាធិបតេយ្យតាមរយៈការពង្រឹងជំនឿនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលទេ ។ ការកាត់ទោសក៏មិនត្រូវបានយល់ថាបម្រើផលប្រយោជន៍សង្គម ហើយផ្តល់ឱកាសឲ្យជនរងគ្រោះនូវឱកាសបកស្រាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនឲ្យគេដឹង និងអនុញ្ញាតឲ្យជនដៃដល់ឡើងសារភាពនិងបកស្រាយអំពីហេតុផលផ្ទាល់ខ្លួន ការសុំទោស ឬបង្ហាញពីការសោកស្តាយដែរ ។ សម្តីរបស់នាយករដ្ឋមន្ត្រីនិងទេសរដ្ឋមន្ត្រីបានបង្ហាញយ៉ាងច្បាស់ថា យុត្តិធម៌មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ការផ្សះផ្សាដែលជាដំណើរការយកឈ្នះទៅលើខ្មែរក្រហមនិងបញ្ចុះបញ្ចូលខ្មែរក្រហមទេ ។

ហេតុនេះ រដ្ឋាភិបាលហាក់ដូចជាបានដើរតាមគោលនយោបាយគាំទ្រ "ការទាមទារសន្តិភាព និងការផ្សះផ្សាឲ្យខាងតែបានហើយ គ្រប់គ្រងនិងវាស់វែងយុត្តិធម៌ដោយប្រុងប្រយ័ត្ន ប្រសិនបើមិនអាចចៀសវាងបាន" ។ តាមហេតុផលនៃការផ្សះផ្សានេះមេដឹកនាំខ្មែរក្រហមដែលបានចូលសារភាពនិង "ផ្សះផ្សា" (អៀង សារី, ខៀវ សំផន, នួន ជា) មិនគួរយកទៅកាត់ទោសទេ ។ ផ្ទុយទៅវិញ បុគ្គលដែលនៅជាសត្រូវ (តា ម៉ុក) ឬគ្មានតួនាទីនៅក្នុងការផ្សះផ្សា (ឌុច) អាចនិងគួរកាត់ទោសដើម្បីរកយុត្តិធម៌ ។ អ្វីៗមិនអាចទាយទុកមុនបានទេ ពិសេសប្រសិនបើរដ្ឋាភិបាលរក្សានូវគោលនយោបាយដដែលក្រោយពីបានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដែលក្រោមកិច្ចព្រមព្រៀងនេះ ខៀវ សំផន និង នួន ជា អាចយកទៅកាត់ទោសបាន តែចំពោះ អៀង សារី នៅស្មុគស្មាញ ។

សរុបមក វាមានការលំបាកក្នុងការយកសកម្មភាពរបស់រាជរដ្ឋាភិបាលដើម្បីវាយតម្លៃអំពីការចង់ឲ្យមានការទទួលខុសត្រូវពិតប្រាកដ ។ រដ្ឋាភិបាលហាក់ដូចជាមិនចាប់អារម្មណ៍ចំពោះការជួសជុលសង្គម ការផ្សះផ្សា ឬការពង្រឹងធម្មាធិបតេយ្យដើម្បីធ្វើឲ្យប្រជាជនរស់នៅកាន់តែសុខស្រួលឡើយ ។ ហេតុផលផ្សេងទៀតជាអ្នកកំណត់គោលនយោបាយរបស់រដ្ឋាភិបាល ។

**(នៅមានត)**

**ស៊ុហ្សាណា លីនតុន**

## ពន្យល់ពាក្យខ្មែរក្រហម

**សេរីនិយមៈ** ឥតមានច្បាប់វិន័យ ចេញទៅណាមកណាតែខ្លួន ។

**យោធានិយមៈ** និយមអាវុធ ។

**បុគ្គលនិយមៈ** និយមតែខ្លួនឯង ។

*(ដកស្រង់ចេញពីឯកសារ T.S D ៥១០)*

**សមូហភាពៈ** ការប្រមូលផ្តុំសង្គមមនុស្ស ។

**របបកម្មសិទ្ធិៈ** គឺរបបមានអ្នកមានអ្នកក្រ ពេលគឺមានរបស់ទ្រព្យផ្ទាល់ៗខ្លួនរបស់បុគ្គលម្នាក់នៅក្នុងសង្គម ។

*(ដកស្រង់ចេញពីកំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)*

# អតីតយោធាខេមរភូមិន្ទម្នាក់មានយោបល់ចំពោះ ខៀវ សំផន

ខ្ញុំបាទឈ្មោះ ជុំ តែម អតីតជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី, ខៀវ សំផន ។ សព្វថ្ងៃជាកងយោធាខេមរភូមិន្ទខេត្តកណ្ដាល ។

លោកនិពន្ធនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាជាទីគោរព! ខ្ញុំបាទបានអានសៀវភៅនិពន្ធដោយ ខៀវ សំផន "ប្រវត្តិសាស្ត្រកម្ពុជាថ្មីនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" បានចប់សព្វគ្រប់រួចហើយ ។ ខ្ញុំបានដកស្រង់សម្ដីខ្លះៗរបស់អ្នកនិពន្ធដែលមានអត្ថន័យ ដោះសាមិនទទួលខុសត្រូវទាំងស្រុងក្នុងសម័យឆ្នាំ ១៩៦៧-៧៩ រហូតដល់ ប៉ុល ពត ស្លាប់ ។

ពាក្យដោះសាទាំងអស់ដែលខ្ញុំបានដកស្រង់ចេញពីសៀវភៅនិពន្ធដោយ ខៀវ សំផន មានដូចខាងក្រោម÷

**១) ខៀវ សំផន ចូលសមាជិកមជ្ឈិម"ត្រៀម" នៅឆ្នាំ ១៩៧១ "ពេញសិទ្ធិ" នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ។**

កំណត់សម្គាល់នៃពាក្យទី១នេះ ខ្ញុំយល់ថា ខៀវ សំផន មានតួនាទីដ៏សំខាន់ក្នុងបក្ស ទោះបីជា រូប ខៀវ សំផន ចូលជាសមាជិកធម្មតាក៏ដោយ ប៉ុន្តែក្នុងដំណាក់កាលនោះ ខៀវ សំផន ជាគ្រូបង្រៀន ជាសាស្ត្រាចារ្យ ជាបញ្ញវន្ត និងជាមន្ត្រីជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាលសម្ដេចឪ ពាក្យសម្ដីនិងទង្វើទាំងឡាយរបស់ ខៀវ សំផន អាចធ្វើប្រជាភិថុតិ ធ្វើឲ្យមហាជន ប្រជាជនក្នុងប្រទេសទទួលស្គាល់ យល់តាម ដើរតាម និងកោតសរសើរ ។ ឧទាហរណ៍ដូចករណី ខៀវ សំផន មិនចេះភ្លើតភ្លើន យកត្រីមួយ ឬសាច់ជ្រូកមួយដុំចងខ្សែដាក់ស្ងោរយកជាតិ ហើយលើកម្ហូបនោះទៅទុកសម្រាប់ស្ងោរនៅថ្ងៃបន្ទាប់ទៀត ។ សម្ដេចឪប្រទានរថយន្តឲ្យ ខៀវ សំផន ប៉ុន្តែគាត់ទុកចោលនៅឯផ្ទះ សុខចិត្តជិះកង់ទៅធ្វើការ ។ ពេលទៅធ្វើការ គាត់ស្លៀកពាក់យ៉ាងសាមញ្ញពាក់ស្បែកជើងផ្ទាត់ វេចបាយមួយកញ្ចប់ទឹកមួយដបទៅជាមួយ ។ ដូច្នេះ ខៀវ សំផន មានគោលបំណងច្បាស់លាស់ក្នុងការកំណត់របបសក្ដិភូមិនិងមូលធននិយមតាំងពីដើមមក ។ ទន្ទឹមនឹងការបំពាក់បំប៉នពីលេខាបក្ស ប៉ុល ពត មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា) បានចាប់ផ្ដើមពង្រីកសកម្មភាពរបស់ខ្លួននៅភ្នំពេញ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដូចមានអត្ថន័យក្នុងការនិពន្ធរបស់ ខៀវ សំផន ស្រាប់ ។ ក៏ប៉ុន្តែ ខៀវ សំផន បែរជាឆ្លើយដោះសានូវទង្វើរបស់ខ្លួនទៅវិញ ។

**២) ការបង្ខំចិត្តរត់គេចចេញពីភ្នំពេញនៅឆ្នាំ១៩៦៧ ។**

ចំណុចទី២នេះ ខ្ញុំយល់ឃើញថា ខៀវ សំផន បានដឹងថាប្រទេសជាតិមានសភាពការណ៍មួយដ៏ធូរស្រាលមួយតានតឹង ។ ប្រាកដណាស់ថា បក្សកុម្មុយនិស្តកម្ពុជាមានផែនការវាយរំលំរបបសក្ដិភូមិនិយម ទាំងនយោបាយ ទាំងយោធាក្នុងប៉ុន្មានឆ្នាំខាងមុខជាមិនខាន ។ កន្លងមក ខៀវ សំផន ដែលស្ថិតក្រោមការប្រជុំឬការចាត់តាំងរបស់បក្សកុម្មុយនិស្តកម្ពុជាបានខិតខំធ្វើចលនាបំផុសចិត្តសាស្ត្រ នយោបាយធ្វើប្រជាភិថុតិឥតឆ្អៀលមហាជន ប្រជាជននៅភ្នំពេញ ថ្លៃងពាក្យបំផ្លើសមួលបង្កាច់គ្រប់បែបយ៉ាងធ្វើឲ្យព្រះរាជាណាចក្រទី១ចុះអន់ខ្សោយ ។ អូសទាញកម្លាំងមហាជនឲ្យដើរតាមខ្លួនឬបក្សខ្លួន ។ ដូច្នេះ ខៀវ សំផន បានធ្វើការសម្រេចជូនបក្សមួយភាគធំក្នុងឆ្នាំង១៩៦៧ ។ មកដល់ដំណាក់កាលតស៊ូអាវុធ ខៀវ សំផន បានទទួលការទុកចិត្តពីបក្សកុម្មុយនិស្តកម្ពុជាដាច់ខាត តួនាទីដ៏ខ្ពស់អំពីបក្សនៅក្នុងក្បាលម៉ាស៊ីនបក្សកុម្មុយនិស្តកម្ពុជា ។ ខៀវ សំផន ត្រូវប្ដូរទិសដៅដឹកនាំគឺរត់ចូលព្រៃដែលមាន ប៉ុល ពត, អៀង សារី និង តាម៉ុក ។ល ។ នៅរង់ចាំក្នុងមូលដ្ឋានបង្អែកជាស្រេច ដូចយើងបានអានសៀវភៅ ខៀវ សំផន ក្នុងឃ្លាមួយ "នៅពេលយើងខ្ញុំចុះពីលើផ្លូវថ្នល់ យើងខ្ញុំបានឃើញថា មានវិធានការការពារហ្មត់ចត់ ។ មានមនុស្សយាមតាមផ្លូវមិនឃ្លាតឆ្ងាយពីគ្នាប៉ុន្មានទេ ហើយមានឮពាក្យស្ងោកបណ្ដាក់គ្នាចប់តែផ្លូវ" ។ ចំណុចនេះខ្ញុំយល់ថា ខៀវ សំផន មានឋានៈមិនតូចទេក្នុងបក្សកុម្មុយនិស្តកម្ពុជា ដូចមានការធ្វើបដិសណ្ឋារកិច្ចដើម្បីទទួល ខៀវ សំផន ក្នុងថ្ងៃចូលមូលដ្ឋានដំបូង ។

**៣) នៅចុងបញ្ចប់នៃជំពូកទីបួន ខៀវ សំផន សរសេរថា "គួរឲ្យរំភើបចិត្ត ពីព្រោះខ្ញុំឃើញកម្លាំងថ្មីកំពុងលេចចេញជារូបរាង**

ដែលជាកម្លាំងពិតប្រាកដ» ។

យើងអាចដឹងពីទឹកចិត្តរបស់ ខៀវ សំផន យ៉ាងច្បាស់ពីមូលហេតុដែលគាត់រត់ចូលក្នុងទីតាំងបផ្អែកនេះ គឺដើម្បីចូលរួមរៀបចំផែនការតស៊ូប្រដាប់អាវុធជាមួយគណៈកម្មការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដើម្បីផ្តួលរំលំ...រាល់ការប្រជុំ រាល់ការសម្រេចទាំងឡាយរបស់បក្សកុម្មុយនិស្តកម្ពុជា ក្នុងនាមជាក្បាលម៉ាស៊ីន ខៀវ សំផន ត្រូវទទួលខុសត្រូវដឹកនាំកម្លាំងតស៊ូប្រយុទ្ធមួយផ្នែកធំ ។ ស្តាប់តាមការសរសេររបស់ ខៀវ សំផន គាត់មិនភ្លេចទេពីរឿងនយោបាយប្រជាភិថុតិ មួយម៉ាត់ណាក៏ប្រជាកសិករ មួយម៉ាត់ណាក៏បំផុសពីចលនា«ភ្នំវាយចាប» កងទ័ពព្រះរាជាណាចក្រទី១កាត់កប្រជាជន បំផុសកំហឹងប្រជាជនដើម្បីឲ្យប្រជាកសិករបច្ចុប្បន្ននេះមានកំហឹងឈឺចាប់ជាមួយ ។ ខៀវ សំផន មិនបោលទេរឿងញុះញង់បំភ័ន្តភ្នែកដែលជាកិច្ចការ ខៀវ សំផន ប្រើកន្លងមកដែលធ្វើឲ្យមនុស្សស្លាប់រាប់លាននាក់ ។

**៤) ខៀវ សំផន រន្ធត់ចិត្តពីរឿងជម្លៀសប្រជាជនចេញពីទីក្រុង ។**

នៅចុងខែមីនា ឆ្នាំ១៩៧៥ ខៀវ សំផន បានមករស់នៅទីបញ្ជាការរួមរបស់បក្សកុម្មុយនិស្តកម្ពុជាដែលតាំងនៅភូមិដូងឃុំស្រែអណ្តូង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ នៅទីនោះជាទីបញ្ជាការសមរភូមិ ភូមិភាគនិរតី បញ្ជានិងតាមដានការវាយសម្រុកចូលទីក្រុងភ្នំពេញ ។ ដូចពាក្យ ខៀវ សំផន និយាយឥតខុសថា គាត់ជាអ្នកដឹកនាំកំពូលម្នាក់ក្នុងបក្សកុម្មុយនិស្តកម្ពុជាចូលរួមដឹកនាំបញ្ជានិងរកគ្រប់វិធីប៉ុកលល្បិច ក្បួនយុទ្ធសាស្ត្រនយោបាយ ពង្រឹងជំហរបច្ចេកទេសប្រយុទ្ធឲ្យកងទ័ពនិងប្រជាជនក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន មានសមត្ថភាពវាយខ្មាំងសត្រូវឲ្យបានជោគជ័យ ។

រីឯផែនការជម្លៀសប្រជាជនពីភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះក៏មិនហួសអ្វីពីផែនការរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដែរ ដែលមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន និង តាម៉ុក ដែលជាអ្នកចេញបញ្ជាឲ្យមេទ័ពខ្មែរក្រហមគ្រប់មុខព្រួញទាំងអស់អនុវត្តព្រមគ្នា ជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ។ ខ្ញុំនៅចាំច្បាស់ណាស់នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមត្រូវបានចែកចេញជាក្រុមតូចៗ មួយក្រុមមានគ្នា៣-៤នាក់ ដើរកាន់ក្បាលមេក្រូស្រែកជំទាលថា «បងប្អូនពុកម៉ែដែលនៅក្នុងទីក្រុងភ្នំពេញទាំងអស់គ្នា អង្គការស្នើសុំឲ្យចេញពីលំនៅឋានចំនួន៣ថ្ងៃសិន ខ្លាចក្រែងមានយន្តហោះទម្លាក់គ្រាប់បែកមកលើទីក្រុង» ។

តើនរណាជាអង្គការ? អង្គការគឺគណៈកម្មាធិការមជ្ឈិមបក្ស, គណៈតំបន់, គណៈស្រុក, គណៈឃុំ, គណៈភូមិ, ទីបញ្ជាការរួម, ទីបញ្ជាការសមរភូមិ, កងឈ្លប, ប៉ុល ពត, អៀង សារី, ខៀវ សំផន, តាម៉ុក, កម្មាភិបាលគ្រប់ជាន់ថ្នាក់, អង្គការថ្នាក់ភូមិ, ឬអង្គការថ្នាក់មជ្ឈិម ។ ទាំងនេះគឺជាអង្គការ ។

ខ្ញុំគិតថា ប្រសិនបើ ប៉ុល ពត នៅរស់ តើ ខៀវ សំផន អាចធ្វើពុតសម្រក់ទឹកភ្នែកអាណិតប្រជាជនយ៉ាងម៉េច? រន្ធត់ចិត្តយ៉ាងម៉េច? ខៀវ សំផន ពិតជាមិនហ៊ានធ្វើពុតទេ ។

**៥) ខ្ញុំមិនសូវយល់ដឹងប៉ុន្មានទេអំពីការវិវត្តន៍នៃសភាពការណ៍នៅតាមព្រំដែន ។**



យុន យ៉ាត

ស្ទើរតែគ្រប់ទំព័រសៀវភៅ ខៀវ សំផន បានសរសេរតែនយោបាយនិងផែនការវៀតណាមមានគំនិតក្តោបក្តាប់ទឹកដីកម្ពុជា វៀតណាមចង់ត្រួតត្រាបក្សកុម្មុយនិស្តកម្ពុជា វៀតណាមចង់ត្រួតត្រាឥណ្ឌូចិន ។ ខៀវ សំផន ស្អប់វៀតណាមដល់ឆ្អឹង ការកើតមានសង្គ្រាមរវាងខ្មែរ-វៀតណាមនៅព្រំប្រទល់រហូតដល់មានកងទ័ពរបួសពេញមន្ទីរពេទ្យភ្នំពេញ រហូតដល់គាត់មានតួនាទីស្វែងរកបង់រុំរបួសនិងថ្នាំសង្កូវសម្រាប់កងទ័ពដែលរបួសទៀតផង ។ ហេតុអ្វីក៏ ខៀវ សំផន ឆ្លើយថាមិនយល់ដឹងប៉ុន្មានអំពីសង្គ្រាមនៅព្រំដែនកម្ពុជា-វៀតណាម ។

**៦) ខ្ញុំចាត់ទុកព្រឹត្តិការណ៍ទាំងអស់នោះដែលកើតឡើងជាកំហុសនយោបាយឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ហើយមិនឃើញថាជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរនោះទេ ។**

ខ្មែរក្រហមក៏តំណាងឲ្យនិន្នាការមួយដែលចង់បានយុត្តិធម៌សង្គម ប្រឆាំងអំពើពុករលួយ និងអំពើដែលអ្នកមានធ្លៀតកេងប្រវ័ញ្ចលើទុក្ខវេទនារបស់អ្នកក្រខ្សត់ ។



សមមិត្ត ខៀវ សំផន

នៅត្រង់ចំណុចនេះ ខៀវ សំផន កាន់តែមិនទទួលខុសត្រូវអំពីបទប្រល័យពូជសាសន៍ថែមទៀត ហើយថែមទាំងនិយាយថាការសម្លាប់ដ៏ឃោរឃៅទៅលើប្រជាជនរាប់លាននាក់នោះជាកំហុសនយោបាយ ។ ខៀវ សំផន មិនឃើញថាជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរត្រង់ណាសោះ ។ ទន្ទឹមនឹងនោះ ខៀវ សំផន បានលើកតម្កើងពីរភាពរបស់របបខ្លួនទៀតផង ។

**៧) ខ្ញុំមានសំណូមពរសុំស្នើថា កុំឲ្យការពិភាក្សាវែកញែកនោះប្រទាញយើងឲ្យធ្លាក់នៅក្នុងបរិយាកាសគុំកួននិងមន្ទិលសង្ស័យមិនចេះចប់នោះទៀត ។ សន្តិភាពនិងស្ថិរភាពនៃប្រទេសយើងអាស្រ័យលើសមត្ថភាពរបស់យើងទាំងអស់គ្នា ធ្វើយ៉ាងណារក្សាស្មារតីនឹងនឲ្យបាន ហើយហ៊ានមើលប្រវត្តិសាស្ត្រជាតិជាក់ស្តែងដែលប្រទេសយើងទើបបានឆ្លងកាត់ថ្មីៗនេះឲ្យចំនិងឲ្យច្បាស់ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។**

ចំណុចទី៧នេះ ខៀវ សំផន បានគំរាមកំហែងក្រុមអ្នកច្បាប់ដែលព្យាយាមបង្កើតតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលខាងមុខ ក៏ដូចជាគំរាមកំហែងដល់ប្រជាជន ឬក៏ប្រកាសប្រាប់ដល់ជនទាំងឡាយណាដែលកំពុងគាំទ្រមេខ្មែរក្រហមនៅប៉ៃលិនឲ្យចេះឈឺចាប់ នៅពេលជនរងគ្រោះឬតុលាការកាត់ទោសឲ្យបនប្រល័យពូជសាសន៍ត្រូវជាប់ពន្ធនាគារអស់មួយជីវិត ។ បានន័យថា បន្ទាប់ពីតុលាការកាត់ទោសឬចេញសាលក្រមអូសកមេខ្មែរក្រហមដែលនៅសេសសល់ឲ្យចូលគុកមួយជីវិតនោះប្រទេសកម្ពុជាច្បាស់ជាមានសង្គ្រាមម្តងទៀតមិនខាន ។

**៨) អ្នកសង្កេតការណ៍ខ្លះបានសម្តែងនូវការមន្ទិលសង្ស័យថា កសិករទាំងនោះបានត្រូវខ្មែរក្រហមកៀរមក ។ ខ្ញុំពុំអាចជឿយ៉ាងនេះបានទេ ។**

ចំណុចនេះគឺមិនខុសអ្វីពីការមន្ទិលសង្ស័យរបស់អ្នកសង្កេត-ការណ៍នោះទេ រូបខ្ញុំនេះហើយដែលជាជនរងគ្រោះម្នាក់ដែលខ្មែរក្រហមកៀរយកទៅតាំងពីភូមិភាគបូព៌ារហូតភូមិភាគពាយ័ព្យ (ខេត្តពោធិសាត់) ។ ខ្ញុំនិងអ្នកភូមិចំនួន៣០០គ្រួសារត្រូវខ្មែរក្រហមកៀរយកទៅសម្លាប់ ។ អ្នកភូមិស្លាប់អស់ជាងពាក់កណ្តាលនៅសល់ប៉ុន្មានកុំតែបានរត់រួច ម៉្លេះត្រូវខ្មែរក្រហមកៀរឡើងភ្នំអស់ ហើយមិនដឹងជាស្លាប់ប៉ុន្មានទៀតទេ ចុះប្រជាជននៅភូមិ

ដទៃទៀតមានវាសនាយ៉ាងណា? ត្រូវសម្លាប់ ត្រូវកៀរឡើងភ្នំ ត្រូវព្រាត់ប្រាសដោយសារអ្នកណា? ខៀវ សំផន និយាយថា ពួកគេ(ខ្មែរក្រហម)គ្មានពេលឯណាកៀរប្រជាជនទៅជាមួយទេ ព្រោះខ្លួនកំពុងរត់ប្រញាប់ប្រញាល់ ។

រឿងជាក់ស្តែងមួយទៀតគឺអ្នកភូមិខ្ញុំបានរត់រួចពីការកាប់សម្លាប់ ហើយធ្វើដំណើរមកដល់ភូមិស្នាមព្រះ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិសាត់ ត្រូវខ្មែរក្រហមមួយក្រុមដេញបាញ់ប្រហារនិងសម្លាប់ ។ អ្នកភូមិទាំងនោះត្រូវបានប្រមូលទាំងហ្វូងសំដៅឡើងលើភ្នំនិងសម្លាប់ចោល ។ ខ្មែរក្រហមកៀរប្រជាជនយកទៅជាមួយធ្វើជារនាំងការពារខ្លួនកុំឲ្យវៀតណាមបាញ់ ។ វាពិតជាអសោចកេរ្តិ៍ណាស់ ខៀវ សំផន មិនចាំបាច់និយាយកែខ្លួនទេ មិនបាច់បំផុសចលនាអ្វីទៀតទេ ក្នុងពេលបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាស្អប់ខ្ពើមសង្គ្រាមណាស់ កុំនាំប្រជាជនឲ្យដើរតាមខ្លួន លំបាកវេទនាស្លាប់ឥតប្រយោជន៍ទៀត ។ បងប្អូនអតីតខ្មែរក្រហមនិងគ្រួសារទាំងអស់គ្នាកំពុងមានសេចក្តីសុខហើយ ។

**៩) ចំពោះខ្ញុំ លំដាប់ណាខ្ញុំមិនទាន់រកចម្លើយបាន ខ្ញុំនៅតែមានចិត្តមួយគិតថា ទិសដែលបានតម្រង់ជីវិតរបស់ខ្ញុំរហូតមកដល់ពេលនេះដោយតម្កល់កិច្ចការការពារឯករាជ្យនិងអធិបតេយ្យភាពជាតិ ជាបុព្វសិទ្ធិ នោះវានៅតែត្រឹមត្រូវដោយចាំបាច់ជានិច្ច ។**

នៅពេលនេះ ខៀវ សំផន កំពុងទាមទាររកចម្លើយហើយ មានន័យថា ត្រូវតែមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីឲ្យដឹងថាតើគាត់មានទោសឬអត់? ខៀវ សំផន ចេះតែនិយាយពីអំពើឆោតល្ងង់របស់ខ្លួនតាំងពីមុនមករហូតដល់ឥឡូវ ឆោតល្ងង់មិនទទួលខុសត្រូវ ឆោតល្ងង់មិនហ៊ានសារភាពពីទោសកំហុសឆោតល្ងង់ហ៊ាននិយាយកែប្រែប្រវត្តិសាស្ត្រ ញុះញង់ឲ្យកូនខ្មែរស្គាល់តែសេចក្តីវិនាសហិនហោចប្រទេសជាតិមិនស្គាល់ការការអភិវឌ្ឍន៍ ។ មនុស្សឆោតល្ងង់ តាមសម្គាល់មនុស្សនោះមានគំនិតតឹងរឹងកោងកាច ឃោរឃៅ ធ្វើអ្វីតាមតែចិត្តនឹកឃើញ ។

នេះខ្ញុំគ្រាន់តែដកស្រង់ប្រយោគខ្លះៗប៉ុណ្ណោះ ពីព្រោះថារូបខ្ញុំមិនអាចយល់បាននូវខ្លឹមសារនៅក្នុងសៀវភៅទាំងស្រុងទេ ។ ខៀវ សំផន សរសេរតែអំពីវីរភាពរបស់ខ្លួនសម័យដែលខ្លួនបានឋិតនៅក្នុងរបបផ្តាច់ការផ្ទាល់ ។ ខៀវ សំផន នៅតែធ្វើជាមិនដឹងថា ប្រជាជនកម្ពុជាភាគច្រើននិងសកលលោកទាំងមូលស្អប់ខ្ពើមរបបខ្លួន គេមិនគាំទ្រ រហូតដល់អង្គការចាត់តាំងរបស់របបខ្លួនត្រូវរលំរលាយ ។

ខៀវ សំផន នៅតែចិញ្ចឹមចិត្តគាំទ្ររបបប្រល័យពូជសាសន៍ ដូចឃ្លាថា "ខ្ញុំយល់ឃើញថា ខ្ញុំត្រូវតែឈរនៅខាងកម្លាំងណាដែលខ្ញុំមើលទៅឃើញថាជាកម្លាំងជាតិមួយដែរ ឲ្យតែកម្លាំងនោះប្រឆាំងនឹងអំពើរំលោភបំពានលើអធិបតេយ្យភាពរបស់យើង ទោះបីមានមតិជាតិយើងខ្លះយល់ឃើញថា កម្លាំងនោះអាក្រក់យ៉ាងនេះយ៉ាងនោះក៏ដោយ ។ ទោះបីមានក្រោយៗមកទៀតមានទំនាស់ជាច្រើនក្នុងការប្រព្រឹត្តរបស់គេក៏ដោយ ។ ការគិតគូររបស់ខ្ញុំ នៅពេលដែលប្រទេសមានអាសន្ន គឺធ្វើដូចម្តេចឲ្យតែប្រទេសខ្មែរបានឆ្លងផុតគ្រោះថ្នាក់សិន ទើបបញ្ហាអ្វីផ្សេងទៀតអាចដោះស្រាយបាន" ។

ក្នុងឃ្លា ខៀវ សំផន នេះបានន័យថា ជនរងគ្រោះក្នុងឆ្នាំ ១៩៧៥-៧៩ ត្រូវតែសម្លាប់ចោល ត្រូវតែបង្អត់បាយ ត្រូវតែធ្វើការជាទម្ងន់ ដើម្បីជួយឲ្យប្រទេសជាតិឆ្លងកាត់គ្រោះថ្នាក់សិន ទើបក្រោយមកអាចដោះស្រាយគ្នាបាន ។ ខៀវ សំផន នៅតែយល់ថា ទង្វើទាំងអម្បាលម៉ាននៅក្នុងអំឡុង៣ឆ្នាំ៨ខែ និង២០ថ្ងៃ ជាទង្វើរក្សាទឹកដីនិងស្នេហាជាតិ ។

ជាបន្តទៅនេះ ខ្ញុំបាទសូមសំណូមពរដ៏ទទូចដូចខាងក្រោម÷

◆ បងប្អូនទាំងអស់ដែលធ្លាប់បម្រើនិងគាំទ្រ ខៀវ សំផន, អៀង សារី, នួន ជា រហូតមកដល់សព្វថ្ងៃនេះ កុំជឿនូវពាក្យសម្តីញុះញង់ឲ្យបងប្អូនលំបាកវេទនាទៀត ។

◆ ប្អូនៗយុវជន-យុវនារីសម័យថ្មីនេះ សូមកុំជឿនៅពេលបានអាននិងបានស្តាប់ការនិយាយរបស់ ខៀវ សំផន ក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាថ្មី...ចូរប្អូនខិតខំស្វែងយល់ពីមតិនិងមជ្ឈដ្ឋានភាគច្រើនដែលមិនគាំទ្រការសរសេររបស់ ខៀវ សំផន ។

◆ សូមឲ្យរាជរដ្ឋាភិបាលអាណត្តិទី៣និងអង្គការសហប្រជាជាតិមេត្តាជំរុញល្បឿននៃការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ ។

**ជុំ តែម**

# អ្នកភូមិត្រពាំងកកោះសុំឱ្យជួយរកគ្រួសារ

“មេឃត្រជាក់ទឹកកូនទឹកចៅ” ជាសម្តីរបស់លោកយាយ ជុំ ឆន អាយុ៦៥ឆ្នាំ មានទីលំនៅ ភូមិត្រពាំងកកោះ ឃុំដូនយ៉យ ស្រុកឈូក ខេត្តកំពត ។ ភូមិកកោះមិននៅជាប់នឹងផ្លូវជាតិទេ ។ ខ្ញុំបានធ្វើដំណើរដោយរថយន្តចុះពីផ្លូវគ្រួសក្រហមឆ្លងកាត់តាមខ្នងទំនប់ដែលមានប្រវែងជាង៥គីឡូម៉ែត្រនិងត្រូវធ្វើដំណើរដោយថ្មើរជើងក្នុងចម្ងាយជាង៣គីឡូម៉ែត្រទៀតទើបទៅដល់ ។ ប្រជាជនជាច្រើននាក់នៅក្នុងភូមិនេះដែលធ្លាប់ទៅបម្រើបដិវត្តន៍ខ្មែរក្រហមត្រូវបាត់ខ្លួនមិនឃើញវិលមកវិញសោះ ។ ក្នុងដំណើរ កាត់ភ្លៀងរលឹមស្រិចៗ ទៅកាន់ផ្ទះម្ចាស់ប្រវត្តិរូបម្នាក់ឈ្មោះ មិន យឿន ឆ្លងកាត់វាលស្រែដាច់កន្ទុយភ្នែក ខ្ញុំបានជួបយាយ ជុំ ឆន ដែលកំពុងតែរានដីស្រែ ។ បន្ទាប់ពីការសួរនាំរកហេតុផល គាត់សប្បាយចិត្តយ៉ាងខ្លាំង ព្រោះគិតថាក្រុមខ្ញុំមានដំណឹងអំពីកូនស្រីរបស់គាត់ឈ្មោះ លន ថារី ។ ថារី បានចូលបដិវត្តន៍ជាមួយអ្នកភូមិជាច្រើននាក់ទៀតនៅសាលាឃុំដូនយ៉យ ។ ថារី ត្រូវអង្គការជ្រើសរើសឲ្យទៅធ្វើការនៅភ្នំពេញហើយបានបាត់ខ្លួនរហូត ។ យាយឆន និយាយថា គាត់រង់ចាំ ថារី រហូតដល់សព្វថ្ងៃ ។ ក្តីសង្ឃឹម


អ្នកភូមិកំពុងសាកសួរពត៌មានពីក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

របស់ យាយឆន ហាក់មានតិចតួចណាស់ ព្រោះរយៈពេលជាង ២០ឆ្នាំកន្លងផុតទៅហើយ គាត់ពុំដែលបានទទួលដំណឹងអ្វីបន្តិចសោះពី ថាវី ។ ចំណែក សុខ ម៉ាច អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិជាមួយយាយឆន ដែរ បានប្រាប់ខ្ញុំថា "ជួយរកកូនស្រីរបស់ខ្ញុំផង វាឈ្មោះ ញ៉ៀត រ៉ែង ហៅ រ៉េត" ។ ញ៉ៀត រ៉ែង ហៅ រ៉េត ក៏មានរឿងរ៉ាវប្រហាក់ប្រហែលនឹង ថាវី និងអ្នកផ្សេងទៀតដែរ ។ ទាំងភ្លៀងរលឹមនៅកណ្តាលវាលស្រែ ខ្ញុំបានកត់ឈ្មោះនេះទុកដើម្បីកុំឲ្យភ្លេច ។ ម៉ាច បានថ្លែងអំណរគុណដល់ក្រុមខ្ញុំនិងសង្ឃឹមថាក្រុមខ្ញុំនឹងជួយធ្វើឲ្យអារម្មណ៍របស់គាត់បានធូរស្រាលឡើង ។ ខ្ញុំបានសន្យាចំពោះគាត់ថានឹងចុះផ្សាយដំណឹងនេះនៅក្នុងទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ខ្ញុំឈរស្តាប់រឿងរ៉ាវទាំងឡាយរបស់បងប្អូនអ្នកស្រុកនៅកណ្តាលវាលស្រែ ។ ពូៗខ្លះកំពុងតែខិតខំភ្ជួររាស់ទាំងកណ្តាលភ្លៀងនិងខ្លះទៀតកំពុងឆាយដីលើកទំនប់ភ្លឺស្រែទប់ទឹកកុំឲ្យហូរចេញពីស្រែ ។ នៅឯនាយប្រហែល២០០ម៉ែត្រពីទីតាំងខ្ញុំឈរ មីងម្នាក់រត់សំដៅមកខ្ញុំទាំងខ្លួនទទឹកជោក ។ គាត់ឈ្មោះ ជ័យ សុខ ហៅ ជ័យ ណាស់ អាយុ៣៦ឆ្នាំ ជាជនជាតិចាម ។ ណាស់ បានរៀបរាប់ប្រាប់ខ្ញុំព្រមទាំងធ្វើកាយវិការថា គាត់បានបាត់ដំណឹងសូន្យឈឹងពីបងប្រុសរបស់គាត់ចំនួនបីនាក់គឺ ជ័យ យន់, ជ័យ នី និង ជ័យ ឡោះ ។ ដោយសារ ណាស់ មានវ័យក្មេងពេកកាលពីជំនាន់ខ្មែរក្រហម ទើបគាត់ពុំបានដឹងរឿងរ៉ាវទាក់ទងនឹងជីវិតបងប្រុសរបស់គាត់ទាំងបីឡើយ ។ គាត់គ្រាន់តែដឹងថា បងប្រុសរបស់គាត់ធ្លាប់បានធ្វើការបម្រើខ្មែរក្រហម ។ ណាស់ បានទទូចសុំឲ្យខ្ញុំជួយស្រាវជ្រាវរកបងប្រុសទាំងបីរបស់គាត់ផង ទោះជាតាមវិធីណាក៏ដោយ ។ ខ្ញុំបានព្យាយាមពន្យល់គាត់ដូចដែលខ្ញុំបានពន្យល់ទៅ សុខ ម៉ាច និង ជុំ ឆន ដែរ ។

បន្ទាប់ពីចំណាយពេលអស់រយៈពេលជិតមួយម៉ោងនៅកណ្តាលវាលស្រែ ខ្ញុំនិងអ្នកភូមិបានបន្តដំណើររួមគ្នាឆ្ពោះទៅលំនៅឋានរបស់ មិន យឿន ជាម្ចាស់ប្រវត្តិរូបដែលខ្ញុំចង់ជួប ។ ភ្លៀងនៅតែធ្លាក់រ៉ាវៗមិនដាច់ ។ ពេលទៅដល់ផ្ទះរបស់ មិន យឿន ខ្ញុំបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមគ្រួសាររបស់គាត់និងអ្នកជិតខាង ។ យឿន ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលស្មោះស្ម័គ្រនឹងអង្គការបដិវត្តន៍ ។ នៅក្នុងរបបខ្មែរក្រហម យឿន ពុំដែលពិបាកនឹងការងារឡើយ ។ គាត់បានប្រៀបធៀបការងារនៅក្នុងរបបខ្មែរក្រហមថាងាយស្រួលជាងបច្ចុប្បន្ន ។ យឿន នៅតែមានទំនុកចិត្តចំពោះអង្គការខ្មែរក្រហមថាបានធ្វើឲ្យខ្លួនគាត់មានការងារល្អៗធ្វើនិងបានសប្បាយជាមួយនឹងការមើលកុនល្ខោននិងរាំរែក ។ បច្ចុប្បន្ន យឿន មានគ្រួសារនិងមានកូនក្នុងបន្ទុក ។ កម្រិតជីវភាពរបស់ យឿន ស្ថិតក្នុងស្ថានភាពមិនគាប់ប្រសើរប៉ុន្មានទេ ។ យឿន សប្បាយចិត្តនឹងការនាំរំឭករឿងរ៉ាវរបស់គាត់ ព្រមទាំងបានសួរនាំពីការបាត់ខ្លួន មិន យ៉ាត់ ដែលត្រូវជាប្អូនបង្កើតរបស់គាត់ផង ។ ខ្ញុំមានប្រវត្តិរូបរបស់ មិន យ៉ាត់ ដែរ ។ យឿន និង យ៉ាត់ បានរត់ចេញពីភ្នំពេញជាមួយគ្នានៅពេលដែលរបបខ្មែរក្រហមត្រូវវាយបណ្តេញដោយកងទ័ពវៀតណាម ប៉ុន្តែអ្នកទាំងពីរបានបែកគ្នានៅពាក់កណ្តាលផ្លូវដោយ យឿន វិលត្រឡប់មកស្រុកកំណើត ហើយ យ៉ាត់ បន្តដំណើរទៅមុខជាមួយកម្មាភិបាលដូចគ្នាជាច្រើននាក់ទៀត ។ រហូតមកដល់សព្វថ្ងៃ យឿន នៅតែទន្ទឹងរង់ចាំផ្លូវ យ៉ាត់ ជានិច្ច ។ ។

ពេលត្រឡប់មកពីផ្ទះរបស់ យឿន វិញ ខ្ញុំឃើញអ្នកភូមិជាច្រើននាក់ចោមរោមរថយន្តរបស់ក្រុមខ្ញុំដែលចតនៅក្រោមដើមអម្ពិលទឹក ។ អ្នកភូមិទាំងនោះបានឃាត់ដំណើរក្រុមរបស់ខ្ញុំនិងសំណូមពរឲ្យជួយស្រាវជ្រាវរកសាច់ញាតិដែលបានបាត់ខ្លួននៅក្នុងពីជំនាន់ខ្មែរក្រហមផង ។

នៅម៉ោង៦និង១៨នាទីល្ងាច ខ្ញុំបានចាកចេញពីភូមិត្រពាំងកកោះដោយពាំនាំមកជាមួយនូវដំណឹងស្វែងរកគ្រួសាររបស់អ្នកភូមិ និងពត៌មានរបស់ម្ចាស់ប្រវត្តិរូបឈ្មោះ មិន យឿន ។ ខ្ញុំសប្បាយចិត្ត ព្រោះខ្ញុំយល់ថាការងាររបស់ខ្ញុំបានជួយចែករំលែកទុក្ខលំបាករបស់ប្រជាជនក្នុងភូមិកកោះ និងកាត់បន្ថយនូវគំនិតស្មុគស្មាញរបស់គាត់ព្រមទាំងបានជួយព្យាបាលជំងឺផ្លូវចិត្តដែលរ៉ាំរ៉ៃជាយូរយារមកហើយ ។

**ផេង ពង្សរ៉ាស៊ី**

# សេចក្តីប្រកាសរកកូនស្រី

នាងខ្ញុំឈ្មោះ ចាន់ ស្រៀប អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិជីប្រាប ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។

សូមសួរកូនស្រីឈ្មោះ អ៊ុំច សារឿន ហៅ យឿន បានចូលបម្រើបដិវត្តន៍នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៤ ។ មុនបែកភ្នំពេញឆ្នាំ១៩៧៥ យឿន បម្រើការក្នុងកងនារីសែងរបួសនៅវត្តអង្គកែវ ឃុំអង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ ។ នៅឆ្នាំ១៩៧៦ យឿន បានផ្ញើសំបុត្រមកផ្ទះម្តង ប្រាប់ថាធ្វើពេទ្យនៅភ្នំពេញ ។ ប្រហែល៩ឆ្នាំមុន យឿន បានផ្ញើសំបុត្រមកភូមិកំណើតម្តងទៀត ប្រាប់ថារស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នាងខ្ញុំបានឲ្យកូនប្រុសទៅរក ប៉ុន្តែរកមិនឃើញ ។ តាំងពីពេលនោះមកក៏បាត់ដំណឹង យឿន រហូត ។ មកដល់បច្ចុប្បន្ន យឿន មានអាយុប្រហែល៤០ឆ្នាំ ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះខាងលើសូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុស

នាងខ្ញុំឈ្មោះ សុខ ភាច អាយុ៧៨ឆ្នាំ មានស្រុកកំណើតនិងរស់នៅភូមិពោន ឃុំត្រឡាច ស្រុកទ្រាំង(១០៨) ខេត្តតាកែវ ។ នាងខ្ញុំមានកូន១២នាក់ សព្វថ្ងៃនៅរស់៧នាក់ ។

សូមសួររកកូនប្រុសឈ្មោះ កង ទង ហៅ កង សារឿន មានឈ្មោះបដិវត្តន៍ គឹម កើតឆ្នាំមមែ ។ គឹម បានចេញទៅបម្រើបដិវត្តន៍ខ្មែរក្រហមក្នុងអាយុ១៧ឆ្នាំ មាននាទីជាទាហានជើងទឹក ។ គឹម បានបាត់ខ្លួនចាប់តាំងពីរបបខ្មែរក្រហមដួលរលំមកម្ល៉េះ ។ ប្រសិនបើ គឹម នៅរស់មកដល់សព្វថ្ងៃនេះ មានអាយុប្រហែល៥០ឆ្នាំ ។

ប្រសិនបើអស់លោក-លោកស្រីមានពត៌មានអំពីឈ្មោះខាងលើ សូមមេត្តាផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។



សកម្មភាពលើកទំនប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 55, July 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**